ក

មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

១. ព្រះរាជក្រម

២០-៧-២០០៧ -ព្រះរាជក្រម នស/រកម/០៧០៧/០២២ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ក្រោមទឹក ៥៩៥៧

២០-៧-២០០៧ -ព្រះរាជក្រម នស/រកម/០៧០៧/០២៣ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពី ការកំណត់ចំនួនអាសនៈរដ្ឋសភា នីតិកាលទី ៤ ៦០០៩

២. ព្រះរាជក្រឹត្យ

២៨-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/៣១៥ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ង្វៀន ធៀនញ៉ាន** (NGUYEN THIEN NHAN) ជនជាតិវៀតណាម សញ្ជាតិវៀតណាម កើតនៅខេត្តហ្វានធៀន ប្រទេសវៀតណាម ដោយប្តូរឈ្មោះជា **ឡាយ ស៊ុនមិញ** (LAY SUN MINH) ៦០១១

២៨-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/៣១៦ ស្តីពីការតែងតាំងឯកឧត្តម **ឌួង សុធន** ជានាយករងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋលេខាធិការ ៦០១២

២៨-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/៣១៧ ស្តីពីការតែងតាំងឯកឧត្តម **ឃឹម បូរ** ជាអគ្គលេខាធិការរង រាជរដ្ឋាភិបាលមានឋានៈស្មើ រដ្ឋលេខាធិការ ៦០១៣

២៨-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/៣១៨ ស្តីពីការតែងតាំងឯកឧត្តម **ឈុន ស៊ីរុន** ជាអភិបាលខេត្តកណ្តាល ជំនួសឯកឧត្តម **ឃឹម បូរ** ដែលត្រូវបានទទួលភារកិច្ចថ្មី ៦០១៤

៣០-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/៣១៩ ស្តីពីការបន្ថយរយៈពេលទទួលរងទោស និងលើកលែងទោសឱ្យទណ្ឌិតដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ៦០១៥

៣០-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/៣២០ ស្តីពីការតម្លើងឋានន្តរស័ក្តិ ថ្នាក់នាយឧត្តមសេនីយ៍ផ្កាយមាសបួន ជូនឯកឧត្តម ឧត្តមសេនីយ៍ឯក **ខុល គៀន** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៦០២២

០១-៨-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៨០៧/៣២១ ស្តីពីការតែងតាំងឯកឧត្តម **ជិវ សុខហាក់** ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ រដ្ឋលេខាធិការ ជំនួសឯកឧត្តម **ម៉ុន ហុង** ដែលត្រូវបានតែងតាំងជាអនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌	៦០២៣

II~ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ

សេចក្តីសំរេច

២៧-៧-២០០៧	-សេចក្តីសំរេចរួមលេខ ០០៥ ព.រ.ក ស្តីពីការបង្កើតបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈសម្រាប់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ	៦០២៤

III~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

២៧-៧-២០០៧	-អនុក្រឹត្យលេខ ៨៩ អនក្រ.បក ស្តីពីការប្រែក្លាយសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល	៦០៣៤
៣១-៧-២០០៧	-អនុក្រឹត្យលេខ ៩០ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា	៦០៤៧
២៥-៧-២០០៧	-អនុក្រឹត្យលេខ ៦០១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៦០៤៩
២៥-៧-២០០៧	-អនុក្រឹត្យលេខ ៦០២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៦០៥០
២៦-៧-២០០៧	-អនុក្រឹត្យលេខ ៦០៣ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ	៦០៥១
២៦-៧-២០០៧	-អនុក្រឹត្យលេខ ៦០៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ	៦០៥២
២៦-៧-២០០៧	-អនុក្រឹត្យលេខ ៦០៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៦០៥៣
២៦-៧-២០០៧	-អនុក្រឹត្យលេខ ៦០៦ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	៦០៥៤
២៦-៧-២០០៧	-អនុក្រឹត្យលេខ ៦០៧ អនក្រ.តត ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិ ដើម្បីការពារ និង អភិវឌ្ឍន៍រមណីយដ្ឋានវប្បធម៌ធម្មជាតិ នៃប្រាសាទព្រះវិហារ	៦០៥៥
២៦-៧-២០០៧	-អនុក្រឹត្យលេខ ៦០៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៦០៥៧
២៦-៧-២០០៧	-អនុក្រឹត្យលេខ ៦០៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៦០៥៩
២៦-៧-២០០៧	-អនុក្រឹត្យលេខ ៦១០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	៦០៦០
២៦-៧-២០០៧	-អនុក្រឹត្យលេខ ៦១១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៦០៦១
២៦-៧-២០០៧	-អនុក្រឹត្យលេខ ៦១២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	៦០៦២

២៦-៧-២០០៧ -អនុក្រឹត្យលេខ ៦១៣ អនក្រ.បក ស្តីពីការផ្តល់គោរមងារ 6063
២៧-៧-២០០៧ -អនុក្រឹត្យលេខ ៦១៤ អនក្រ.បក ស្តីពីការផ្តល់គោរមងារមុនីសារាភ័ណ្ឌ 6064
២៨-៧-២០០៧ -អនុក្រឹត្យលេខ ៦១៥ អនក្រ.បក ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ និង នាយទាហានជាន់ខ្ពស់ ៦០៦៦
២៨-៧-២០០៧ -អនុក្រឹត្យលេខ ៦១៦ អនក្រ.បក ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ៦០៦៨
៣០-៧-២០០៧ -អនុក្រឹត្យលេខ ៦១៧ អនក្រ.បក ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៦០៧០
៣០-៧-២០០៧ -អនុក្រឹត្យលេខ ៦១៨ អនក្រ.បក ស្តីពីការដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍ ៦០៧២
៣០-៧-២០០៧ -អនុក្រឹត្យលេខ ៦១៩ អនក្រ.បក ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៦០៧៣
៣០-៧-២០០៧ -អនុក្រឹត្យលេខ ៦២០ អនក្រ.បក ស្តីពីការផ្តល់គោរមងារស្ថាបនាជាតិ ៦០៧៤

២-សារាចរ

២៧-៧-២០០៧ -សារាចរលេខ ០៣ សរ ស្តីពីវិធានការពង្រឹងប្រព័ន្ធគ្រប់គ្រង និង ត្រួតពិនិត្យការធ្វើអាជីវកម្មសម្ភារៈកសិកម្ម ៦០៧៦

៣-សារាចរណែនាំ

០៨-៦-២០០៧ -សារាចរណែនាំលេខ ០៤ សរ.ណន ស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ៦០៨០

IV-ការងារបណ្តាក្រសួង

ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

១២-៦-២០០៧ -ប្រកាសលេខ ៤៦៥ សហវ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ ២០០៧ (ត មកពីរាជកិច្ច លេខ ៤៩...ដល់...៥៧) ៦០៩៨

ព្រះរាជក្រម

នស/រកម/០៧០៧/០២២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៧នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី
នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចការពារ
បេតិកភណ្ឌវប្បធម៌ក្រោមទឹក

មាត្រា ១.-

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលអនុម័តកាលពីថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០០១ នៅទីក្រុងប៉ារីស ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញាអន្តរជាតិនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នស/រកម.០៧០៧.៣១៥

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
រដ្ឋមន្ត្រីស្តីទី

ហត្ថលេខា

ហ៊ឹម ឆែម

ចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៧
អគ្គនាយកនៃអគ្គលេខាធិការដ្ឋានរដ្ឋាភិបាល

ឃួន ប៉ិនភេន

អនុសញ្ញា
ស្តីពី
កិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក

សន្និសីទកំពូលរបស់អង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ ដែលបានប្រជុំនាទីក្រុងប៉ារីស ចាប់ពីថ្ងៃទី ១៥ ខែ តុលា ដល់ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០០១ នាសម័យប្រជុំលើកទី៣១ :

ដោយទទួលស្គាល់ ពីសារៈសំខាន់នៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកក្នុងនាមជាផ្នែកមួយ នៃបេតិកភណ្ឌរបស់មនុស្សជាតិ និងក្នុងនាមជាធាតុផ្សំយ៉ាងសំខាន់ពិសេសរបស់ប្រវត្តិសាស្ត្ររបស់មនុស្ស របស់បណ្តាប្រជាជាតិទាំងឡាយ និងទំនាក់ទំនងទៅវិញទៅមក ដែលទាក់ទងទៅនឹងបេតិកភណ្ឌរួម

ដោយយល់ឃើញថា វាជាការចាំបាច់បំផុតក្នុងការការពារ និងថែរក្សាបេតិកភណ្ឌវប្បធម៌ក្រោមទឹក ហើយដែលការទទួលខុសត្រូវលើភារកិច្ចនេះធ្លាក់ទៅលើរដ្ឋទាំងអស់

ដោយពិនិត្យឃើញថា សាធារណជនកាន់តែមានការចាប់អារម្មណ៍ និងឱ្យតម្លៃខ្ពស់លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក

ដោយជឿជាក់ ពីសារសំខាន់នៃការសិក្សាស្រាវជ្រាវព័ត៌មាន និងការអប់រំដើម្បីកិច្ចការពារ និងការថែរក្សាបេតិកភណ្ឌវប្បធម៌ក្រោមទឹក

ដោយជឿជាក់ថា សាធារណជនមានសិទ្ធិទទួលបាននូវផលប្រយោជន៍ខាងការអប់រំ និងការកំសាន្តសប្បាយព្រមទាំងការបើកចំហប្រកបដោយការទទួលខុសត្រូវ និងគ្មានការគំរាមកំហែងលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ហើយដែលការអប់រំសាធារណជនបានរួមចំណែកក្នុងការធ្វើឱ្យការវាយតម្លៃ ការការពារ និងការយល់ដឹងពីបេតិកភណ្ឌប្រភេទនេះកាន់តែប្រសើរឡើង

ដោយយល់ឃើញថា រាល់អន្តរាគមន៍ទាំងឡាយណា ដែលគ្មានការអនុញ្ញាត ឱ្យប្រព្រឹត្តទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក គឺជាការគំរាមកំហែងមួយចំពោះបេតិកភណ្ឌប្រភេទនេះ ហើយដែលចាំបាច់ត្រូវចាត់វិធានការម៉ឺងម៉ាត់ជាងនេះ ដើម្បីរារាំងអន្តរាគមន៍បែបនេះ

ដោយយល់ច្បាស់ពី ការចាំបាច់ក្នុងការបង្ការនូវផលប៉ះពាល់ជាអវិជ្ជមាន នៃសកម្មភាពស្របច្បាប់ជាយថាហេតុមួយចំនួន ដែលអាចកើតមានលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក

ដោយព្រួយបារម្ភយ៉ាងខ្លាំងអំពី ការកើនឡើង នៃអាជីវកម្មបែបពាណិជ្ជកម្មលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក និងជាពិសេសសអំពីសកម្មភាពមួយចំនួន ដែលមានគោលបំណងលក់ដូរ ធ្វើលទ្ធកម្ម ឬដោះដូរបំណែកទាំងឡាយនៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក

ដោយយល់ឃើញ ការអភិវឌ្ឍន៍ផ្នែកបច្ចេកវិទ្យាជួយសម្រួលដល់ការស្រាវជ្រាវ និងរកឃើញនូវបេតិកភណ្ឌវប្បធម៌ក្រោមទឹក

ដោយជឿជាក់ថា កិច្ចសហប្រតិបត្តិការរវាងបណ្តារដ្ឋ បណ្តាអង្គការអន្តរជាតិ ស្ថាប័នវិទ្យាសាស្ត្រ អង្គការវិជ្ជាជីវៈ បុរាណវត្ថុវិទូ អ្នកមុជទឹក ភាគីពាក់ព័ន្ធនឹងមហាជន គឺជាការចាំបាច់បំផុតដើម្បីការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក

ដោយយល់ឃើញថា បុរេសនា[១] កំណាយ និងកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ទាមទារជាចាំបាច់នូវលំហូរចូល និងការពឹងផ្អែកលើវិធីបែបវិទ្យាសាស្ត្រពិសេស និងការប្រើប្រាស់បច្ចេកទេស និងសម្ភារៈសមស្រប ក៏ដូចជាវិជ្ជាជីវៈ ឯកទេសកម្រិតខ្ពស់ដែលគេហៅថា លក្ខណៈវិនិច្ឆ័យឯកភាព

ដោយយល់ច្បាស់ពីភាពចាំបាច់ ក្នុងការតាក់តែងជាក្រម និងអភិវឌ្ឍនូវវិធានគតិយុត្ត ដែលទាក់ទងទៅនឹងការការពារ និងការថែរក្សាបេតិកភណ្ឌវប្បធម៌ក្រោមទឹក ស្របតាមនីតិអន្តរជាតិ និងទំនៀមទម្លាប់អន្តរជាតិ ជាពិសេសអនុសញ្ញារបស់អង្គការយូណេស្កូ ពាក់ព័ន្ធនឹងវិធានការដែលត្រូវប្រកាន់យក សំដៅហាមឃាត់ និងទប់ស្កាត់ការនាំចូល ការនាំចេញ និងការផ្ទេរកម្មសិទ្ធិខុសច្បាប់ នៃសម្បត្តិវប្បធម៌ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៧០ នៃអនុសញ្ញារបស់អង្គការយូណេស្កូសម្រាប់ការការពារបេតិកភណ្ឌពិភពលោក បេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៧២ និងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨២

ដោយព្រួយបារម្ភ ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃវិធានការ ដែលត្រូវប្រកាន់យកក្នុងកម្រិតអន្តរជាតិ តំបន់ និងជាតិ ដើម្បីថែរក្សាផ្នែកទាំងឡាយនៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ក្នុងគោលដៅវិទ្យាសាស្ត្រ ឬការការពារ ដើម្បីប្រមូលយកមកវិញ នូវបេតិកភណ្ឌទាំងនោះ

ក្រោយពីធ្វើការសម្រេច ក្នុងសម័យប្រជុំលើកទីម្ភៃប្រាំបួនរបស់ខ្លួន បញ្ហានេះនឹងក្លាយជាកម្មវត្ថុ នៃអនុសញ្ញាអន្តរជាតិមួយ អនុសញ្ញានេះទទួលបានការអនុម័ត នៅថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០០១ ។

មាត្រា ១.- និយមន័យ

ក្នុងន័យនៃអនុសញ្ញានេះ មានពាក្យសព្ទមួយចំនួនដូចខាងក្រោម :

១ (ក) បេតិកភណ្ឌវប្បធម៌ក្រោមទឹកសំដៅដល់ រាល់ដានស្នាមនៃអត្ថិភាពរបស់មនុស្ស ដែលមានចរិតលក្ខណៈវប្បធម៌ប្រវត្តិសាស្ត្រ ឬបុរាណវត្ថុវិទ្យាដែលលិចក្នុងទឹកមួយផ្នែក ឬទាំងស្រុង តាមកាលកំណត់ទៀងទាត់

---

[១] Prospection : ការរកអណ្តូងរ៉ែ

ឬជាអចិន្ត្រៃយ៍តាំងពីរយៈពេលមួយរយឆ្នាំ(១០០) យ៉ាងតិចមានជាអាទិ៍ :

(ក១) រមណីយដ្ឋាន រចនាសម្ព័ន្ធ អាគារ វត្ថុ និងសំណល់ឆ្អឹងរបស់មនុស្ស ព្រមទាំងបរិបទបុរាណវត្ថុវិទ្យា និងធម្មជាតិរបស់របស់ទាំងនេះ

(ក២) នាវា យន្តហោះ យានយន្តដទៃទៀត ឬរាល់ភាគនៃរបស់ទាំងនេះ ដោយមាននាវាកណ្តូ ឬបន្ទុកដទៃទៀត និងព្រមទាំងបរិបទបុរាណវត្ថុវិទ្យា និងធម្មជាតិ និង

(ក៣) រាល់វត្ថុទាំងឡាយ ដែលមានលក្ខណៈសណ្ឋានជាបុរេប្រវត្តិ ។

(ខ) បំពង់បង្ហូរប្រេង ឧស្ម័ន និងខ្សែកាបួដែលដាក់ ឬដំឡើងក្នុងជម្រៅសមុទ្រ មិនចាត់ទុកជាផ្នែកនៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកឡើយ។

(គ) សំណង់ក្រៅពីបំពង់បង្ហូរប្រេង ឧស្ម័ន ឬខ្សែកាបួដែលដាក់ ឬតំឡើងក្នុងជម្រៅសមុទ្រ ហើយដែលកំពុងប្រើប្រាស់នៅឡើយមិនចាត់ទុកជាផ្នែកនៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកឡើយ ។

២. (ក) រដ្ឋភាគី សំដៅដល់រដ្ឋទាំងឡាយដែលយល់ព្រមភ្ជាប់កាតព្វកិច្ចដោយអនុសញ្ញានេះ ហើយដែលអនុសញ្ញានេះចូលជាធរមានចំពោះរដ្ឋទាំងនោះ

(ខ) អនុសញ្ញានេះអនុវត្តចំពោះទឹកដីដែលមានចែងក្នុងមាត្រា ២៦ កថាខណ្ឌទី ២ (ខ) ដែលក្លាយជាភាគីនៃអនុសញ្ញានេះ ស្របតាមលក្ខខណ្ឌដូចបានកំណត់ក្នុងកថាខណ្ឌនេះដែលទាក់ទិនទៅនឹងទឹកដីនីមួយៗ។ ក្នុងន័យនេះ ពាក្យ " រដ្ឋភាគី " សំដៅដល់ទឹកដីទាំងនេះ ។

៣. យូណេស្កូ សំដៅដល់អង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ ។

៤. អគ្គនាយក សំដៅដល់អគ្គនាយករបស់អង្គការយូណេស្កូ។

៥. តំបន់ " ហ្សូន " សំដៅដល់ជម្រៅបាតសមុទ្រ និងស្រទាប់ដីខាងក្រោមរបស់សមុទ្រ ដែលហួសពីដែនកំណត់យុត្តាធិការជាតិ ។

៦. អន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក សំដៅដល់សកម្មភាពមួយដែលមានកម្មវត្ថុជាចម្បងគឺ បេតិកភណ្ឌវប្បធម៌ក្រោមទឹក ហើយដែលអាចប៉ះពាល់ជាខ្លាំងដល់បេតិកភណ្ឌនេះ ឬរាល់សកម្មភាពដែលបណ្តាលឱ្យមានការប៉ះពាល់ ឬការខូចខាតផ្សេងទៀតដោយផ្ទាល់ ឬដោយប្រយោល ។

៧. អន្តរាគមន៍ដែលមានផលវិភាគដោយចៃដន្យចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក សំដៅដល់សកម្មភាពមួយដែលទោះបីមាន ឬគ្មានផលប៉ះពាល់ជាសំខាន់ ឬមួយផ្នែកណាទោះចំពោះកម្មវត្ថុនៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកក្តី ក៏អាចប៉ះពាល់ដល់បេតិកភណ្ឌនេះ ឬបង្កឱ្យមានការខូចខាតផ្សេងទៀត ។

៨. នាវា និងយន្តហោះរបស់រដ្ឋ សំដៅដល់នាវាចម្បាំង ឬយន្តហោះដែលជាកម្មសិទ្ធិរបស់រដ្ឋណាមួយ ឬដែលធ្វើប្រតិបត្តិការក្រោមការត្រួតពិនិត្យរបស់រដ្ឋនោះ ប្រើប្រាស់ដោយផ្តាច់មុខនៅខណៈពេលដែលយន្តហោះ ឬនាវាចម្បាំងទាំងនោះលិច ក្នុងគោលដៅសេវាសាធារណៈ មិនមែនពាណិជ្ជកម្ម ដែលត្រូវបានគេធ្វើអត្តសញ្ញាណកម្មដូចនេះ

ហើយដែលឆ្លើយតបទៅនឹងនិយមន័យនៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ។

៩. វិធានទាំងឡាយគឺសំដៅដល់ វិធានទាំងឡាយណាពាក់ព័ន្ធទៅនឹងអន្តរាគមន៍ ដែលធ្វើឡើងទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដូចបានរៀបរាប់ក្នុងមាត្រា ៣៣ នៃអនុសញ្ញានេះ ។

មាត្រា ២.- គោលបំណង និងគោលការណ៍ទូទៅ

១. អនុសញ្ញានេះមានគោលបំណងធានា និងពង្រឹងការការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ។

២. រដ្ឋភាគីទាំងឡាយសហការគ្នាក្នុងកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ។

៣. រដ្ឋភាគីទាំងឡាយថែរក្សាការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដើម្បីជាផលប្រយោជន៍របស់មនុស្សជាតិ ស្របតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ ។

៤. រដ្ឋភាគីទាំងឡាយចាត់វិធានការជាឯកត្តជន ឬជារួម ស្របតាមអនុសញ្ញានេះ និងស្របតាមនីតិអន្តរជាតិដែលចាំបាច់ ដើម្បីកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដោយប្រើប្រាស់មធ្យោបាយដែលសមស្របបំផុតទៅតាមសមត្ថភាពរៀងៗខ្លួន ។

៥. កិច្ចអភិរក្សបេតិកភណ្ឌវប្បធម៌ក្រោមទឹក ត្រូវចាត់ទុកជាជម្រើសអាទិភាពមុនបង្អស់ចំពោះរាល់អន្តរាគមន៍ទាំងឡាយណាមកលើបេតិកភណ្ឌនេះ ដែលមិនទាន់ទទួលបានការអនុញ្ញាត ។

៦. ផ្នែកទាំងឡាយនៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលរកបានមកវិញត្រូវចាត់វិធានការតម្កល់ទុក រក្សាទុក និងគ្រប់គ្រងយ៉ាងណាដើម្បីធានាកិច្ចអភិរក្សដែលមានលក្ខណៈយូរអង្វែង ។

៧. បេតិកភណ្ឌវប្បធម៌ក្រោមទឹកមិនត្រូវប្រើប្រាស់ជាកម្មវត្ថុនៃអាជីវកម្មបែបពាណិជ្ជកម្មណាមួយឡើយ ។

៨. ស្របតាមការអនុវត្តតៗគ្នានៃរដ្ឋទាំងឡាយ និងស្របតាមនីតិអន្តរជាតិ ជាពិសេសអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ គ្មានបទប្បញ្ញត្តិណាមួយនៃអនុសញ្ញានេះ ដែលអាចត្រូវបានបកស្រាយដូចជាផ្លាស់ប្តូរវិធានទាំងឡាយនៃនីតិអន្តរជាតិ និងការអនុវត្តតៗគ្នានៃបណ្តារដ្ឋទាំងឡាយទាក់ទងទៅនឹងអភ័យឯកសិទ្ធិអធិបតេយ្យ ឬសិទ្ធិណាមួយរបស់រដ្ឋណាមួយនោះដែលទាក់ទងទៅនឹងនាវា និងយន្តហោះរបស់រដ្ឋនោះឡើយ ។

៩. រដ្ឋភាគីទាំងឡាយធានាថា រាល់សំណល់ឆ្អឹងរបស់មនុស្សទាំងអស់ ដែលលិចក្នុងដែនទឹកសមុទ្រត្រូវបានគោរពយ៉ាងម៉ឺងម៉ាត់ ។

១០. រដ្ឋគួរលើកទឹកចិត្តឱ្យសាធារណជន មានការចូលរួមប្រកបដោយការទទួលខុសត្រូវ និងមិនមានការភ័យខ្លាចចំពោះការងារបេតិកភណ្ឌវប្បធម៌ក្រោមទឹក តែក្នុងគោលដៅសង្កេតការណ៍ ឬការងារឯកសារប៉ុណ្ណោះ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ចំណាប់អារម្មណ៍របស់សាធារណជនចំពោះបេតិកភណ្ឌប្រភេទនេះ ក៏ដូចជាចូលរួមចំណែកក្នុងការលើកតម្លៃនិងការការពារបេតិកភណ្ឌប្រភេទនេះផងដែរ លើកលែងតែក្នុងករណីណា ដែលកិច្ចការនេះមាន

លក្ខណៈវិសមិតភាពជាមួយនឹងមុខងាររបស់គាត់។

១១. គ្មានសកម្មភាព ឬអំពើណាមួយដែលធ្វើឡើងលើមូលដ្ឋាននៃអនុសញ្ញានេះ អាចអនុញ្ញាតឱ្យមានសិទ្ធិវាយតម្លៃ សិទ្ធិគាំទ្រ ឬសិទ្ធិប្រឆាំងនឹងការទាមទារអធិបតេយ្យភាព ឬ យុត្តាធិការជាតិឡើយ។

មាត្រា៣.- ទំនាក់ទំនងរវាងអនុសញ្ញានេះ និងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ

គ្មានបទប្បញ្ញត្តិណាមួយនៃអនុសញ្ញានេះធ្វើឱ្យប៉ះពាល់ដល់សិទ្ធិយុត្តាធិការ និងករណីយកិច្ចរបស់រដ្ឋទាំងឡាយក្នុងក្របខណ្ឌនៃច្បាប់អន្តរជាតិ រួមទាំងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ។ អនុសញ្ញានេះត្រូវបកស្រាយ និងអនុវត្តក្នុងបរិបទ និងស្របតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់អន្តរជាតិ រួមទាំងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ។

មាត្រា៤.- ទំនាក់ទំនងជាមួយសិទ្ធិទទួលជំនួយ និងសិទ្ធិទទួលផលប្រយោជន៍ពីកំណប់

គ្មានសកម្មភាពណាមួយទាក់ទងទៅនឹងបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលគ្រប់គ្រងដោយអនុសញ្ញានេះចំពោះនឹងសិទ្ធិទទួលជំនួយ និងសិទ្ធិទទួលផលប្រយោជន៍ពីកំណប់ឡើយ លើកលែងតែ :

ក. សកម្មភាពនោះត្រូវបានអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ច និង

ខ. សកម្មភាពនោះស្របទាំងស្រុងនឹងអនុសញ្ញានេះ និង

គ. សកម្មភាពនោះធានាថា កិច្ចការពារជាអតិបរមានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ខណៈពេលដែលរាល់ប្រតិបត្តិការនៃការទទួលយកមកវិញត្រូវបានធានា។

មាត្រា៥.- សកម្មភាពដែលមានឧប្បត្តិហេតុដោយចៃដន្យចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក

រដ្ឋជាភាគីនីមួយៗប្រើប្រាស់មធ្យោបាយសមស្របបំផុតដែលខ្លួនមាន ដើម្បីទប់ស្កាត់ ឬកាត់បន្ថយរាល់ផលវិបាកជាអវិជ្ជមាន បណ្តាលមកពីសកម្មភាពទាំងឡាយណា ដែលទាក់ទិនទៅនឹងយុត្តាធិការរបស់ខ្លួន ដែលមានឧប្បត្តិហេតុដោយចៃដន្យណាមួយចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក។

មាត្រា៦.- កិច្ចព្រមព្រៀងទ្វេភាគី និងថ្នាក់តំបន់ ឬកិច្ចព្រមព្រៀងពហុភាគី

១. រដ្ឋភាគីទាំងឡាយត្រូវបានលើកទឹកចិត្តឱ្យចុះកិច្ចព្រមព្រៀងទ្វេភាគិ និងថ្នាក់តំបន់ ឬកិច្ចព្រមព្រៀងពហុភាគីដទៃទៀត ឬឱ្យកែលម្អកិច្ចព្រមព្រៀងដែលមានស្រាប់ ដើម្បីធានាការថែរក្សាបេតិកភណ្ឌវប្បធម៌ក្រោមទឹក។ រាល់កិច្ចព្រមព្រៀងទាំងនេះត្រូវតែស្របជាច់ខាតទៅនឹងបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ និងមិនត្រូវធ្វើឱ្យចរិតលក្ខណៈសកលនៃអនុសញ្ញានេះត្រូវចុះខ្សោយឡើយ ។ ក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀងទាំងនេះ រដ្ឋទាំងឡាយអាចអនុម័តរាល់វិធាន និងរាល់បទបញ្ជាដែលពាក់ពន្ធ័ផ្ទាល់ សំដៅធានាកិច្ចការពារយ៉ាងប្រសើរបំផុតដល់បេតិកភណ្ឌវប្បធម៌ក្រោមទឹក បើប្រៀបធៀបទៅនឹងបណ្តាវិធានដែលបានអនុម័តក្នុងក្របខណ្ឌនៃអនុសញ្ញានេះ ។

២. ភាគីទាំងឡាយនៃកិច្ចព្រមព្រៀងទ្វេភាគី ឬថ្នាក់តំបន់ ឬកិច្ចព្រមព្រៀងពហុភាគីដទៃទៀត អាចអញ្ជើញរដ្ឋទាំងឡាយដែលមានចំណងទាក់ទងពិតប្រាកដ ជាពិសេសចំណងទាក់ទងផ្នែកវប្បធម៌ ប្រវត្តិសាស្ត្រ ឬបុរាណវិទ្យាជាមួយនឹងបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលពាក់ព័ន្ធ ឱ្យចូលរួមក្នុងកិច្ចព្រមព្រៀងទាំងនេះបាន ។

៣. អនុសញ្ញានេះមិនផ្លាស់ប្តូរសិទ្ធិ និងកាតព្វកិច្ចនៃបណ្តារដ្ឋភាគីចូលរួម ក្នុងន័យនៃកិច្ចការពារនាវាដែលលិចក្នុងទឹកស្របតាមកិច្ចព្រមព្រៀងទ្វេភាគី និងថ្នាក់តំបន់ ឬកិច្ចព្រមព្រៀងពហុភាគីដទៃទៀតដែលចុះរួចហើយ មុនការអនុម័តនៃអនុសញ្ញានេះ ជាពិសេសប្រសិនបើកិច្ចព្រមព្រៀងទាំងនេះស្របតាមកម្មវត្ថុ នៃអនុសញ្ញានេះ ។

មាត្រា៧.- បេតិកភណ្ឌវប្បធម៌ក្រោមទឹកក្នុងដែនទឹកផ្ទៃក្នុង ដែនទឹកប្រជុំកោះ និងដែនសមុទ្រ

១. ក្នុងការអនុវត្តអធិបតេយ្យភាពរបស់ខ្លួន បណ្តារដ្ឋភាគីមានសិទ្ធិផ្តាច់មុខក្នុងការដាក់បទបញ្ជា និងអនុញ្ញាតរាល់កិច្ចអន្តរាគមន៍នានាលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលស្ថិតក្នុងដែនទឹកផ្ទៃក្នុង ដែនទឹកប្រជុំកោះ និងដែនសមុទ្ររបស់ខ្លួន។

២. ដោយមិនប៉ះពាល់ដល់កិច្ចព្រមព្រៀងអន្តរជាតិ និងវិធានការដទៃទៀតនៃច្បាប់អន្តរជាតិ ដែលកំពុងអនុវត្តដើម្បីកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក រដ្ឋភាគីទាំងឡាយអាចចេញបទប្បញ្ញត្តិក្នុងការអនុវត្តវិធានចំពោះកិច្ចអន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលស្ថិតនៅក្នុងដែនទឹកផ្ទៃក្នុង ដែនទឹកប្រជុំកោះ និងដែនសមុទ្ររបស់ខ្លួន។

៣. ក្នុងដែនទឹកប្រជុំកោះ និងដែនសមុទ្ររបស់ខ្លួន ក្នុងការអនុវត្តអធិបតេយ្យភាពរបស់ខ្លួន និងស្របតាមការអនុវត្តទូទៅដែលត្រូវគោរពរវាងរដ្ឋ និងរដ្ឋ ក្នុងកិច្ចសហប្រតិបត្តិការដើម្បីអនុម័តយកវិធីដ៏ប្រសើរបំផុត សំដៅការពារបណ្តានាវា និង យន្តហោះរបស់រដ្ឋ ហើយក្នុងករណីនៃការរុករកឃើញនាវា និងយន្តហោះរបស់រដ្ឋដែលមានអត្តសញ្ញាណច្បាស់លាស់ រដ្ឋភាគីនានាត្រូវតែផ្តល់ព័ត៌មានដល់រដ្ឋម្ចាស់យានជាភាគីនៃអនុសញ្ញានេះ និងរដ្ឋដទៃទៀតដែលមាន

ទំនាក់ទំនងជិតស្និទ្ធនឹងគ្នា ជាពិសេសខាងផ្នែកវប្បធម៌ ប្រវត្តិសាស្ត្រ ឬ បុរាណវិទ្យា ។

មាត្រា៨.- បេតិកភណ្ឌវប្បធម៌ក្រោមទឹកក្នុងតំបន់តភ្ជាប់

ដោយមិនប៉ះពាល់ដល់មាត្រា ៩ និងមាត្រា ១០ ក៏ដូចជាក្នុងការអនុវត្តតាមមាត្រា ៣០៣ កថាខណ្ឌទី ២ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ រដ្ឋភាគីទាំងឡាយអាចដាក់បទប្បញ្ញត្តិ និងអនុញ្ញាតរាល់អន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលស្ថិតក្នុងតំបន់តភ្ជាប់របស់ខ្លួន។ ដើម្បីសម្រេចគោលបំណងនេះ បណ្តារដ្ឋភាគីត្រូវដាក់បទប្បញ្ញត្តិដើម្បីអនុវត្តវិធានទាំងនោះ។

មាត្រា៩.- សេចក្តីប្រកាស និងសេចក្តីជូនដំណឹងក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងលើខ្ពង់រាបបាតសមុទ្រ

១. វាជាកាតព្វកិច្ចរបស់រដ្ឋភាគីក្នុងកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹកស្ថិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងលើខ្ពង់រាបបាតសមុទ្រ ស្របតាមអនុសញ្ញានេះ។

ជាលទ្ធផល :

(ក) រដ្ឋភាគីមួយនៅពេលណាពលរដ្ឋរបស់ខ្លួនណាម្នាក់ ឬនាវាដែលមានសញ្ជាតិរបស់ខ្លួនរកឃើញ ឬចង់ធ្វើអន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលស្ថិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬលើខ្ពង់រាបបាតសមុទ្រ ត្រូវតែតម្រូវឱ្យពលរដ្ឋនោះ ឬប្រមុខនាវានោះ ប្រកាសដល់ខ្លួន នូវការរកឃើញ ឬកិច្ចអន្តរាគមន៍នោះ

(ខ) ក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬលើខ្ពង់រាបបាតសមុទ្ររបស់រដ្ឋភាគីមួយទៀត :

(ខ១) រដ្ឋភាគីទាំងឡាយត្រូវតែតម្រូវឱ្យពលរដ្ឋ ឬប្រមុខនាវារបស់ខ្លួន ប្រកាសនូវការរកឃើញ ឬកិច្ចអន្តរាគមន៍នេះដល់ខ្លួនផង និងដល់ភាគីផ្សេងទៀតផង

(ខ២) ឬក្នុងករណីចាំបាច់ណាមួយនោះ រដ្ឋភាគីត្រូវតែតម្រូវឱ្យពលរដ្ឋ ឬប្រមុខនាវាប្រកាសដល់ខ្លួននូវការរកឃើញ ឬកិច្ចអន្តរាគមន៍នេះ និងត្រូវធ្វើការផ្សព្វផ្សាយព័ត៌មាននេះបញ្ជូនឱ្យបានលឿន និងប្រកបដោយប្រសិទ្ធភាពជូនដល់រដ្ឋភាគីដទៃទៀត។

២. ដោយតម្កល់នូវលិខិតតូបករណ៍សម្រាប់ស៊ុំសច្ចាប័ន ស៊ុំការយល់ព្រម និងការទទួលយក ឬការស៊ុំចូលជាភាគី រដ្ឋភាគីមួយត្រូវបញ្ជាក់អំពីរបៀបដែលខ្លួននឹងបញ្ជូនសេចក្តីប្រកាសទាំងនេះ ដូចមានចែងក្នុងកថាខណ្ឌទី ១ (ខ) នៃមាត្រានេះ។

៣. រដ្ឋភាគីមួយជូនដំណឹងដល់អគ្គនាយកអំពីការរុករកឃើញ ឬកិច្ចអន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលខ្លួនបានទទួល ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ។

៤. អគ្គនាយកចែកចាយរាល់ព័ត៌មានដែលខ្លួនបានទទួលឱ្យដល់រដ្ឋភាគីទាំងអស់ ស្របតាមខ្លឹមសារកថាខណ្ឌទី ៣ នៃមាត្រានេះ ។

៥. គ្រប់រដ្ឋភាគីអាចជូនដំណឹងឱ្យរដ្ឋភាគីណាមួយ ក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬលើខ្ពង់រាបបាតសមុទ្រដែលមានបេតិកភណ្ឌវប្បធម៌ក្រោមទឹក ហើយដែលចង់បានការពិគ្រោះយោបល់ពីរដ្ឋនេះ អំពីរបៀបធានាកិច្ចការពារប្រកបដោយប្រសិទ្ធភាពចំពោះបេតិកភណ្ឌនេះ ។ សេចក្តីប្រកាសនេះត្រូវឈរលើមូលដ្ឋានទំនាក់ទំនងច្បាស់លាស់រវាងទំនាក់ទំនងផ្នែកវប្បធម៌ ប្រវត្តិសាស្ត្រ ឬបុរាណវិទ្យា ជាមួយនឹងបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលពាក់ព័ន្ធ។

មាត្រា១០.- ការការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹកក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងលើខ្ពង់រាបបាតសមុទ្រ

១. ការអនុញ្ញាតសម្រាប់កិច្ចអន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬលើខ្ពង់រាបបាតសមុទ្រ អាចប្រព្រឹត្តទៅបាន លុះត្រាតែស្របនឹងបទប្បញ្ញត្តិ នៃមាត្រានេះ។

២. រដ្ឋជាភាគីមួយ ដែលមានបេតិកភណ្ឌវប្បធម៌ក្រោមទឹកស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬលើខ្ពង់រាបបាតសមុទ្ររបស់ខ្លួន មានសិទ្ធិហាមឃាត់ ឬអនុញ្ញាតរាល់កិច្ចអន្តរាគមន៍លើបេតិកភណ្ឌនេះដើម្បីរារាំងរាល់ការធ្វើឱ្យប៉ះពាល់ដល់សិទ្ធិអធិបតេយ្យ ឬប៉ះពាល់ដល់យុត្តាធិការរបស់ខ្លួន ដូចដែលត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ រួមទាំងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ។

៣. នៅពេលដែលការរុករកបេតិកភណ្ឌវប្បធម៌ក្រោមទឹកត្រូវបានធ្វើឡើង ឬនៅពេលដែលកិច្ចអន្តរាគមន៍មួយត្រូវបានគ្រោងអនុវត្តលើបេតិកភណ្ឌវប្បធម៌ក្រោមទឹកក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬលើខ្ពង់រាបបាតសមុទ្ររបស់រដ្ឋភាគីណាមួយ រដ្ឋភាគីនេះត្រូវ :

(ក) ពិគ្រោះយោបល់ជាមួយរដ្ឋភាគីដទៃទៀត ដែលបានបង្ហាញពីផលប្រយោជន៍របស់ខ្លួន ស្របតាមមាត្រា ៩ កថាខណ្ឌទី៥ ពីរបៀបដ៏ប្រសើរបំផុតដើម្បីការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក

(ខ) សម្របសម្រួលពិគ្រោះយោបល់ ក្នុងឋានៈជារដ្ឋសម្របសម្រួល លើកលែងតែរដ្ឋនេះប្រកាសយ៉ាងជាក់លាក់ថា ខ្លួនមិនមានបំណងនឹងធ្វើយ៉ាងនេះ។ ក្នុងករណីនេះ រដ្ឋភាគីទាំងឡាយដែលបានបង្ហាញពីផលប្រយោជន៍ស្របតាមមាត្រា៩ កថាខណ្ឌទី៥ ត្រូវចាត់តាំងរដ្ឋណាមួយឱ្យបំពេញនាទីជាអ្នកសម្របសម្រួល។

៤. ដោយមិនធ្វើឱ្យប៉ះពាល់ដល់ភារកិច្ចរបស់រដ្ឋភាគីទាំងអស់ក្នុងកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក តាមរយៈការអនុម័តនូវរាល់វិធានការសមស្របតាមច្បាប់អន្តរជាតិ សំដៅរារាំងរាល់គ្រោះថ្នាក់ភ្លាមៗចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹកជាពិសេសអំពើគក់ប្លន់ រដ្ឋសម្របសម្រួលអាចចាត់វិធានការសមស្រប និង ឬផ្តល់ការអនុញ្ញាតចាំបាច់ទាំងអស់ ស្របតាមអនុសញ្ញានេះ ហើយក្នុងករណីចាំបាច់អាចចាត់ការមុនរាល់ការពិគ្រោះយោបល់ដើម្បីរារាំងរាល់គ្រោះថ្នាក់ភ្លាមៗចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដោយហេតុផលនៃសកម្មភាពមនុស្ស ឬដោយ

ហេតុផលដទៃទៀត ជាពិសេសការរកប្អូន ។ ក្នុងពេលអនុម័តវិធានការទាំងនេះ រដ្ឋភាគីអាចស្នើសុំជំនួយពីរដ្ឋភាគីដទៃទៀតបាន ។

៥. រដ្ឋសម្របសម្រួល :

(ក) ត្រូវធ្វើឱ្យសម្រេចនូវវិធានការការពារដែលបានព្រមព្រៀងរវាងរដ្ឋទាំងឡាយ ដែលបានចូលរួមក្នុងការពិគ្រោះយោបល់គ្នា រួមទាំងរដ្ឋសម្របសម្រួល លើកលែងតែរដ្ឋទាំងនោះរួមទាំងរដ្ឋសម្របសម្រួលយល់ព្រមឱ្យរដ្ឋភាគីមួយផ្សេងទៀត ជាអ្នកអនុវត្តវិធានការនេះ។

(ខ) ត្រូវផ្តល់ការអនុញ្ញាតទាំងអស់ដែលចាំបាច់ចំពោះវិធានការទាំងឡាយ ដែលបានព្រមព្រៀងស្របតាមបណ្តាវិធានទាំងនោះ លើកលែងតែបណ្តារដ្ឋដែលចូលរួមក្នុងការពិគ្រោះយោបល់ រួមទាំងរដ្ឋសម្របសម្រួលសម្រេចប្រគល់ឱ្យរដ្ឋភាគីមួយផ្សេងទៀតជាអ្នកផ្តល់ការអនុញ្ញាតនេះ។

(គ) អាចដឹកនាំរាល់ការស្រាវជ្រាវបឋមជាចាំបាច់ចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក និងផ្តល់រាល់ការអនុញ្ញាតចាំបាច់ ព្រមទាំងបញ្ជូនយ៉ាងប្រញាប់នូវលទ្ធផលនៃការស្រាវជ្រាវនេះ ដល់អគ្គនាយក ហើយអគ្គនាយកត្រូវបញ្ជូនភ្លាមនូវព័ត៌មានទាំងនេះដល់រដ្ឋភាគីទាំងឡាយដទៃទៀត។

៦. ដោយធ្វើការសម្របសម្រួលនូវរាល់មតិយោបល់ ដោយធ្វើការអនុម័តនូវរាល់វិធានការ និងដោយធ្វើការដឹកនាំការស្រាវជ្រាវបឋម និង ឬដោយផ្តល់នូវការអនុញ្ញាតចាំបាច់ទាំងអស់ ស្របតាមមាត្រានេះ រដ្ឋសម្របសម្រួលត្រូវប្រព្រឹត្តក្នុងនាមរដ្ឋភាគីទាំងមូល មិនមែនសម្រាប់ផលប្រយោជន៍របស់ខ្លួនទោះឡើយ។ ទង្វើបែបនេះមិនអាចត្រូវបានលើកឡើងដើម្បីទាមទារសិទ្ធិបុរិមា[១] ឬសិទ្ធិយុត្តាធិការណាមួយដែលមិនទទួលស្គាល់ដោយច្បាប់អន្តរជាតិ ជាពិសេសដោយអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រឡើយ។

៧. ក្រោមបទប្បញ្ញត្តិនៃវាក្យខណ្ឌទី ២និងទី ៤ នៃមាត្រានេះ មិនអនុញ្ញាតឱ្យមានកិច្ចអន្តរាគមន៍ណាមួយ ធ្វើឡើងលើនាវា ឬយន្តហោះរបស់រដ្ឋ ដោយគ្មានការយល់ព្រមពីរដ្ឋសាមី និងដោយគ្មានកិច្ចសហប្រតិបត្តិការពីរដ្ឋសម្របសម្រួលឡើយ។

មាត្រា១១.- ការធ្វើសេចក្តីរាយការណ៍ និងការជូនដំណឹងនៅក្នុងតំបន់

១. ជាបន្ទុករបស់រដ្ឋភាគីទាំងអស់ ត្រូវការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលស្ថិតក្នុងតំបន់ ស្របតាមអនុសញ្ញានេះ និងស្របតាមមាត្រា ១៤៩ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ។ ដោយហេតុនេះនៅពេលដែលពលរដ្ឋនៃរដ្ឋភាគីមួយ ឬនាវាដែលកាន់ទង់ជ័យរបស់រដ្ឋនោះរកឃើញ ឬមានបំណងចង់ធ្វើអន្តរាគមន៍

(១) Droit préferentiel

លើតំបន់ដែលមានបេតិកភណ្ឌវប្បធម៌ក្រោមទឹក រដ្ឋភាគីនោះចាំបាច់ត្រូវតែឱ្យពលរដ្ឋរបស់ខ្លួន ឬប្រមុខនាវា ប្រកាសប្រាប់នូវការរុករកនោះ ឬកិច្ចអន្តរាគមន៍នោះ ។

២. បណ្តារដ្ឋភាគីត្រូវជូនដំណឹងចំពោះអគ្គនាយក និងចំពោះអគ្គលេខាធិការ នៃអាជ្ញាធរអន្តរជាតិទទួលបន្ទុកជាលសមុទ្រជ្រៅៗ អំពីការរុករក ឬកិច្ចអន្តរាគមន៍ទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលគេបានប្រកាសប្រាប់ ។

៣. អគ្គនាយកត្រូវផ្តល់ព័ត៌មានដល់គ្រប់រដ្ឋភាគីដោយគ្មានកាលកំណត់ នូវរាល់ព័ត៌មានដែលខ្លួនបានជូនដំណឹង ។

៤. រដ្ឋភាគីមួយអាចជូនដំណឹងចំពោះអគ្គនាយកដែលត្រូវពិគ្រោះអំពីវិធីការពារប្រកបដោយប្រសិទ្ធភាពចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក ។ សេចក្តីប្រកាសនោះត្រូវធ្វើឡើងលើមូលដ្ឋាននៃទំនាក់ទំនងពិតប្រាកដមួយជាមួយបេតិកភណ្ឌវប្បធម៌ក្រោមទឹកនេះ ដោយគិតគូរជាពិសេសដល់សិទ្ធិអាទិភាពទាំងឡាយនៃបណ្តារដ្ឋដែលមានប្រភពដើមខាងវប្បធម៌ ប្រវត្តិសាស្ត្រ ឬបុរាណវិទ្យា ។

មាត្រា១២.- កិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹកក្នុងតំបន់

១. លិខិតអនុញ្ញាតអាចត្រូវផ្តល់ឱ្យសម្រាប់កិច្ចអន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ស្ថិតនៅក្នុងតំបន់លុះត្រាណាតែខ្លឹមសារនៃលិខិតអនុញ្ញាតនោះស្របតាមបទប្បញ្ញត្តិនៃមាត្រានេះប៉ុណ្ណោះ ។

២. អគ្គនាយកត្រូវអញ្ជើញរដ្ឋភាគីទាំងអស់ដែលបានបង្ហាញពីផលប្រយោជន៍របស់គេ ដូចមានចែងក្នុងមាត្រា ១១ វាក្យខណ្ឌទី ៤ ឱ្យធ្វើការពិគ្រោះយ៉ាងយកចិត្តទុកដាក់អំពីការរក្សាការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ហើយត្រូវជ្រើសតាំងរដ្ឋភាគីមួយ ដែលនឹងទទួលបន្ទុកធ្វើការសម្របសម្រួលពិគ្រោះយោបល់ក្នុងនាមជារដ្ឋសម្របសម្រួល ។ អគ្គនាយកក៏ត្រូវអញ្ជើញអាជ្ញាធរអន្តរជាតិទទួលបន្ទុកជាលសមុទ្រជ្រៅ ១ ឱ្យចូលរួមក្នុងការពិគ្រោះយោបល់នោះផងដែរ ។

៣. គ្រប់រដ្ឋភាគីអាចចាត់វាលវិធានការទាន់ពេល ស្របតាមអនុសញ្ញានេះ ប្រសិនបើចាំបាច់ត្រូវពិគ្រោះយោបល់ជាមុនដើម្បីទប់ស្កាត់រាល់គ្រោះថ្នាក់ជាបន្ទាន់ចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលបណ្តាលមកពីសកម្មភាពរបស់មនុស្សឬសកម្មភាពផ្សេងៗទៀត ដូចជាការលួចប្លន់ជាដើម ។

៤. រដ្ឋសម្របសម្រួល :

(ក) ត្រូវធ្វើឱ្យសម្រេចនូវវាលវិធានការការពារដែលបានយល់ព្រមដោយបណ្តារដ្ឋចូលរួមក្នុងកិច្ចពិគ្រោះយោបល់ រួមទាំងរដ្ឋសម្របសម្រួល លើកលែងតែបណ្តារដ្ឋពិគ្រោះយោបល់រួមទាំងរដ្ឋសម្របសម្រួលយល់ស្របឱ្យរដ្ឋភាគីមួយផ្សេងទៀតចាត់វិធានការទាំងនេះ ។

(ខ) ត្រូវចេញលិខិតអនុញ្ញាតចាំបាច់ទាំងអស់ចំពោះវាលវិធានការដែលបានយល់ព្រមរួចហើយ ស្រប

តាមអនុសញ្ញានេះ លើកលែងតែបណ្តារដ្ឋពិគ្រោះយោបល់ រួមទាំងរដ្ឋសម្របសម្រួលយល់ស្របឱ្យរដ្ឋភាគីមួយ ផ្សេងទៀតចេញលិខិតអនុញ្ញាតទាំងនេះ ។

៥. រដ្ឋសម្របសម្រួលអាចដឹកនាំរាល់ការសិក្សាស្រាវជ្រាវបឋមដែលចាំបាច់ត្រូវធ្វើ ទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក និងចេញរាល់លិខិតអនុញ្ញាតចាំបាច់សម្រាប់កិច្ចការនេះ ហើយរដ្ឋនេះត្រូវបញ្ជូនជាបន្ទាន់នូវលទ្ធផលទាំងឡាយដល់អគ្គនាយកដែលជាអ្នកមានភារកិច្ចផ្ទេរព័ត៌មានទាំងនេះឱ្យដល់បណ្តារដ្ឋភាគីដទៃទៀត ។

៦. ដោយសម្របសម្រួលរាល់កិច្ចពិគ្រោះយោបល់ ដោយចាត់វិធានការដឹកនាំ ចាត់ចែងការស្រាវជ្រាវទាំងឡាយដែលចាំបាច់ជាបឋម និង ឬដោយចេញលិខិតអនុញ្ញាតទាំងឡាយតាមមាត្រានេះ រដ្ឋសម្របសម្រួលធ្វើកិច្ចការនេះដើម្បីជាផលប្រយោជន៍របស់មនុស្សជាតិទាំងមូលក្នុងនាមរដ្ឋភាគីទាំងអស់ ។ គេត្រូវយកចិត្តទុកដាក់ជាពិសេសដល់សិទ្ធិបុរិមារបស់រដ្ឋទាំងឡាយដែលមានប្រភពដើមផ្នែកវប្បធម៌ ប្រវត្តិសាស្ត្រ ឬបុរាណវត្ថុវិទ្យាប្រហាក់ប្រហែលនឹងបេតិកភណ្ឌដែលពាក់ព័ន្ធ។

៧. គ្មានរដ្ឋណាមួយអាចធ្វើអន្តរាគមន៍ ឬអនុញ្ញាតឱ្យធ្វើអន្តរាគមន៍លើនាវា ឬយន្តហោះរបស់រដ្ឋដែលស្ថិតក្នុងតំបន់ ដោយគ្មានការយល់ព្រមពីរដ្ឋម្ចាស់នាវា ឬម្ចាស់យន្តហោះនោះបានឡើយ ។

មាត្រា១៣.- អភ័យឯកសិទ្ធិអធិបតេយ្យ

នាវាចម្បាំង និងនាវារដ្ឋាភិបាល ឬយន្តហោះយោធាដែលទទួលបាននូវអភ័យឯកសិទ្ធិអធិបតេយ្យកំពុងធ្វើប្រតិបត្តិការក្នុងគោលដៅមិនមែនពាណិជ្ជកម្មក្នុងសកម្មភាពធម្មតានៃប្រតិបត្តិការរបស់ខ្លួន ហើយដែលមិនចូលរួមធ្វើអន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក គ្មានកាតព្វកិច្ចត្រូវធ្វើសេចក្តីប្រកាសអំពីការរកឃើញបេតិកភណ្ឌវប្បធម៌ក្រោមទឹក តាមមាត្រា ៩ មាត្រា ១០ មាត្រា ១១ និងមាត្រា ១២ នៃអនុសញ្ញានេះទេ ។ ក៏ប៉ុន្តែ ដោយចាត់វិធានការសមស្រប ដែលមិនធ្វើឱ្យប៉ះពាល់ដល់ប្រតិបត្តិការទាំងឡាយផង ដល់សមត្ថភាពប្រតិបត្តិនៃនាវាចម្បាំង និងនាវារដ្ឋាភិបាល ឬយន្តហោះយោធារបស់ពួកគេ ដែលទទួលបានអភ័យឯកសិទ្ធិអធិបតេយ្យ កំពុងប្រតិបត្តិការក្នុងគោលដៅមិនមែនពាណិជ្ជកម្មផង រដ្ឋភាគីទាំងឡាយ ក្នុងវិធានការសមហេតុផល និងអាចធ្វើទៅបាន ត្រូវធានាថានាវាទាំងនេះបានគោរពតាមបទប្បញ្ញត្តិនានា នៃមាត្រា ៩ មាត្រា ១០ មាត្រា ១១ និងមាត្រា ១២ នៃអនុសញ្ញានេះ ។

មាត្រា១៤.- ការត្រួតពិនិត្យអំពីការហូរចូលក្នុងដែនដីរបស់ខ្លួន ការធ្វើពាណិជ្ជកម្ម និងការរក្សាទុក

រដ្ឋភាគីទាំងឡាយត្រូវចាត់វិធាននានា ដើម្បីរារាំងការហូរចូលក្នុងដែនដីរបស់ខ្លួន ការធ្វើពាណិជ្ជកម្ម និងការកាន់កាប់បេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលនាំចេញដោយខុសច្បាប់ និង ឬដែលត្រូវគេរើបអូស ពេលដែលការ

រីបអូសនោះរំលោភលើបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ។

មាត្រា១៥.- ការមិនប្រើប្រាស់នូវតំបន់នានា ដែលស្ថិតនៅក្រោមយុត្តាធិការរបស់រដ្ឋភាគីទាំងឡាយ

រដ្ឋភាគីទាំងឡាយត្រូវចាត់គ្រប់វិធានការ ដើម្បីហាមឃាត់ការប្រើប្រាស់ទឹកដីរបស់ខ្លួន រួមទាំងកំពង់ផែសមុទ្ររបស់ខ្លួនក៏ដូចជាកោះសិប្បនិម្មិត សំណង់នានា និងរចនាសម្ព័ន្ធដែលស្ថិតក្រោមយុត្តាធិការផ្តាច់មុខ ឬដែលស្ថិតនៅក្រោមការត្រួតត្រាផ្តាច់មុខរបស់ខ្លួន សម្រាប់ធ្វើជាមូលដ្ឋានអន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលមិនស្របតាមបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ។

មាត្រា១៦.- វិធានការទាក់ទិននឹងពលរដ្ឋ និងនាវា

រដ្ឋភាគីទាំងឡាយត្រូវចាត់គ្រប់វិធានការសមស្រប ដើម្បីធានាថាពលរដ្ឋរបស់ខ្លួន និងនាវាទាំងឡាយដែលដោតទង់ជាតិរបស់ខ្លួន មិនចូលរួមក្នុងកិច្ចអន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលមិនស្របទៅនឹងអនុសញ្ញានេះ។

មាត្រា១៧.- ទណ្ឌកម្ម

១. រដ្ឋភាគីនីមួយៗត្រូវដាក់ទណ្ឌកម្មចំពោះគ្រប់បទល្មើសផ្ទុយនឹងវិធានការដែលខ្លួនបានដាក់ចេញ ដើម្បីជំរុញឱ្យអនុសញ្ញានេះអនុវត្តបានសម្រេច ។

២. ទណ្ឌកម្មដែលយកមកអនុវត្តចំពោះបទល្មើសនានាត្រូវតែមានលក្ខណៈធ្ងន់ធ្ងរដើម្បីធានាការគោរពអនុសញ្ញានេះ និងដើម្បីបន្ថយការប្រព្រឹត្តបទល្មើស ទោះជានៅទីណាក៏ដោយ។ ការដាក់ទណ្ឌកម្ម គឺសំដៅទប់ស្កាត់រាល់ការទាញយកប្រយោជន៍របស់ជនល្មើសពីសកម្មភាពខុសច្បាប់របស់ខ្លួន។

៣. រដ្ឋភាគីទាំងឡាយត្រូវសហការគ្នាដើម្បីធានារាល់ការអនុវត្តទណ្ឌកម្មទាំងនេះ ដោយផ្អែកលើមាត្រានេះ។

មាត្រា១៨.- ការរឹបអូស និងការប្រើប្រាស់ផ្នែកនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក

១. រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់ ដើម្បីធ្វើការរឹបអូសនៅលើទឹកដីរបស់ខ្លួន នូវផ្នែកនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលបានស្រង់យកដោយមិនស្របទៅនឹងបទប្បញ្ញត្តិនៃអនុសញ្ញានេះ។

២. រាល់រដ្ឋភាគីដែលបានធ្វើការរើបម្រួសផ្នែកនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដោយអនុវត្តតាមអនុសញ្ញានេះ ត្រូវធ្វើការចុះបញ្ជី និងថែរក្សាផ្នែកនានាទាំងនោះ ហើយត្រូវចាត់រាល់វិធានការសមហេតុផល ដើម្បីធានាភាពគង់វង្សស្ថិតស្ថេរនៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកទាំងនោះ។

៣. រាល់រដ្ឋភាគីដែលបានធ្វើការរើបម្រួសផ្នែកនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដោយអនុវត្តតាមអនុសញ្ញានេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អគ្គនាយក និងដល់រដ្ឋដទៃទៀតដែលមានទំនាក់ទំនងពិតប្រាកដ ជាពិសេសទំនាក់ទំនងខាងវប្បធម៌ ប្រវត្តិសាស្ត្រ ឬបុរាណវិទ្យាជាមួយបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលមានការពាក់ព័ន្ធ ។

៤. រដ្ឋភាគីដែលបានធ្វើការរើបម្រួសផ្នែកនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ត្រូវធានាឱ្យមានការប្រើប្រាស់បានជាប្រយោជន៍ទូទៅ ដោយធ្វើការថ្លឹងថ្លែងអំពីភាពចាំបាច់នៃការថែរក្សា និងការសិក្សាស្រាវជ្រាវអំពីសារសំខាន់នៃការផ្គុំឡើងវិញនូវផ្នែកនានាដែលបែកខ្ចែក អំពីសេចក្តីត្រូវការក្នុងការស្វែងយល់របស់មហាជន អំពីការតាំងពិព័រណ៍ និងការអប់រំ ព្រមទាំងសារប្រយោជន៍របស់រដ្ឋទាំងអស់ដែលមានទំនាក់ទំនងពិតប្រាកដ ជាពិសេសទំនាក់ទំនងផ្នែកវប្បធម៌ ប្រវត្តិសាស្ត្រ ឬបុរាណវត្ថុវិទ្យាជាមួយបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលមានការពាក់ព័ន្ធ។

មាត្រា១៩.- កិច្ចសហការ និងការចែករំលែកព័ត៌មាន

១. រដ្ឋភាគីទាំងឡាយត្រូវសហការគ្នា និងត្រៀមខ្លួនក្នុងការជួយគ្នាទៅវិញទៅមក ដើម្បីធានាកិច្ចការពារ និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ក្រោមទឹកក្នុងក្របខ័ណ្ឌនៃអនុសញ្ញានេះ ជាអាទិ៍ទៅពេលដែលអាចធ្វើទៅបាន តាមរយៈការសហការគ្នាក្នុងការរុករក ក្នុងការធ្វើកំណាយ ការរៀបចំឯកសារ ការថែរក្សា និងការលើកតម្លៃចំពោះបេតិកភណ្ឌប្រភេទនេះ ។

២. ល្គឹកណាដែលកម្មវត្ថុនៃអនុសញ្ញានេះអាចអនុញ្ញាតឱ្យបាន រដ្ឋភាគីនីមួយៗត្រូវត្រៀមរំលែកជាមួយបណ្តារដ្ឋភាគីដទៃទៀត នូវរាល់ព័ត៌មានដែលពាក់ព័ន្ធនឹងបេតិកភណ្ឌវប្បធម៌ក្រោមទឹក ។ ជាពិសេសរាល់ព័ត៌មាន ដែលពាក់ព័ន្ធនឹងការរកឃើញផ្នែកនានានៃបេតិកភណ្ឌនេះ ជាអាទិ៍ មានទីតាំងរបស់វា មានផ្នែកនានាដែលត្រូវជីកកកាយបាន ឬរើបម្រួសបាន វត្ថុល្មើសដែលផ្ទុយនឹងអនុសញ្ញានេះ ឬដែលរំលោភលើបទប្បញ្ញត្តិផ្សេងៗនៃច្បាប់អន្តរជាតិ វិធីសាស្ត្រ និងបច្ចេកទេសវិទ្យាសាស្ត្រដែលសមស្របនិងការវិវត្តរបស់ច្បាប់ ដែលអាចយកមកអនុវត្តបានចំពោះបេតិកភណ្ឌប្រភេទនេះ ។

៣. រាល់ព័ត៌មានដែលទាក់ទងទៅនឹងការរុករកឃើញ ឬទាក់ទងទៅនឹងទីតាំងនៃផ្នែកនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលត្រូវចែករំលែករវាងរដ្ឋភាគីទាំងឡាយ ឬរវាងអង្គការយូណេស្កូ និងបណ្តារដ្ឋភាគី ត្រូវស្ថិតនៅជាសម្ងាត់ ហើយអាចផ្តល់បានចំពោះតែអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តារដ្ឋភាគី លុះណាតែព័ត៌មាននោះសមស្របទៅនឹងច្បាប់ជាតិរបស់ខ្លួន ហើយល្គឹកណាដែលការផ្សព្វផ្សាយព័ត៌មាននេះអាចមានគ្រោះថ្នាក់ ឬហានិភ័យសម្រាប់

ការថែរក្សានូវផ្នែកនានាដែលពាក់ព័ន្ធនឹងបេតិកភណ្ឌនេះ ។

៤. រដ្ឋភាគីនីមួយៗត្រូវចាត់ត្រូវវិធានការសមរម្យដែលអាចធ្វើទៅបាន រួមទាំងការប្រើនូវមូលដ្ឋានទិន្នន័យអន្តរជាតិសមស្រប ដើម្បីផ្សព្វផ្សាយព័ត៌មានដែលខ្លួនមានស្តីពីផ្នែកនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលត្រូវជីកកកាយបាន ឬរើបអូសបានដោយរំលោភលើអនុសញ្ញានេះ ឬដោយផ្ទុយនឹងច្បាប់អន្តរជាតិ ។

មាត្រា២០.- ការចាប់អារម្មណ៍របស់មហាជន

រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការសមស្រប ដើម្បីធ្វើឱ្យសាធារណជន មានចំណាប់អារម្មណ៍យល់ដឹងពីតម្លៃ និងផលប្រយោជន៍របស់បេតិកភណ្ឌវប្បធម៌ក្រោមទឹក និងអំពីសារសំខាន់នៃកិច្ចការពារ ដែលត្រូវបានចែងដោយអនុសញ្ញានេះ ។

មាត្រា២១.- ការបណ្តុះបណ្តាលផ្នែកបុរាណវត្ថុវិទ្យាក្រោមទឹក

រដ្ឋភាគីទាំងឡាយត្រូវសហការគ្នា ដើម្បីរៀបចំការបណ្តុះបណ្តាលផ្នែកបុរាណវត្ថុវិទ្យាក្រោមទឹក ព្រមទាំងផ្នែកបច្ចេកទេសក្នុងការថែរក្សាបេតិកភណ្ឌវប្បធម៌ក្រោមទឹក និងដើម្បីធ្វើការផ្ទេរបច្ចេកវិទ្យាពាក់ព័ន្ធទៅនឹងបេតិកភណ្ឌនេះ ទៅតាមលក្ខខណ្ឌសមស្រប ។

មាត្រា២២.- អាជ្ញាធរមានសមត្ថកិច្ច

១. ដើម្បីធានាឱ្យមានការអនុវត្តបានត្រឹមត្រូវនូវអនុសញ្ញានេះ បណ្តារដ្ឋភាគីត្រូវបង្កើតក្រុម ឬអាជ្ញាធរមានសមត្ថកិច្ច ឬពង្រឹងអាជ្ញាធរដែលមានស្រាប់ ដើម្បីធ្វើការបង្កើត ការរក្សាទុក និងការធ្វើបច្ចុប្បន្នភាព នៃបញ្ជីសារពើភណ្ឌបេតិកភណ្ឌវប្បធម៌ក្រោមទឹក និងដើម្បីធានាប្រកបដោយប្រសិទ្ធភាពនូវកិច្ចការពារ ការថែរក្សា ការលើកតម្លៃ និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ក្រោមទឹក ព្រមទាំងការស្រាវជ្រាវ និងការអប់រំ ។

២. រដ្ឋភាគីទាំងឡាយត្រូវផ្តល់ព័ត៌មានដល់អគ្គនាយក នូវឈ្មោះ និងអាសយដ្ឋាន នៃអាជ្ញាធរមានសមត្ថកិច្ចខាងផ្នែកបេតិកភណ្ឌវប្បធម៌ក្រោមទឹក ។

មាត្រា២៣.- សន្និសីទនានានៃបណ្តារដ្ឋភាគី

១. អគ្គនាយកជាអ្នកកោះប្រជុំនៃបណ្តារដ្ឋភាគី ក្នុងឆ្នាំក្រោយពីការចូលជាធរមាននៃអនុសញ្ញានេះ បន្ទាប់មក ត្រូវកោះប្រជុំយ៉ាងតិចរៀងរាល់ពីរឆ្នាំម្តង។ អគ្គនាយកត្រូវកោះប្រជុំសន្និសីទវិសាមញ្ញមួយនៃបណ្តារដ្ឋភាគី ប្រសិនបើមានការស្នើសុំពីបណ្តារដ្ឋភាគីភាគច្រើន។

២. សន្និសីទនៃបណ្តារដ្ឋភាគីកំណត់អំពីមុខងារ និងការទទួលខុសត្រូវរបស់ខ្លួន ។

៣. សន្និសីទនៃបណ្តារដ្ឋភាគីអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

៤. សន្និសីទនៃបណ្តារដ្ឋភាគី អាចបង្កើតក្រុមប្រឹក្សាពិគ្រោះយោបល់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេសមួយរួមមានសមាសភាពជាអ្នកជំនាញ ដែលបេក្ខភាពរបស់ពួកគេត្រូវបានស្នើឡើងដោយបណ្តារដ្ឋភាគី ដែលត្រូវមានការថ្លឹងថ្លែងអំពីគោលការណ៍បែងចែកដោយសមធម៌ស្របតាមភូមិសាស្ត្រនិងស្របតាមកម្មវត្ថុនៃគោលការណ៍តុល្យភាពរវាងភេទនិងភេទ ។

៥. ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាពិគ្រោះយោបល់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេសត្រូវជួយរៀបចំសន្និសីទនៃបណ្តារដ្ឋភាគីខាងផ្នែកវិទ្យាសាស្ត្រ ឬបច្ចេកទេស ដែលទាក់ទិនទៅនឹងការអនុវត្តវិធាននានា ។

មាត្រា២៤.- លេខាធិការដ្ឋាននៃអនុសញ្ញានេះ

១. អគ្គនាយកជាអ្នកទទួលខុសត្រូវចំពោះលេខាធិការដ្ឋាននៃអនុសញ្ញានេះ។

២. មុខងាររបស់លេខាធិការដ្ឋាននេះរួមមានជាអាទិ៍ :

(ក) ការរៀបចំសន្និសីទនៃបណ្តារដ្ឋភាគី ដូចដែលមានចែងក្នុងមាត្រា២៣ កថាខណ្ឌ ទី១

(ខ) ផ្តល់ការឧបត្ថម្ភជាចាំបាច់ដល់បណ្តារដ្ឋភាគី ដើម្បីអនុវត្តបានទូវរាល់សេចក្តីសម្រេចនានារបស់សន្និសីទនៃបណ្តារដ្ឋភាគី។

មាត្រា២៥.- ការដោះស្រាយជម្លោះដោយសន្តិវិធី

១. រាល់ជម្លោះរវាងរដ្ឋភាគីពីរ ឬច្រើនស្តីពីការបកស្រាយ ឬការអនុវត្តនូវអនុសញ្ញានេះ គឺជាកម្មវត្ថុ នៃកិច្ចចរចា ប្រកបដោយសុទ្ធចិត្ត ឬដោយមធ្យោបាយនៃដំណោះស្រាយសន្តិវិធីតាមជម្រើសរបស់ខ្លួន។

២. ប្រសិនបើការចរចាទាំងនេះមិនអនុញ្ញាតឱ្យមានការដោះស្រាយជម្លោះក្នុងរយៈពេលមួយសមស្រប ជម្លោះនេះអាចដាក់ជូនអង្គការយូណេស្កូជាអ្នកសម្របសម្រួល ដោយការព្រមព្រៀងរួមគ្នារវាងរដ្ឋភាគីនានាដែលពាក់ព័ន្ធ។

៣. ប្រសិនបើគ្មានការសម្របសម្រួលណាមួយអាចកើតឡើងទេ ឬប្រសិនបើការសម្របសម្រួលនោះមិនឈានដល់ដំណោះស្រាយមួយទេ រាល់បទប្បញ្ញត្តិដែលទាក់ទិនទៅនឹងដំណោះស្រាយជម្លោះ ដូចមានចែងក្នុងផ្នែកទី១៥ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី នីតិសមុទ្រ នឹងត្រូវបានយកមកអនុវត្តចំពោះគ្រប់ជម្លោះរវាងបណ្តារដ្ឋភាគីនៃអនុសញ្ញានេះ តាមរយៈការបកស្រាយ ឬការអនុវត្តនៃអនុសញ្ញានេះ ទោះបីរដ្ឋនោះជាភាគី ឬមិនមែនជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រក៏ដោយ ។

៤. គ្រប់នីតិវិធីជ្រើសរើសដោយរដ្ឋភាគីមួយនៃអនុសញ្ញានេះ និងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រដូចមានចែងក្នុងមាត្រា២៨៧ ត្រូវបានយកមកអនុវត្តចំពោះដំណោះស្រាយនៃជម្លោះតាមមាត្រានេះ លើកលែងតែរដ្ឋភាគីនេះ ពេលផ្តល់សច្ចាប័ន ទទួលយក ឬយល់ព្រមចូលជាសមាជិកនៃអនុសញ្ញានេះ ឬនៅពេលណាមួយបន្ទាប់មក បានជ្រើសរើសយកនីតិវិធីមួយផ្សេងទៀតតាមមាត្រា២៨៧ សម្រាប់ដោះស្រាយជម្លោះដែលកើតចេញពីអនុសញ្ញានេះ។

៥. នៅពេលដែលខ្លួនផ្តល់សច្ចាប័ន ទទួលយក ឬយល់ព្រម ឬចូលជាសមាជិកនៃអនុសញ្ញានេះ ឬនៅពេលណាមួយបន្ទាប់មក រដ្ឋភាគីនៃអនុសញ្ញានេះដែលមិនមែនជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រមានសេរីភាពក្នុងការជ្រើសរើស តាមការប្រកាសជាលាយលក្ខណ៍អក្សរនូវមធ្យោបាយមួយ ឬច្រើនដូចមានចែងក្នុង មាត្រា២៨៧ កថាខណ្ឌទី១ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រសម្រាប់ដោះស្រាយជម្លោះតាមមាត្រានេះ ។ មាត្រា២៨៧ អនុវត្តចំពោះសេចក្តីប្រកាសនេះ ក៏ដូចជាចំពោះគ្រប់ជម្លោះ ដែលរដ្ឋនេះជាភាគី ហើយដែលមិនបានចែងកំណត់ដោយសេចក្តីប្រកាសមួយជាធរមាន។ ក្នុងគោលបំណងធ្វើការផ្សះផ្សា និងធ្វើជាអាជ្ញាកណ្តាលស្របតាមឧបសម្ព័ន្ធទី៥ និងទី ៧ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ រដ្ឋនេះមានសម្បទាគ្រប់គ្រាន់ក្នុងការចាត់តាំងអ្នកសម្របសម្រួល និងអ្នកអាជ្ញាកណ្តាល ដែលនឹងត្រូវចុះឈ្មោះក្នុងបញ្ជីរៀបរាប់ នៅឧបសម្ព័ន្ធទី ៥ មាត្រា ២ និងនៅឧបសម្ព័ន្ធទី ៧ មាត្រា២ សម្រាប់ដោះស្រាយជម្លោះនានា ដែលកើតចេញពីអនុសញ្ញានេះ។

មាត្រា៦៦.- ការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលជាសមាជិក

១. អនុសញ្ញានេះ អាចដាក់ឱ្យរដ្ឋជាសមាជិករបស់អង្គការយូណេស្កូ ផ្តល់សច្ចាប័ន ទទួលយក ឬយល់ព្រម។

២. អនុសញ្ញានេះដាក់ឱ្យចូលជាសមាជិកពីសំណាក់ :

(ក) រដ្ឋមិនមែនជាសមាជិកអង្គការយូណេស្កូ តែជាសមាជិករបស់អង្គការសហប្រជាជាតិ ឬសមាជិករបស់ស្ថាប័នជំនាញពិសេសមួយស្ថិតក្នុងប្រព័ន្ធនៃអង្គការសហប្រជាជាតិ ឬរបស់ភ្នាក់ងារអន្តរជាតិផ្នែកថាមពលបរមាណូ ព្រមទាំងបណ្តារដ្ឋភាគីនៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ និងគ្រប់រដ្ឋផ្សេងទៀតដែលបានអញ្ជើញឱ្យចូលជាសមាជិកដោយសន្និសីទកំពូលរបស់អង្គការយូណេស្កូ។

(ខ) បណ្តាដែនដីដែលទទួលបាននូវស្វ័យភាពផ្ទៃក្នុងពេញលេញបានទទួលស្គាល់ដោយអង្គការសហប្រជាជាតិ ប៉ុន្តែមិនទាន់បានទទួលឯករាជភាពពេញលេញ ស្របតាមសេចក្តីសម្រេចលេខ ១៥១៤ (១៥) របស់មហាសន្និបាត ហើយដែលមានសមត្ថកិច្ចលើបញ្ហាទាំងឡាយដែលគ្រប់គ្រងដោយអនុសញ្ញានេះ រួមទាំងសមត្ថកិច្ចចុះសន្ធិសញ្ញាស្តីពីបញ្ហាទាំងនេះ។

៣. រាល់លិខិតូបករណ៍នៃការផ្តល់សច្ចាប័ន នៃការទទួលយក នៃការយល់ព្រម ឬនៃការចូលជាសមាជិក ត្រូវតម្កល់ទុកនៅនឹងអគ្គនាយក។

មាត្រា២៧.- ការចូលជាធរមាន

អនុសញ្ញានេះចូលជាធរមានបីខែក្រោយកាលបរិច្ឆេទនៃការតម្កល់លិខិតូបករណ៍ទី២០ ដូចដែលមានចែងនៅមាត្រា២៦ ប៉ុន្តែចំពោះតែរដ្ឋ ឬដែនដីចំនួន២០ដែលបានតម្កល់លិខិតូបករណ៍របស់ខ្លួនតែប៉ុណ្ណោះ។ អនុសញ្ញានេះចូលជាធរមានចំពោះរដ្ឋ ឬដែនដីទាំងអស់រយៈពេលបីខែក្រោយកាលបរិច្ឆេទនៃការតម្កល់ទុកលិខិតូបករណ៍របស់ខ្លួន។

មាត្រា២៨.- សេចក្តីប្រកាសទាក់ទងទៅនឹងសាគរទ្វីប

នៅពេលដែលខ្លួនផ្តល់សច្ចាប័ន ទទួលយក យល់ព្រម ឬចូលជាសមាជិកនៃអនុសញ្ញានេះ រាល់រដ្ឋភាគីទាំងអស់អាចប្រកាសបានគ្រប់ពេលថាវិធានទាំងឡាយដែលអនុវត្តចំពោះសាគរទ្វីបរបស់ខ្លួន គ្មានលក្ខណៈចរិតជាសមុទ្រឡើយ។

មាត្រា២៩.- វិសាលភាពអនុវត្តតាមភូមិសាស្ត្រ

នៅពេលដែលខ្លួនផ្តល់សច្ចាប័ន ទទួលយក យល់ព្រម ឬចូលជាសមាជិកនៃអនុសញ្ញានេះ រដ្ឋឬ ដែនដីមួយតាមរយៈសេចក្តីប្រកាសដែលបានតម្កល់ទុកទៅកន្លែងរក្សាឯកសារ អាចចែងថាអនុសញ្ញានេះមិនអាចអនុវត្តចំពោះផ្នែកណាមួយជាកំណត់ ស្ថិតក្នុងដែនដីរបស់ខ្លួន ស្ថិតក្នុងដែនទឹកផ្ទៃក្នុង ដែនទឹកប្រជុំកោះ ឬក្នុងដែនសមុទ្ររបស់ខ្លួន ហើយត្រូវបញ្ជាក់ពីមូលហេតុនៃសេចក្តីប្រកាសនៅក្នុងអនុសញ្ញានេះ។ ប្រសិនបើអាចធ្វើទៅបាន នឹងក្នុងរយៈពេលសមស្របបំផុត រដ្ឋព្យាយាមប្រមូលលក្ខខណ្ឌទាំងឡាយ ដែលក្នុងនោះអនុសញ្ញានេះ នឹងអនុវត្តចំពោះតំបន់ពិសេសៗ នានា ដែលមានចែងក្នុងសេចក្តីប្រកាសរបស់ខ្លួន។ នៅពេលដែលកិច្ចការនេះសម្រេចបាន ពេលនោះរដ្ឋនឹងដកសេចក្តីប្រកាសរបស់ខ្លួនចេញទាំងស្រុង ឬមួយផ្នែក។

មាត្រា៣០.- សិទ្ធិបម្រុងនានា

លើកលែងតែមាត្រា ២៩ ចេញ គ្មានសិទ្ធិបម្រុងណាមួយអាចធ្វើទៅបានឡើយចំពោះអនុសញ្ញានេះ ។

មាត្រា៣១.- វិសោធនកម្ម

១. រដ្ឋភាគីទាំងអស់ តាមរយៈលិខិតជាលាយលក្ខណ៍អក្សរផ្ញើជូនអគ្គនាយក អាចស្នើសុំធ្វើ វិសោធនកម្ម ចំពោះអនុសញ្ញានេះ ។ អគ្គនាយកមានភារកិច្ចបញ្ជូនលិខិតនេះទៅដល់បណ្តារដ្ឋភាគីទាំងអស់ ។ ក្នុងរយៈពេល៦ ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការបញ្ជូនលិខិតនេះ ប្រសិនបើរដ្ឋភាគីចំនួនពាក់កណ្តាលយ៉ាងតិចផ្តល់ចម្លើយជាវិជ្ជមាន ចំពោះការស្នើសុំនេះ នោះអគ្គនាយកអាចដាក់សេចក្តីស្នើសុំនេះសម្រាប់ពេលសន្និសីទបន្ទាប់នៃបណ្តារដ្ឋភាគីដើម្បី ធ្វើការពិភាក្សា និងធ្វើការអនុម័តជាយថាហេតុ ។

២. វិសោធនកម្មទាំងឡាយត្រូវអនុម័តតាមសំឡេងភាគច្រើនពីរភាគបី នៃបណ្តារដ្ឋភាគីវត្តមាននិងចូលរួម បោះឆ្នោត ។

៣. វិសោធនកម្មនៃអនុសញ្ញានេះ នៅពេលដែលបានទទួលការអនុម័តរួចហើយ ត្រូវដាក់ជូនបណ្តារដ្ឋភាគី ដើម្បីសុំការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការបញ្ចូលជាសមាជិក ។

៤. សម្រាប់រដ្ឋភាគីទាំងឡាយ ដែលបានផ្តល់សច្ចាប័ន បានទទួលយក បានយល់ព្រម ឬបានចូលជា សមាជិក រួចហើយ ការធ្វើវិសោធនកម្មចំពោះអនុសញ្ញានេះចូលជាធរមានរយៈពេលបីខែក្រោយបន្ទាប់ពីបានតម្កល់លិខិតូបករណ៍ ទាំងឡាយ ដូចមានចែងនៅកថាខណ្ឌទី៣ នៃមាត្រានេះ ដោយបណ្តារដ្ឋភាគីចំនួនពីរភាគបី (២/៣) ។ បន្ទាប់មក សម្រាប់រដ្ឋ ឬដែនដីនីមួយៗដែលផ្តល់សច្ចាប័ន ទទួលយក យល់ព្រមចំពោះវិសោធនកម្ម ឬចូលជាសមាជិក ហើយ វិសោធនកម្មនេះចូលជាធរមានរយៈពេលបីខែក្រោយបន្ទាប់ពីកាលបរិច្ឆេទ នៃការតម្កល់ទុកដោយភាគីនេះ នូវ លិខិតូបករណ៍ផ្តល់សច្ចាប័ន ទទួលយក យល់ព្រម ឬចូលជាសមាជិករបស់ខ្លួន ។

៥. រដ្ឋ ឬដែនដីមួយដែលក្លាយជាភាគីនៃអនុសញ្ញានេះ ក្រោយការចូលជាធរមាននៃវិសោធនកម្មមួយស្រប តាមកថាខណ្ឌទី៤ នៃមាត្រានេះ ដោយមិនបានបញ្ចេញឆន្ទៈផ្ទុយពីនេះត្រូវចាត់ថា :

(ក) ជាភាគីនៃអនុសញ្ញាដែលបានធ្វើវិសោធនកម្មរួចហើយ និង

(ខ) ជាភាគីនៃអនុសញ្ញាដែលមិនបានធ្វើវិសោធនកម្មចំពោះរដ្ឋភាគីទាំងអស់ ដែលមិនត្រូវបានចងភ្ជាប់ កាតព្វកិច្ចដោយវិសោធនកម្មនេះ ។

មាត្រា៣២.- ការប្តឹងបដិសេធនី

១. រដ្ឋភាគីមួយអាចធ្វើការប្តឹងបដិសេធនីអនុសញ្ញានេះបានតាមរយៈបណ្តឹងជាលាយលក្ខណ៍អក្សរផ្ញើជូនអគ្គនាយក ។

២. ការប្តឹងបដិសេធនឹងមានអានុភាពជាប់ពីរខែក្រោយមក បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង លើកលែងតែពាក្យបណ្តឹងនេះកំណត់កាលបរិច្ឆេទមួយក្រោយទៀត។

៣. ការប្តឹងបដិសេធនឹងមិនធ្វើឱ្យប៉ះពាល់អ្វីសោះឡើយដល់កាតព្វកិច្ចរបស់គ្រប់រដ្ឋភាគីក្នុងការបំពេញកាតព្វកិច្ចទាំងអស់ ដូចដែលមានចែងក្នុងអនុសញ្ញានេះ ហើយដែលរដ្ឋភាគីទាំងនេះត្រូវគោរពតាមច្បាប់អន្តរជាតិ ដែលមានលក្ខណៈឯករាជ្យពីអនុសញ្ញានេះ។

មាត្រា៣៣.- វិធាននានា

បណ្តាវិធានដែលបានចងភ្ជាប់ជាឧបសម្ព័ន្ធនៃអនុសញ្ញានេះគឺជាផ្នែករួមបញ្ចូលនៃអនុសញ្ញានេះ លើកលែងតែមានបទប្បញ្ញត្តិជាក់លាក់ផ្ទុយពីនេះ ការយោងណាមួយទៅនឹងអនុសញ្ញានេះក៏ជាការឆ្លើយតបទៅលើវិធានទាំងនោះដែរ ។

មាត្រា៣៤.- ការចុះបញ្ជីនៅអង្គការសហប្រជាជាតិ

ស្របតាមមាត្រា១០២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ អនុសញ្ញានេះនឹងត្រូវបានចុះបញ្ជីនៅលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិ យោងតាមពាក្យសុំរបស់អគ្គនាយក ។

មាត្រា៣៥.- អត្ថបទផ្លូវការ

អនុសញ្ញានេះត្រូវបានរៀបចំឡើងជាភាសាអង់គ្លេស អារ៉ាប់ ចិន អេស្ប៉ាញ៉ុល បារាំង និងរុស្ស៊ី អត្ថបទទាំងប្រាំមួយភាសានេះ មានតម្លៃជាផ្លូវការដូចគ្នា។

ឧបសម្ព័ន្ធ

វិធាននានាទាក់ទិនទៅនឹងអន្តរាគមន៍នានាលើបេតិកភណ្ឌវប្បធម៌ក្រោមទឹកៈ

១.- គោលការណ៍ទូទៅ

វិធាន១: ដើម្បីថែរក្សាបេតិកភណ្ឌវប្បធម៌ក្រោមទឹក ការអភិរក្សត្រូវចាត់ទុកដូចជាកិច្ចការអាទិភាព ។ ជាលទ្ធផល រាល់អន្តរាគមន៍ដែលធ្វើទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ត្រូវបានអនុញ្ញាត លុះណាតែធ្វើសមស្រប ជាមួយកិច្ចការពារបេតិកភណ្ឌនេះប៉ុណ្ណោះ ហើយអាចអនុញ្ញាតបានតែក្នុងលក្ខខណ្ឌដែលការធ្វើអន្តរាគមន៍ទាំងនេះ បានរួមវិភាគទានដ៏មានសារសំខាន់ដល់កិច្ចការពារ ដល់ការយល់ដឹង ឬដល់ការលើកតម្លៃបេតិកភណ្ឌនេះ ។

វិធាន២: ការធ្វើអាជីវកម្មខាងពាណិជ្ជកម្មលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ក្នុងគោលដៅជំនួញ ឬកេងកម្រៃ ឬការធ្វើឱ្យបែកខ្ញែកដែលមិនអាចជួសជុលបាន គឺមានលក្ខណៈវិសមិតភាពទាំងស្រុងទៅនឹងកិច្ចការពារ និងអភិបាលកិច្ចល្អនៃបេតិកភណ្ឌនេះ។ ផ្នែកនានា នៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកមិនអាចធ្វើជាកម្មវត្ថុនៃជំនួញ នៃប្រតិបត្តិការលក់-ទិញ ឬផ្លាស់ប្តូរផ្ទាល់ក្នុងលក្ខណៈជាទំនិញប្រភេទពាណិជ្ជកម្មឡើយ ។
វិធាននេះមិនអាចត្រូវបកស្រាយក្នុងគោលបំណងរារាំងដល់ :

(ក) ការផ្គត់ផ្គង់សេវាបុរាណវត្ថុវិទ្យាវិជ្ជាជីវៈ ឬសេវាពាក់ព័ន្ធចាំបាច់ ដែលប្រភេទ និងគោលបំណង គឺស្របទាំងស្រុងទៅនឹងអនុសញ្ញានេះ ក្នុងលក្ខខណ្ឌដែលមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ។

(ខ) ឃ្លាំងរក្សាវត្ថុនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលប្រមូលបានក្នុងក្របខណ្ឌនៃគម្រោងស្រាវជ្រាវ ដែលធ្វើឡើងស្របតាមអនុសញ្ញានេះ លុះត្រាណាដែលការរក្សាទុកនេះមិនប៉ះពាល់ដល់សារប្រយោជន៍ផ្នែកវិទ្យាសាស្ត្រ ឬវប្បធម៌ឬដល់ភាពដើមនៃផ្នែកនានាដែលប្រមូលបាន មិនបណ្តាលឱ្យមានការបែកបាក់ដែលមិនអាចជួសជុលបាន ទោះជាស្របទៅនឹងបទប្បញ្ញត្តិនៃវិធាន ៣៣ និង៣៤ និងទោះជាត្រូវស្នើសុំការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចក៏ដោយ ។

វិធាន៣: បទអន្តរាគមន៍ទាំងឡាយទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក មិនបានធ្វើឱ្យប្រែប្រួលដល់បេតិកភណ្ឌនេះឡើយ ទោះជាវាមានសារសំខាន់ដើម្បីឈានទៅសម្រេចគោលបំណងនៃគម្រោងនេះក៏ដោយ ។

វិធាន៤: បទអន្តរាគមន៍ទាំងឡាយទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ត្រូវតម្រូវឱ្យមានបច្ចេកទេស និងការរុករកដែលមិនមានការបំផ្លិចបំផ្លាញ ចំពោះការប្រមូលយកវត្ថុទាំងឡាយ ។ ប្រសិនបើការធ្វើកំណាយ ឬការប្រមូលយកបង្ហាញថាមានសារសំខាន់ចំពោះគោលដៅនៃការសិក្សាវិទ្យាសាស្ត្រ ឬចំពោះកិច្ចការពារជាស្ថាពរ នៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក វិធីសាស្ត្រនិង បច្ចេកទេសទាំងនោះ ដែលយកមកប្រើប្រាស់ត្រូវតែមានកម្រិតបំផ្លិចបំផ្លាញយ៉ាងតិចតួចបំផុត និងត្រូវតែបង្គួលក្នុណៈងាយស្រួលចំពោះការថែរក្សាការពារដំណែលទាំងឡាយនេះ ។

វិធាន៥: បទអន្តរាគមន៍ទាំងឡាយទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក មិនត្រូវធ្វើឱ្យប្រែប្រួល ដោយឥតប្រយោជន៍ដល់សំណល់ឆ្អឹងរបស់មនុស្ស និងកន្លែងពិសិដ្ឋនានាឡើយ ។

វិធាន៦: បទអន្តរាគមន៍ទាំងឡាយទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ត្រូវតែបញ្ញត្តិយ៉ាងតឹងរឹង ដើម្បីធ្វើឱ្យព័ត៌មានផ្នែកវប្បធម៌ ប្រវត្តិសាស្ត្រ និងបុរាណវត្ថុវិទ្យា ដែលប្រមូលបាន អាចចុះបញ្ជីបានត្រឹមត្រូវ ។

វិធាន៧: រាល់បំណងស្វែងយល់របស់សាធារណជនចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក ត្រូវតែសម្រួលជូន លើកលែងតែក្នុងករណីដែលបំណងស្វែងយល់នេះមានវិសមិតភាពជាមួយកិច្ចការពារ និងការគ្រប់គ្រងនៃរមណីយដ្ឋាននោះ ។

វិធាន៨: កិច្ចសហប្រតិបត្តិការអន្តរជាតិផ្នែកអន្តរាគមន៍លើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ត្រូវតែទទួលបានការលើកទឹកចិត្ត ដើម្បីសម្រួលដល់ការផ្លាស់ប្តូរប្រកបដោយផ្លែផ្កា រវាងបុរាណវិទូនិងអ្នកឯកទេសវិជ្ជាជីវៈដទៃទៀត ដែលមានការពាក់ព័ន្ធ និងដើម្បីប្រើប្រាស់ឱ្យបានប្រសើរបំផុតនូវសមត្ថកិច្ចរបស់ពួកគេ ។

២.- ពិពណ៌នាអំពីគម្រោង

វិធាន៩: មុនកិច្ចអន្តរាគមន៍ទាំងអស់ ការពិពណ៌នាអំពីគម្រោងត្រូវបានគាក់តែងឡើង និងដាក់ជូនពិនិត្យ ដើម្បីសុំការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ដែលជាអ្នកទទួលរាល់ព័ត៌មានវិទ្យាសាស្ត្រចាំបាច់នានា ។

វិធាន១០: ការពិពណ៌នាគម្រោងរួមមាន:

(ក) តុល្យការនៃការសិក្សាបឋម ឬដំបូង

(ខ) សេចក្តីប្រកាស និងគោលបំណងនៃគម្រោង

(គ) វិធី និងបច្ចេកទេសដែលនឹងប្រើប្រាស់

(យ) ផែនការហិរញ្ញប្បទាន

(ង) ប្រតិទិនគ្រោងទុកនៃការប្រតិបត្តិគម្រោង

(ច) សមាសភាពនៃក្រុមទទួលខុសត្រូវគម្រោង ដោយមានការបញ្ជាក់ពីលក្ខណសម្បត្តិ មុខងារ និងបទពិសោធន៍របស់សមាជិកក្រុមនីមួយៗ

(ឆ) កម្មវិធីវិភាគ និងកម្មវិធីការងារដទៃទៀត ត្រូវប្រកាន់យកបន្ទាប់ពីសកម្មភាពនៅការដ្ឋាន

(ជ) កម្មវិធីអភិរក្សសម្ភារៈបុរាណវត្ថុវិទ្យា និងរមណីយដ្ឋាន ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមានសមត្ថកិច្ច

(ឈ) គោលនយោបាយគ្រប់គ្រង និងថែទាំរមណីយដ្ឋានសម្រាប់ពេញមួយរយៈពេល នៃគម្រោងមួយ

(ញ) កម្មវិធីរក្សាឯកសារ

(ដ) ផែនការសន្តិសុខ

(ឋ) នយោបាយបរិស្ថាន

(ឌ) បែបបទសហការជាមួយសារមន្ទីរ និងស្ថាប័នដទៃទៀតជាពិសេសផ្នែកវិទ្យាសាស្ត្រ

(ឍ) ផែនការរៀបចំរបាយការណ៍

(ណ) បែបបទនៃការរក្សាទុកបណ្ណសារកំណាយ រួមទាំងផ្នែកនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលប្រមូលបាន និង

(ត) កម្មវិធីផ្សព្វផ្សាយ ។

វិធាន១១: រាល់កិច្ចអន្តរាគមន៍ទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ត្រូវដំណើរការឱ្យស្របតាមការពិពណ៌នាគម្រោងដែលយល់ព្រមដោយអាជ្ញាធរមានសមត្ថកិច្ច។

វិធាន១២: ក្នុងករណីនៃការរកឃើញដោយមិនបានគ្រោងទុក ឬក្នុងករណីនៃការផ្លាស់ប្តូរសភាពការណ៍ ការពិពណ៌នាគម្រោង ត្រូវតែពិនិត្យឡើងវិញ និងកែសម្រួល ដោយមានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ច។

វិធាន១៣: ក្នុងករណីបន្ទាន់ ឬក្នុងករណីនៃការរកឃើញដោយចៃដន្យ រាល់កិច្ចអន្តរាគមន៍ទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក រួមទាំងវិធានការអភិរក្សនានា ឬសកម្មភាពរយៈពេលខ្លី ជាពិសេសដើម្បីស្ថេរភាពរមណីយដ្ឋាន និងដើម្បីកិច្ចអន្តរាគមន៍ដើម្បីថែរក្សាបេតិកភណ្ឌវប្បធម៌ក្រោមទឹក អាចអនុញ្ញាតឱ្យបាន ទោះបីជាគ្មានបទពិពណ៌នា

គម្រោងក៏ដោយ ។

៣.- ការសិក្សាបឋម

វិធាន១៤: ការសិក្សាបឋមនានា ដែលមានចែងនៅក្នុងវិធាន១០(ក) រួមមានការវាយតម្លៃអំពីសារៈសំខាន់នៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក បរិស្ថានធម្មជាតិ និងពីហានិភ័យ ដែលនឹងត្រូវប្រឈមចំពោះការបំផ្លិចបំផ្លាញដោយគម្រោងដែលបានគ្រោងទុក ព្រមទាំងលទ្ធភាពនៃការទទួលបាននូវទិន្នន័យនានា ដែលឆ្លើយតបទៅនឹងកម្មវត្ថុនៃគម្រោង ។

វិធាន១៥: ការវាយតម្លៃនេះរួមមានផងដែរនូវការសិក្សាជាមូលដ្ឋានអំពីការវាយតម្លៃបែបប្រវត្តិសាស្ត្រ និងបែបបុរាណវត្ថុវិទ្យា អំពីលក្ខណៈចរិតបែបបុរាណវត្ថុវិទ្យា និងបែបបរិស្ថាននៃរមណីយដ្ឋាន និងអំពីផលវិបាកនៃរាល់ការជ្រៀតចូលជាយថាហេតុចំពោះស្ថេរភាពរយៈពេលវែងនៃបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលពាក់ព័ន្ធដោយកិច្ចអន្តរាគមន៍នានា ។

៤.- គោលបំណង វិធីសាស្ត្រ និងបច្ចេកទេសនៃគម្រោង

វិធាន១៦: វិធីសាស្ត្រទាំងឡាយដែលប្រើប្រាស់ត្រូវស្របជាមួយនឹងគោលបំណងនៃគម្រោង ហើយបច្ចេកទេសប្រើប្រាស់ក៏ត្រូវមានលក្ខណៈប្រែប្រួលតិចតួចដែលអាចធ្វើទៅបាន ។

៥.- ហិរញ្ញប្បទាន

វិធាន១៧: លើកលែងតែក្នុងករណីដែលមានការប្រញាប់បន្ទាន់ក្នុងកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ហិរញ្ញប្បទានដ៏សមល្មមមួយត្រូវបានធានាជាមុន មុនពេលចាប់ផ្តើមគ្រប់អន្តរាគមន៍ ក្នុងកម្រិតគ្រប់គ្រាន់មួយដើម្បីដឹកនាំ គ្រប់គ្រងបានល្អគ្រប់ដំណាក់ការងារ ដូចដែលបានគ្រោងទុកនៅក្នុងការពិពណ៌នាគម្រោង រួមទាំងការថែរក្សាការរក្សាទុកឯកសារ និងការអភិរក្សសម្ភារៈបុរាណវត្ថុវិទ្យាដែលប្រមូលបាន ព្រមទាំងការរៀបចំតាក់តែង និងការផ្សព្វផ្សាយរបាយការណ៍នានា ។

វិធាន១៨: ការពិពណ៌នាគម្រោងត្រូវធានាថាគម្រោងនេះអាចនឹងត្រូវធ្វើហិរញ្ញប្បទានគ្រប់គ្រាន់រហូតដល់

កាលកំណត់នៃលទ្ធផលរបស់វា ដោយទទួលបាននូវការធានារ៉ាប់រងមួយជាឧទាហរណ៍។

វិធាន១៩: ការពិពណ៌នាគម្រោងរួមមានផែនការប្រញាប់បន្ទាន់ ដែលធានាបាននូវការថែរក្សាបេតិកភណ្ឌវប្បធម៌ក្រោមទឹក និងការរក្សាទុកឯកសារដែលមានការពាក់ព័ន្ធ ក្នុងករណីដែលហិរញ្ញប្បទានគ្រោងទុកនោះត្រូវបានកាត់ផ្តាច់។

៦.- រយៈពេលនៃគម្រោង - ប្រតិទិនការងារ

វិធាន២០: មុនការចាប់ផ្តើមគ្រប់កិច្ចអន្តរាគមន៍ ប្រតិទិនការងារសមស្របមួយត្រូវបានបង្កើតឡើងដើម្បីធានាផលសម្រេចនូវរាល់ដំណាក់កាលនានានៃគម្រោង រួមទាំងការថែរក្សា ការរក្សាទុកឯកសារ និងការអភិរក្សផ្នែកនានានៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលប្រមូលមកបាន ព្រមទាំងការរៀបចំតាក់តែង និងការផ្សព្វផ្សាយរបាយការណ៍នានា។

វិធាន២១: ការពិពណ៌នាគម្រោងរួមមានផែនការប្រញាប់បន្ទាន់ដែលធានាការថែរក្សាបេតិកភណ្ឌវប្បធម៌ក្រោមទឹក និងការរក្សាទុកឯកសារដែលជាប់ពាក់ព័ន្ធ ក្នុងករណីដែលគម្រោងនេះនឹងត្រូវកាត់ផ្តាច់ ឬបង្រួញពេល។

៧.- សមត្ថភាព និងគុណភាពជំនាញ

វិធាន២២: រាល់អន្តរាគមន៍ទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក អាចនឹងធ្វើបានតែក្នុងករណីដែលមានការដឹកនាំ និងការត្រួតពិនិត្យ និងដោយមានវត្តមានជាទៀងទាត់របស់អ្នកឯកទេសដែលមានជំនាញគ្រប់គ្រាន់ផ្នែកបុរាណវត្ថុវិទ្យាក្រោមទឹក នឹងដែលមានសមត្ថភាពផ្នែកវិទ្យាសាស្ត្រស្របតាមប្រភេទនៃគម្រោងនេះ។

វិធាន២៣: គ្រប់សមាជិកទាំងអស់នៃក្រុមដែលទទួលខុសត្រូវគម្រោងត្រូវមានគុណភាពជំនាញ និងមានសមត្ថភាពមួយដែលគេទទួលស្គាល់ ដោយប្រៀបទៅនឹងបេសកកម្មរបស់ពួកគេ។

៨.- ការថែរក្សា និងការគ្រប់គ្រងរមណីយដ្ឋាន

វិធាន២៤: កម្មវិធីនៃការថែរក្សាត្រូវបានគ្រោងទុកជាមុននូវវិធីថែទាំដ្ឋានដំណែលបុរាណវត្ថុវិទ្យា ក្នុងអំឡុង

ពេលនៃកិច្ចអន្តរាគមន៍ទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក និងក្នុងអំឡុងពេលនៃការដឹកជញ្ជូនដាំនលលបុរាណវត្ថុវិទ្យាសម្រាប់រយៈពេលវែង។ ការថែរក្សានេះត្រូវធ្វើទៅតាមបទដ្ឋានវិជ្ជាជីវៈនានាដែលនៅជាធរមាន ។

វិធាន២៥: កម្មវិធីនៃការគ្រប់គ្រងរមណីយដ្ឋានត្រូវបានគ្រោងទុកជាមុននូវកិច្ចការពារ និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដែលកំពុងដំណើរការនៅការដ្ឋាននិងក្នុងកាលកំណត់មួយ ។ កម្មវិធីនេះរួមមានព័ត៌មានរបស់សាធារណជន ការអនុវត្តនូវមធ្យោបាយសមហេតុសមផល ដើម្បីស្ថេរភាពនីយកម្មរមណីយដ្ឋាន ដើម្បីការឃ្លាំមើល និងការការពារ ប្រឆាំងនឹងការជ្រៀតចូលដោយខុសច្បាប់ ។

៩.- ការរក្សាទុកឯកសារ

វិធាន២៦: កម្មវិធីនៃការរក្សាទុកឯកសារ រួមមានការរក្សាទុកឯកសារពិស្តារ នៃរាល់អន្តរាគមន៍ទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក រួមទាំងរបាយការណ៍សកម្មភាពមួយដែលឆ្លើយតបទៅនឹងបទដ្ឋានវិជ្ជាជីវៈផ្នែករក្សាទុកឯកសារបុរាណវត្ថុវិទ្យា ដែលនៅជាធរមាន។

វិធាន២៧: ការរក្សាទុកឯកសាររួមមានជាអប្បបរមានូវបញ្ជីសារពើភណ្ឌពិស្តារមួយនៃរមណីយដ្ឋាន រួមទាំងការបញ្ជាក់ពីប្រភពនៃសមាសធាតុបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលបានផ្លាស់ទី ឬបានប្រមូលមក ក្នុងពេលកំពុងអន្តរាគមន៍ទៅលើបេតិកភណ្ឌវប្បធម៌ក្រោមទឹក ទៅលើសៀវភៅកំណត់ហេតុរបស់ការដ្ឋាន ប្លង់នានា រូបភាពនានា ប្លង់ពុះ ព្រមទាំងរូបថតនានា ឬគ្រប់ឯកសារកត់ត្រាផ្សេងៗទៀត។

១០.- សន្តិសុខ

វិធាន២៨: ផែនការសន្តិសុខមួយពេញលេញត្រូវបានបង្កើតឡើង ដើម្បីធានាការពារសន្តិសុខ និងសុខមាលភាពរបស់សមាជិកទាំងឡាយ នៃក្រុមដែលទទួលខុសត្រូវគម្រោង និងអ្នកដទៃទៀត ។ ផែនការនេះសមស្របទៅនឹងបញ្ញត្តិច្បាប់ និងវិជ្ជាជីវៈដែលនៅជាធរមាន។

១១.- បរិស្ថាន

វិធាន២៩: គោលនយោបាយបរិស្ថានពេញលេញមួយត្រូវបានរៀបចំតាក់តែងឡើង ដើម្បីរារាំងរាល់ការប៉ះ

កាលដោយខុសច្បាប់ដល់ជំរាលសមុទ្រជ្រៅៗ និងជីវសមុទ្រ ។

១២.- របាយការណ៍

វិធាន៣០: _ របាយការណ៍បណ្តោះអាសន្នទាំងឡាយនិងរបាយការណ៍បញ្ចប់មួយ ត្រូវបានរៀបចំឡើងស្របតាមប្រតិទិនការងារដែលមានចែងក្នុងបទពិពណ៌នានៃគម្រោងផែនការ និងត្រូវបានតម្កល់ទុកក្នុងបណ្ណសារដ្ឋានសាធារណៈសមស្រប ។

វិធាន៣១: របាយការណ៍នីមួយៗរួមមាន :

(ក) សេចក្តីថ្លែងពីគោលបំណងនានា

(ខ) សេចក្តីថ្លែងពីវិធីសាស្ត្រ និងបច្ចេកទេសដែលប្រើប្រាស់

(គ) សេចក្តីថ្លែងពីលទ្ធផលទទួលបាន

(ឃ) ការរក្សាទុកឯកសារក្រាហ្វិក និងរូបថតសំខាន់ៗដែលមានការពាក់ព័ន្ធទៅនឹងគ្រប់ដំណាក់កាលនៃកិច្ចអន្តរាគមន៍

(ង) អនុសាសន៍នានាពាក់ព័ន្ធទៅនឹងការថែរក្សា និងការអភិរក្សសមាសធាតុនានា នៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកដែលប្រមូលបាន ព្រមទាំងការថែរក្សា និងអភិរក្សរមណីយដ្ឋាន និង

(ច) -អនុសាសន៍នានាពាក់ព័ន្ធទៅនឹងសកម្មភាពអនាគត ។

១៣.- ការអភិរក្សបណ្ណសារនៃគម្រោង

វិធាន៣២: របៀបបទនៃការអភិរក្សបណ្ណសារនៃគម្រោងត្រូវតែសម្រេចឱ្យបានមុនការចាប់ផ្តើមរាល់កិច្ចអន្តរាគមន៍ទាំងអស់ និងត្រូវបានចែងនៅក្នុងបទពិពណ៌នានៃគម្រោង ។

Règle 24. Le programme de préservation prévoit le traitement des vestiges archéologiques pendant les interventions sur le patrimoine culturel subaquatique, pendant leur transport et à long terme. La préservation se fait selon les normes professionnelles en vigueur.

Règle 25. Le programme de gestion du site prévoit la protection et la gestion *in situ* du patrimoine culturel subaquatique en cours de chantier et à son terme. Le programme comprend l'information du public, la mise en oeuvre de moyens raisonnables pour la stabilisation du site, la surveillance, et la protection contre les intrusions.

IX. Documentation

Règle 26. Le programme de documentation comporte la documentation détaillée des interventions sur le patrimoine culturel subaquatique, y compris un rapport d'activité, répondant aux normes professionnelles de documentation archéologique en vigueur.

Règle 27. La documentation comprend au minimum un inventaire détaillé du site, y compris l'indication de la provenance des éléments du patrimoine culturel subaquatique déplacés ou récupérés au cours des interventions sur le patrimoine culturel subaquatique, les carnets de chantier, les plans, les dessins, les coupes, ainsi que les photographies ou tout document sur d'autres supports.

X. Sécurité

Règle 28. Un plan de sécurité adéquat est établi en vue de garantir la sécurité et la santé des membres de l'équipe en charge du projet et des tiers. Ce plan est conforme aux prescriptions légales et professionnelles en vigueur.

XI. Environnement

Règle 29. Une politique de l'environnement adéquate est élaborée afin d'empêcher toute atteinte indue aux fonds marins et à la vie marine.

XII. Rapports

Règle 30. Des rapports intérimaires et un rapport final sont présentés conformément au calendrier figurant dans le descriptif du projet et déposés dans les dépôts d'archives publiques appropriés.

Règle 31. Chaque rapport comprend :

(a) un exposé des objectifs ;

(b) un exposé des méthodes et techniques employées ;

(c) un exposé des résultats obtenus ;

(d) la documentation graphique et photographique essentielle se rapportant à toutes les phases de l'intervention ;

(e) des recommandations concernant la préservation et la conservation des éléments du patrimoine culturel subaquatique récupérés, ainsi que celles du site ; et

(f) des recommandations relatives à des activités futures.

XIII. Conservation des archives du projet

Règle 32. Les modalités de conservation des archives du projet sont arrêtées avant le début de toute intervention et figurent dans le descriptif du projet.

Règle 33. Les archives du projet, comprenant les éléments du patrimoine culturel subaquatique récupérés et une copie de toute la documentation pertinente, sont, autant que possible, gardées intactes et complètes sous forme de collection, de manière à permettre aux spécialistes et au public d'y avoir accès, et de manière à assurer la conservation de ces archives. Ceci est réalisé le plus rapidement possible et, au plus tard, dans les dix ans suivant le terme du projet, dans la mesure où cela est compatible avec la conservation du patrimoine culturel subaquatique.

Règle 34. Les archives du projet sont gérées conformément aux normes professionnelles internationales et sous réserve de l'aval des services compétents.

XIV. Diffusion

Règle 35. Le projet prévoit, dans la mesure du possible, des actions d'éducation et la vulgarisation des résultats du projet, à l'intention du grand public.

Règle 36. Pour chaque projet, un rapport final de synthèse est :

(a) rendu public dès que possible, compte tenu de la complexité du projet et de la nature confidentielle ou sensible de l'information ; et

(b) déposé auprès des archives publiques appropriées.

The foregoing is the authentic text of the Convention duly adopted by the General Conference of the United Nations Educational, Scientific and Cultural Organization during its thirty-first session, which was held in Paris and declared closed the third day of November 2001.

Le texte qui précède est le texte authentique de la Convention dûment adoptée par la Conférence générale de l'Organisation des Nations Unies pour l'éducation, la science et la culture à sa trente-et-unième session, qui s'est tenue à Paris et qui a été déclarée close le troisième jour de novembre 2001.

Lo anterior es el texto auténtico de la Convención aprobada en buena y debida forma por la Conferencia General de la Organización de las Naciones Unidas para la Educación, la Ciencia y la Cultura, en su trigésimo primera reunión, celebrada en París y terminada el tres de noviembre de 2001.

Приведенный выше текст является подлинным текстом Конвенции, надлежащим образом принятой Генеральной конференцией Организации Объединенных Наций по вопросам образования, науки и культуры на ее тридцать первой сессии, состоявшейся в Париже и закончившейся третьего ноября 2001 года.

ويعتبر النص المتقدم هو النص الأصلي للاتفاقية التي اعتمدها على النحو الواجب المؤتمر العام لمنظمة الأمم المتحدة للتربية والعلم والثقافة في دورته الحادية والثلاثين المنعقدة في باريس والتي أعلن اختتامها في اليوم الثالث من نوفمبر/تشرين الثاني ٢٠٠١.

上述文本为在巴黎召开的，于2001年11月3日闭幕的联合国教科文组织第三十一届大会正式通过的公约的正式文本。

IN WITNESS WHEREOF we have appended our signatures this 6th day of November 2001.

EN FOI DE QUOI ont apposé leur signature, ce 6ème jour de novembre 2001.

EN FE DE LO CUAL estampan sus firmas, en este día 6 de noviembre de 2001.

В УДОСТОВЕРЕНИЕ ЧЕГО настоящую Конвенцию подписали 6 ноября 2001 года.

وإثباتاً لما تقدم وقعنا بإمضائنا في هذا اليوم السادس من نوفمبر/تشرين الثاني ٢٠٠١.

为此，我们于2001年11月6日签上我们的名字，以资证明。

The President of the General Conference
Le Président de la Conférence générale
El Presidente de la Conferencia General

Председатель Генеральной конференции

المدير العام

大会主席

The Director-General
Le Directeur général
El Director General

Генеральный директор

رئيس المؤتمر العام

总干事

Certified Copy
Copie certifiée conforme
Copia certificada conforme
Заверенная копия

صورة طبق الأصل

兹证明文本无误

Paris,

Legal Adviser
United Nations Educational, Scientific and Cultural Organization

Conseiller juridique
De l'Organisation des Nations Unies pour l'éducation, la science et la culture

Consejero jurídico
de la Organizacion des las Naciones Unidas para la Educacion, la Ciencia y la Cultura

Юридический советник
Организации Объединенных Наций по вопросам образования, науки и культуры

المستشار القانوني

منظمة الأمم المتحدة للتربية والعلم والثقافة

联合国教育、科学及文化组织
法律顾问

Done in Paris this 6th day of November 2001 in two authentic copies bearing the signature of the President of the thirty-first session of the General Conference and of the Director-General of the United Nations Educational, Scientific and Cultural Organization, which shall be deposited in the archives of the United Nations Educational, Scientific and Cultural Organization and certified true copies of which shall be delivered to all the States and territories referred to in Article 26 as well as to the United Nations.

Fait à Paris ce sixième jour de novembre 2001, en deux exemplaires authentiques portant la signature du Président de la Conférence générale réunie en sa trente-et-unième session, et du Directeur général de l'Organisation des Nations Unies pour l'éducation, la science et la culture, qui seront déposés dans les archives de l'Organisation des Nations Unies pour l'éducation, la science et la culture, et dont les copies certifiées conformes seront remises à tous les États et territoires visés à l'article 26 ainsi qu'à l'Organisation des Nations Unies.

Hecho en Paris en este día seis de noviembre de 2001, en dos ejemplares auténticos que llevan la firma del Presidente de la Conferencia General, en su trigésimo primera reunión, y del Director General de la Organización de las Naciones Unidas para la Educación, la Ciencia y la Cultura, ejemplares que se depositarán en los archivos de esta Organización, y cuyas copias certificadas conformes se remitirán a todos los Estados y territorios a que se refiere el Artículo 26, así como a las Naciones Unidas.

Совершено в г. Париже 6 ноября 2001 года в двух аутентичных экземплярах за подписью Председателя Генеральной конференции, собравшейся на тридцать первую сессию, и Генерального директора Организации Объединенных Наций по вопросам образования, науки и культуры, надлежащим образом заверенные копии которых будут направлены всем государствам и территориям, указанным в статье 26, а также Организации Объединенных Наций.

صدرت في باريس في هذا اليوم السادس من نوفمبر/تشرين الثاني ٢٠٠١، من نسختين أصليتين تحملان توقيعي رئيس المؤتمر العام في دورته الحادية والثلاثين والمدير العام لمنظمة الأمم المتحدة للتربية والعلم والثقافة، وستودع في محفوظات منظمة الأمم المتحدة للتربية والعلم والثقافة، وسترسل نسخ مُصدّق عليها مطابقة للأصل إلى جميع الدول المشار إليها في المادة ٢٦ وإلى منظمة الأمم المتحدة.

2001年11月6日订于巴黎，正本两份，由联合国教科文组织大会第三十一届会议主席和联合国教科文组织总干事签署，并将存放于联合国教科文组织的档案中。经核准的副本将分送第26条所提及的所有国家和地区以及联合国。

ព្រះរាជក្រម

នស/រកម/០៧០៧/០២៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ថ្មី ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការកំណត់ចំនួនអាសនៈរដ្ឋសភានីតិកាលទី៤ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៣ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់
ស្តីពី
ការកំណត់ចំនួនអាសនៈរដ្ឋសភានីតិកាលទី ៤

មាត្រា ១.–

ចំនួនអាសនៈរដ្ឋសភានីតិកាលទី ៤ ត្រូវកំណត់ត្រឹមមួយរយម្ភៃបី (១២៣) ។

មាត្រា ២.–

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣/ល.០៧០៧.៣១៦ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង

លេខ: ៣០០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៧

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

យុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/៣១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគុណជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ង្វៀន ធៀនញ៉ិន (NGUYEN THIEN NHAN) ជនជាតិវៀតណាម សញ្ជាតិវៀតណាម កើតថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៦៣ នៅខេត្តហ្វានធៀន ប្រទេសវៀតណាម ដោយប្តូរឈ្មោះជា ឡាយ ស៊ុនមិញ (LAY SUN MINH) ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣.ល.០៧០៧.៣៣៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៧

លេខ ០២២៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ [illegible] ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
[illegible] ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/៣១៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា នាសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី២ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា

ត្រាស់បង្គាប់

មាត្រា១: តែងតាំងឯកឧត្តម **ជា សុធន** ជានាយករងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋលេខាធិការ ។

មាត្រា២: សម្តេចប្រធានព្រឹទ្ធសភា និងសម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

៣រល.០៧០៧.៣៣៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៧

លេខ: ៣៤៨៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/៣១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានតែងតាំងឯកឧត្តម យឹម បូរ ជាអគ្គលេខាធិការរង រាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា ២: រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧០៧.៣៤០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៧

លេខៈ ៣១៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible]

ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/៣១៨

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រី រាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌ មន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្ដម ឈុន ស៊ីរុន ជាអភិបាលខេត្តកណ្ដាល ជំនួសឯកឧត្ដម ឃឹម បូរ ដែលត្រូវបានទទួលភារកិច្ចថ្មី ។

មាត្រា ២ : សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ។

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧០៧.៣៤១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៧

លេខ: ៣១៧ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុំ ចិនកេង

ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/៣១៩

យើង

ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ១២ ខែ ឱ្យទណ្ឌិតចំនួន ១១ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១ - ទណ្ឌិតឈ្មោះ សួស ឆាន ហៅ ញ៉ាញ់ ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី០១-៥-១៩៩៨ ពីបទ ក្រុមជនប្រដាប់អាវុធ ចាប់មនុស្សបង្ខាំង បង់ជីវិតទារយកប្រាក់ និងការកាន់កាប់អាវុធ ការពាក់ឯកសណ្ឋានខុសពីបទបញ្ជា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤១ ចុះថ្ងៃទី ១៣-៨-១៩៩៨ របស់តុលាការខេត្តកំពង់ស្ពឺ ។

២ - ទណ្ឌិតឈ្មោះ លុច មាស ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៧-១៩៩៨ ពីបទបង្កើតក្រុមប្រដាប់អាវុធ ប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ និងចាប់មនុស្សបង្ខាំងជីវិតទារប្រាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤២ ចុះថ្ងៃទី ១៣-៨-១៩៩៨ របស់តុលាការខេត្តកំពង់ស្ពឺ ។

៣ - ទណ្ឌិតឈ្មោះ ទៀ ជួន ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២១-៦-១៩៩៩ ពីបទអំពើភេរវកម្ម ចាប់មនុស្ស បង្ខាំងមនុស្សខុសច្បាប់ជីវិតទារប្រាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធ

នាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ០៤ ចុះថ្ងៃទី ១៤-០១-២០០០ របស់តុលាការខេត្តកំពង់ស្ពឺ ។

៤. ទណ្ឌិតឈ្មោះ **សាំង រិន** ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-៧-២០០១ ពីបទមនុស្សឃាដគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៤ ចុះថ្ងៃទី ១២-១០-២០០១ របស់តុលាការខេត្តកំពង់ស្ពឺ ។

៥. ទណ្ឌិតឈ្មោះ **សឿន ពៅ** ហៅ ផៃ ណុំ ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី១៩-៦-១៩៩៩ ពីបទអំពើភេរវកម្ម ចាប់មនុស្ស បង្ខាំងមនុស្សខុសច្បាប់ ជំរិតទារប្រាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ ចុះថ្ងៃទី ១៤-០១-២០០០ របស់តុលាការខេត្តកំពង់ស្ពឺ ។

៦. ទណ្ឌិតឈ្មោះ **សែម ម៉ុន** ហៅ ខុំ ញៀន ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២០-៦-១៩៩៩ ពីបទភេរវកម្ម ចាប់មនុស្សបង្ខាំង បង្ខំជំរិតទារយកប្រាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ ចុះថ្ងៃទី ១៤-០១-២០០០ របស់តុលាការខេត្តកំពង់ស្ពឺ ។

៧. ទណ្ឌិតឈ្មោះ **ងឹម ចេក** ហៅ **ឡឺ លី** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៩-៦-១៩៩៩ ពីបទអំពើភេរវកម្ម ចាប់មនុស្សបង្ខាំងមនុស្សខុសច្បាប់ជំរិតទារប្រាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ ចុះថ្ងៃទី ១៤-០១-២០០០ របស់តុលាការខេត្តកំពង់ស្ពឺ ។

៨. ទណ្ឌិតឈ្មោះ **សុខ ឈឿត** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-៩-១៩៩៤ ពីបទរំលោភសេពសន្ថវៈ និង អំពើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ ចុះថ្ងៃទី ២៣-៣-១៩៩៥ របស់តុលាការខេត្តកោះកុង ។

៩. ទណ្ឌិតឈ្មោះ **ខយ ធី** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៣-៦-១៩៩៩ ពីបទប្លន់ និងសម្លាប់មនុស្សដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤១ ចុះថ្ងៃទី ៣០-១១-១៩៩៩ របស់តុលាការខេត្តកោះកុង ។

១០. ទណ្ឌិតឈ្មោះ **ឌីត សុផល ហៅ ម៉ៅ** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៧-៦-១៩៩៦ ពីបទសមគំនិតឃាតកម្ម និង ប្លន់ប្រដាប់អាវុធគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៧ ចុះថ្ងៃទី ១២-៦-១៩៩៦ របស់តុលាការខេត្តស្ទឹងត្រែង ។

១១. ទណ្ឌិតឈ្មោះ **ទ្រី មាន** ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៥-១៩៩៧ ពីបទប្លន់ និង សម្លាប់មនុស្សដោយចេតនាគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៨ ចុះថ្ងៃទី ២៤-១១-១៩៩៧ របស់តុលាការខេត្តស្ទឹងត្រែង ។

មាត្រា ២ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៩ ខែ ឱ្យទណ្ឌិតចំនួន ១៣ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ៖

១~ ទណ្ឌិតឈ្មោះ **ឡាយ សំអាត** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-៤-២០០០ ពីបទប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ និង សម្លាប់មនុស្សដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨១ ចុះថ្ងៃទី ១១-៨-២០០០ របស់តុលាការខេត្តកំពង់ស្ពឺ ។

២~ ទណ្ឌិតឈ្មោះ **ជៀម សុខុម** ហៅ **ទាសនា** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-៨-១៩៩៩ ពីបទសមគំនិតធ្វើមនុស្សឃាតដោយគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ១៩-០១-២០០០ របស់តុលាការខេត្តកំពង់ស្ពឺ ។

៣~ ទណ្ឌិតឈ្មោះ **អំ អឿន** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២១-៥-១៩៩៨ ពីបទបង្កើតក្រុមប្រដាប់អាវុធ មនុស្សឃាត ចាប់មនុស្សបង្ខាំងបង្ខំទារប្រាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៧ ចុះថ្ងៃទី ២២-១០-១៩៩៨ របស់តុលាការខេត្តកំពង់ស្ពឺ ។

៤~ ទណ្ឌិតឈ្មោះ **សឿក សុផាត** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០២-៧-២០០២ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣ ចុះថ្ងៃទី ៣០-៤-២០០៣ របស់តុលាការខេត្តកំពង់ស្ពឺ ។

៥~ ទណ្ឌិតឈ្មោះ **អឿ អ៊ឹម** ភេទប្រុស អាយុ ៥០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៨-៤-២០០១ ពីបទសម្លាប់មនុស្សដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥២ ចុះថ្ងៃទី ០១-៨-២០០១ របស់តុលាការខេត្តកំពង់ស្ពឺ ។

៦~ ទណ្ឌិតឈ្មោះ **ឈូ ចយ** ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១១-៤-២០០០ ពីបទមនុស្សឃាតគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០៤ ចុះថ្ងៃទី ២១-១១-២០០០ របស់តុលាការខេត្តកំពង់ស្ពឺ ។

៧~ ទណ្ឌិតឈ្មោះ **ស្រី សុផល** ហៅ **មឿន ជា** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៩-៦-១៩៩៩ ពីបទសមគំនិតអំពើភេរវកម្ម ចាប់មនុស្សបង្ខាំងខុសច្បាប់ ជំរិតទារប្រាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ ចុះថ្ងៃទី ១៤-០១-២០០០ របស់តុលាការខេត្តកំពង់ស្ពឺ ។

៨~ ទណ្ឌិតឈ្មោះ **ស្វាប ដារ៉ា** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១១-៩-១៩៩៧ ពីបទប្លន់សម្លាប់មនុស្ស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ ចុះថ្ងៃទី ១៦-០១-១៩៩៨ របស់តុលាការខេត្តកំពង់ស្ពឺ ។

៩~ ទណ្ឌិតឈ្មោះ **ឆេត សួន** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២១-៥-១៩៩៨ ពីបទបង្កើតក្រុមប្រដាប់អាវុធ មនុស្សឃាត ចាប់មនុស្ស បង្ខាំងបង្ខំទារប្រាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៧ ចុះថ្ងៃទី ២២-១០-១៩៩៨ របស់តុលាការខេត្តកំពង់ស្ពឺ ។

១០- ទណ្ឌិតឈ្មោះ **អ៊ុង សារិទ្ធ** ហៅ **ឃុន នាង** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៦-២០០០ ពីបទមនុស្សឃាតដោយចេតនាមានអាវុធ បង្ករបួសស្នាមដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៥៨ ចុះថ្ងៃទី ១៥-៦-២០០០ របស់តុលាការខេត្តកំពង់ស្ពឺ ។

១១- ទណ្ឌិតឈ្មោះ **ខៅ ណារី** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០២-៨-២០០១ ពីបទជួញដូរគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៤ "ដ" ចុះថ្ងៃទី ១០-៩-២០០៣ របស់តុលាការក្រុងភ្នំពេញ ។

១២- ទណ្ឌិតឈ្មោះ **អានឡាំងហ្វីលីប្ប បៀរ៉ូឌី** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៦-៦-២០០១ ពីបទអានាចារ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ២៥ "ឃ" ចុះថ្ងៃទី ២០-៣-២០០៦ របស់សាលាឧទ្ធរណ៍ ។

១៣- ទណ្ឌិតឈ្មោះ **ថោង គីមសួរ** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២២-៩-១៩៩៨ ពីបទមនុស្សឃាដគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលដីកាលេខ ១០៨ "គ" ចុះថ្ងៃទី ៣១-១២-២០០៣ របស់សាលាឧទ្ធរណ៍ ។

មាត្រា ៣ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៦ ខែ ឱ្យទណ្ឌិតចំនួន ២០ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ៖

១- ទណ្ឌិតឈ្មោះ **សុខ នាង** ភេទ ស្រី អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៨-០២-២០០៥ ពីបទពង្រត់មនុស្ស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥ ចុះថ្ងៃទី ១២-៧-២០០៥ របស់តុលាការខេត្តស្ទឹងត្រែង ។

២- ទណ្ឌិតឈ្មោះ **សួន ម៉ុន មិ** ហៅ **គិះ** ភេទ ប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៧-៤-២០០៤ ពីបទជួញដូរគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៤ ចុះថ្ងៃទី ០៣-១១-២០០៤ របស់តុលាការខេត្តស្ទឹងត្រែង ។

៣- ទណ្ឌិតឈ្មោះ **នឹម សានសារម្យ** ភេទ ប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១១-៩-២០០០ ពីបទសម្លាប់មនុស្ស និង ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ១៥ ចុះថ្ងៃទី ០៩-៣-២០០១ របស់តុលាការខេត្តកំពង់ស្ពឺ ។

៤- ទណ្ឌិតឈ្មោះ **ចេវ សុខ** ភេទប្រុស អាយុ ៣៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-៦-២០០០ ពីបទមនុស្សឃាតដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០៩ ចុះថ្ងៃទី ១៤-១២-២០០០ របស់តុលាការខេត្តកំពង់ស្ពឺ ។

៥- ទណ្ឌិតឈ្មោះ **ធី ថាវី** ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៣០-១២-២០០៥ ពីបទជួញដូរគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៤ "ឆ" ចុះថ្ងៃទី ១៥-៦-២០០៦ របស់តុលាការក្រុងភ្នំពេញ ។

៦- ទណ្ឌិតឈ្មោះ **ឈន វុត្ថា** ហៅ **ម៉ាប់** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៩-៩-២០០៣ ពីបទប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ "ង" ចុះថ្ងៃទី ១៤-៥-២០០៤ របស់តុលាការក្រុងភ្នំពេញ ។

៧- ទណ្ឌិតឈ្មោះ **ជា សាមិត្ត** ភេទប្រុស អាយុ ៤៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៧-៤-២០០១ ពីបទជួញដូរគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ៧០ "យ" ចុះថ្ងៃទី ២៣-៩-២០០៥ របស់សាលាឧទ្ធរណ៍ ។

៨- **ឈ្មោះ គាម សុផល** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៤-៩-២០០៤ ពីបទប្លន់ម៉ូតូ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥២ "ច" ចុះថ្ងៃទី ២២-៤-២០០៥ របស់តុលាការក្រុងភ្នំពេញ ។

៩- ទណ្ឌិតឈ្មោះ **ម៉ិន រត្ន័ សុធារិទ្ធ** ហៅ **ឆារ៉ែន** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៤-៩-២០០៤ ពីបទប្លន់ម៉ូតូ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥២ "ច" ចុះថ្ងៃទី ២២-៤-២០០៥ របស់តុលាការក្រុងភ្នំពេញ ។

១០- ទណ្ឌិតឈ្មោះ **ឡេង ម៉េងសៀម** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៤-៩-២០០៤ ពីបទប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥២ "ច" ចុះថ្ងៃទី ២២-៤-២០០៥ របស់តុលាការក្រុងភ្នំពេញ ។

១១-ទណ្ឌិតឈ្មោះ **ឡាយ សុខន** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៦-០១-២០០៦ ពីបទក្លែងលិខិតសាធារណៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ ប៉ុន្តែទោសត្រូវអនុវត្តក្នុងពន្ធនាគារកំណត់ ២ ឆ្នាំ ឯទោសនៅសល់ត្រូវព្យួររយៈពេលសាកល្បងចំនួន ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤០ "ខ" ចុះថ្ងៃទី ១០-៨-២០០៦ របស់តុលាការក្រុងភ្នំពេញ ។

១២- ទណ្ឌិតឈ្មោះ **ជុំ អាន** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៩-៦-២០០៤ ពីបទសញ្ជារកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២១ "ឈ" ចុះថ្ងៃទី ៣០-៨-២០០៥ របស់តុលាការក្រុងភ្នំពេញ ។

១៣- ទណ្ឌិតឈ្មោះ **គិន សៅសាយ័ណ្ឌ** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៦-០១-២០០៥ ពីបទប្លន់ (ឆក់ទូរស័ព្ទដៃ) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥

ឆ្នាំ តាមអំណាចសាលក្រមលេខ ១០០ "ច" ចុះថ្ងៃទី ០១-៨-២០០៥ របស់តុលាការក្រុងភ្នំពេញ ។

១៤. ទណ្ឌិតឈ្មោះ **ម៉ូ សុផា** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២១-០១-២០០៥ ពីបទប្លន់ (ឆក់ទូរស័ព្ទដៃ) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០០ "ច" ចុះថ្ងៃទី ០១-៨-២០០៥ របស់តុលាការក្រុងភ្នំពេញ ។

១៥. ទណ្ឌិតឈ្មោះ **លី ចាន់ សុជាតិ** ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៣-១១-២០០៥ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ០៣ "ឈ" ចុះថ្ងៃទី ១២-០១-២០០៦ របស់តុលាការក្រុងភ្នំពេញ ។

១៦. ទណ្ឌិតឈ្មោះ **ម៉ន ម៉ី** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-០១-២០០៦ ពីបទជួញដូរគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១៤ "ដ" ចុះថ្ងៃទី ២៥-៨-២០០៦ របស់តុលាការក្រុងភ្នំពេញ ។

១៧. ទណ្ឌិតឈ្មោះ **គុជ លីមស៊ុយ** ហៅ **គុយ ស៊ុយឆ្វី** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៦-១២-២០០៥ ពីបទបង្ករបួសស្នាមដោយចេតនា ដោយមានកាំបិត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៣ "ច" ចុះថ្ងៃទី ២០-៦-២០០៦ របស់តុលាការក្រុងភ្នំពេញ ។

១៨. ទណ្ឌិតឈ្មោះ **ជា ម៉ិន** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-១២-២០០២ ពីបទប៉ុនប៉ងធ្វើមនុស្សឃាដគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៦៩ "ច" ចុះថ្ងៃទី ០៥-៩-២០០៥ របស់សាលាឧទ្ធរណ៍ ។

១៩. ទណ្ឌិតឈ្មោះ **ឡៅ យ៉ុងចូក** ភេទប្រុស អាយុ ៣៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៣-៤-២០០៣ ពីបទសមគំនិតក្នុងអំពើសញ្ជារកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាច សាលដីកាលេខ ៦៦ "ឃ" ចុះថ្ងៃទី ១១-៩-២០០៦ របស់សាលាឧទ្ធរណ៍ ។

២០. ទណ្ឌិតឈ្មោះ **ញ៉ិល ញៀន** ហៅ **ភ្និញ** ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-៧-២០០២ ពីបទប្លន់ប្រដាប់អាវុធច្រើនលើក ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣៨ "ឆ" ចុះថ្ងៃទី ១៨-១១-២០០៥ របស់តុលាការក្រុងភ្នំពេញ ។

មាត្រា ៤ : ត្រូវលើកលែងទោសឱ្យទណ្ឌិតចំនួន ៦ នាក់ ដែលបានខិតខំ កែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១. ទណ្ឌិតឈ្មោះ **ផាត ឃឿន** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣០-១២-១៩៩៧ ពីបទបង្កើតក្រុមប្រដាប់អាវុធ និង ចាប់ជំរិតមនុស្សយកប្រាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធ

នាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣០ ចុះថ្ងៃទី ២៣-៦-១៩៩៨ របស់តុលាការខេត្តកំពង់ស្ពឺ ។

២. ទណ្ឌិតឈ្មោះ **សឿង ហឿន** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-១០-១៩៩៩ ពីបទសម្លាប់មនុស្សដោយចេតនាមានអារ៉ុច ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៧ ចុះថ្ងៃទី ២៦-៤-២០០០ របស់តុលាការខេត្តកំពង់ស្ពឺ ។

៣. ទណ្ឌិតឈ្មោះ **អ៊ុក ខន** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-១១-១៩៩៩ ពីបទភេរវកម្មចាប់ជំរិតទារប្រាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ១៦ ចុះថ្ងៃទី ០៨-០២-២០០៦ របស់តុលាការកំពូល ។

៤. ទណ្ឌិតឈ្មោះ **សិទ្ធ ស៊ីណា** ហៅ **វសាលី** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២១-១១-២០០០ ពីបទចាប់ជំរិតទារប្រាក់ និង ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ១១ "ខ" ចុះថ្ងៃទី ១៩-០១-២០០៥ របស់សាលាឧទ្ធរណ៍ ។

៥. ទណ្ឌិតឈ្មោះ **អ៊ួន សារ៉ាច** ភេទស្រី អាយុ ៣០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-៤-២០០៥ ពីបទជួញដូរគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ១០១ "ជ" ចុះថ្ងៃទី ២៨-៧-២០០៦ របស់តុលាការក្រុងភ្នំពេញ ។

៦. ទណ្ឌិតឈ្មោះ **យ៉ាន ផល** ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៦-៤-១៩៩៩ ពីបទសម្លាប់មនុស្សដោយចេតនាមានអារ៉ុច ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៣ ចុះថ្ងៃទី ២៦-១០-១៩៩៩ របស់តុលាការខេត្តកំពង់ស្ពឺ ។

មាត្រា ៥ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៦ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ចករ

នរោត្តម សីហមុនី

នស/រកត.០៧០៧.៣៤២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧

លេខ: ៣៧៩៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/៣២០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រ្តីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិ ថ្នាក់នាយឧត្តមសេនីយ៍ផ្កាយមាសបួន ជូនឯកឧត្តម ឧត្តមសេនីយ៍ឯក ខុល គៀន អត្តលេខ ០០២៧ នាយនគរបាលជាតិជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧០៧.៣៤៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧

លេខ ៣២៤ ស.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨០៧/៣២១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១.-ត្រូវបានតែងតាំងឯកឧត្តម **ជឹង សុខហាក់** ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ **រដ្ឋលេខាធិការ** ជំនួសឯកឧត្តម **ម៉ិន ហុន** ដែលត្រូវបានតែងតាំងជាអនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ។

មាត្រា២.-សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣.-ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៤.០៧០៨.៣៤៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី *១* ខែ *សីហា* ឆ្នាំ ២០០៧

លេខ: *៣៣១* ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ

លេខ: ០០៥ ព.រ.ក

សេចក្ដីសម្រេចរួម

ស្ដីពី

ការបង្កើតបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ សម្រាប់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ

ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា

ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលទ្ធផលបោះឆ្នោតជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២នៃព្រឹទ្ធសភា នាសម័យប្រជុំលើកទី១ នីតិកាលទី២ កាលពីថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦
- បានឃើញលទ្ធផលនៃសម័យប្រជុំលើកទី៤នីតិកាលទី៣នៃរដ្ឋសភាកាលពីថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ស្ដីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៧/២៥៦ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧ ស្ដីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិបីឆ្នាំ លើកទី៤
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានឃើញសេចក្ដីសម្រេចរួមលេខ ០១ ពរក ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៤ ស្ដីពីបៀវត្សមូលដ្ឋាន និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា១.- ត្រូវបានបង្កើតបេឡាសោធននិវត្តន៍និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈស្របតាមច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិនៅក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានរដ្ឋសភា និង អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាគុណប្រយោជន៍ជូនដល់អ្នករាជការនៃអគ្គលេខាធិការដ្ឋានទាំងបី ដែលចូលនិវត្តន៍ ឬ បាត់បង់សម្បទាវិជ្ជាជីវៈ ព្រមទាំងអ្នកកំពុងរស់នៅក្នុងបន្ទុករបស់អ្នកទាំងនោះ ។

អគ្គលេខាធិការ អគ្គលេខាធិការរង ដែលកំពុងកាន់តំណែងនៅអគ្គលេខាធិការដ្ឋាននៃស្ថាប័នទាំងបី អាចសុំចូលនិវត្តន៍នៅអគ្គលេខាធិការដ្ឋានសាមីបាន ប៉ុន្តែសាមីជនត្រូវបង់ភាគទានចូលបេឡាសោធននិវត្តន៍ ។

មាត្រា២.- បេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ជាអង្គភាពមួយបង្កើតឡើងដោយសេចក្តីសម្រេចរបស់ប្រធានស្ថាប័ននីមួយៗស្របតាមសេចក្តីសម្រេចនេះ ។

មាត្រា៣.- បេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈជាអង្គភាពមានស្វ័យភាពផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ជាអង្គភាពមួយដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធនៃអគ្គលេខាធិការដ្ឋាននីមួយៗ ។

មាត្រា៤.- បេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈគ្រប់គ្រងដោយអង្គភាពមួយដែលស្ថិតក្រោមការត្រួតពិនិត្យរបស់គណៈកម្មការមួយ ដឹកនាំដោយអគ្គលេខាធិការនីមួយៗ ។

ជំពូកទី ២

បេឡាសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ

មាត្រា៥.- អង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈមានសមាសភាព : ប្រធាន អនុប្រធាន បេឡាករ និង បុគ្គលិក ជាអ្នករាជការនៃអគ្គលេខាធិការដ្ឋាននីមួយៗ ។

មាត្រា៦.- អ្នករាជការទាំងអស់នៃក្រុមនីតិបញ្ញត្តិត្រូវចូលជាសមាជិកនៃបេឡាសោធននិវត្តន៍ និង បេឡាបាត់បង់សម្បទាវិជ្ជាជីវៈនៅតាមអគ្គលេខាធិការដ្ឋាននីមួយៗ ។

មាត្រា៧.- អង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ មានភារកិច្ចដូចខាងក្រោម :

១-ស្រាវជ្រាវ និងរៀបចំបទប្បញ្ញត្តិសម្រាប់បេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ

២- រៀបចំផែនការចំណូល-ចំណាយថវិកាប្រចាំឆ្នាំសម្រាប់បេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ

៣- ប្រមូលភាគទានពីសមាជិក ទទួលថវិកាឧបត្ថម្ភពីរាជរដ្ឋាភិបាល និង ទទួលជំនួយពីប្រភពផ្សេងៗ ទៀត

៤- ចាត់ចែង និង គ្រប់គ្រងការវិនិយោគ

៥- ចាត់ចែង គ្រប់គ្រង វាយតម្លៃ និង បើកផ្តល់សម្រាប់ការចំណាយបន្ទាប់បន្សំតាមការកំណត់

៦- រៀបចំរបាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ និង ប្រចាំឆ្នាំជូនគណៈកម្មការត្រួតពិនិត្យបេឡា និងអគ្គលេខាធិការ

៧- រៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំជូនគណៈកម្មការត្រួតពិនិត្យបេឡា និង អគ្គលេខាធិការ ។

ជំពូកទី ៣
គណៈកម្មការត្រួតពិនិត្យ

មាត្រា៨.- គណៈកម្មការត្រួតពិនិត្យមានសមាសភាពដូចខាងក្រោម ៖

១- តំណាងអគ្គលេខាធិការ	១ រូប	ប្រធាន
២- តំណាងអង្គភាពគ្រប់គ្រងបុគ្គលិក	១ រូប	អនុប្រធាន
៣- ប្រធានបេឡាសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ	១ រូប	សមាជិកអចិន្ត្រៃយ៍
៤- តំណាងអង្គភាពគ្រប់គ្រងហិរញ្ញវត្ថុ	១ រូប	សមាជិក
៥- តំណាងអ្នករាជការ	១ រូប	សមាជិក

គណៈកម្មការនេះតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធានស្ថាប័ន និងមានអាណត្តិ ៣ឆ្នាំ ។

មាត្រា៩.- គណៈកម្មការត្រួតពិនិត្យមានបេសកកម្មតម្រង់ទិស និង ត្រួតពិនិត្យដំណើរប្រព្រឹត្តទៅរបស់អង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ។

ក្នុងក្របខ័ណ្ឌបេសកកម្មនេះ គណៈកម្មការមានភារកិច្ចដូចតទៅ ៖

១- ពិនិត្យ និង សម្រេចលើគម្រោងចំណូល-ចំណាយថវិកាប្រចាំឆ្នាំរបស់បេឡាសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ

២- ពិនិត្យ និង សម្រេចពីទម្រង់បែបបទការងារនៃបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ

៣- កំណត់ និង សម្រេចចំនួនក្របខ័ណ្ឌបុគ្គលិកសម្រាប់បេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ

៤- សម្រេចអំពីកិច្ចសន្យាស្តីពីលទ្ធកម្មសាធារណៈនៃបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ

៥- កំណត់កម្មវិធី និង ផែនការវិនិយោគមូលនិធិនៃបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ

៦- ត្រួតពិនិត្យ និង វាយតម្លៃនូវការចំណាយបន្ទាប់បន្សំតាមការកំណត់

៧- ពិនិត្យ និង សម្រេចលើរបាយការណ៍ប្រចាំឆ្នាំស្តីពីការគ្រប់គ្រងចំណូល និង ចំណាយមូលនិធិរបស់បេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ។

រាល់ការសម្រេចរបស់គណៈកម្មការត្រួតពិនិត្យ ត្រូវបញ្ជូនតាមឋានានុក្រមទៅប្រធានស្ថាប័នរបស់ខ្លួន ដើម្បីសម្រេចជាចុងក្រោយ ។

មាត្រា១០.- សមាជិកគណៈកម្មការត្រួតពិនិត្យ ត្រូវបានជ្រើសរើសក្នុងចំណោមអ្នករាជការដែលសកម្មមានអតីតភាពការងារយ៉ាងតិច ៥ ឆ្នាំ មានបទពិសោធន៍ការងារ មានសមត្ថភាពក្នុងវិស័យគ្រប់គ្រង វិស័យសេដ្ឋកិច្ច វិស័យសង្គមកិច្ច ឬ វិស័យនីតិសាស្ត្រ ។

សមាជិកគណៈកម្មការត្រួតពិនិត្យជាតំណាងអ្នករាជការត្រូវជ្រើសរើសដោយការបោះឆ្នោត ដែលរៀបចំឡើងដោយអគ្គលេខាធិការដ្ឋាន។

គណៈកម្មការត្រួតពិនិត្យត្រូវបើកអង្គប្រជុំយ៉ាងតិច ១ដង ក្នុងរយៈពេល ៣ខែ ។ ទោះជាមានការកំណត់ដូច្នេះក្តី គណៈកម្មការត្រួតពិនិត្យអាចបើកអង្គប្រជុំបានគ្រប់ពេលអាស្រ័យដោយមានការចាំបាច់ ឬ តាមការអញ្ជើញរបស់ប្រធាន ឬ តាមសេចក្តីស្នើពីសមាជិកលើសពី ៥០ % ។

កិច្ចប្រជុំរបស់គណៈកម្មការត្រួតពិនិត្យ អាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានសមាជិកលើសពី ៥០% ។ សមាជិកគណៈកម្មការ មិនអាចឱ្យគេជំនួសបានទេ ។ ករណីកូរ៉ុមមិនគ្រប់ អង្គប្រជុំត្រូវលើកទៅ ១៥ថ្ងៃក្រោយ ដើម្បីពិភាក្សារបៀបវារៈដដែល ។ ការប្រជុំលើកក្រោយនេះមិនចាំបាច់តម្រូវឱ្យមានកូរ៉ុមគ្រប់ឡើយ ហើយរាល់ការសម្រេចនៃការប្រជុំទុកជាបានការ ។

ជំពូកទី ៤
ការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា១១.- អង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ អនុវត្តការងារគណនេយ្យស្របតាមគោលការណ៍គណនេយ្យសាធារណៈ និង បែបបទនានាដែលកំណត់ដោយប្រធានស្ថាប័ននីមួយៗ ។

ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំដដែល ។

របាយការណ៍គ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវដាក់ជូនប្រធានស្ថាប័ននីមួយៗសម្រេចក្នុងអំឡុង ១៥ ថ្ងៃ យ៉ាងយូរ បន្ទាប់ពីការសម្រេចរបស់គណៈកម្មការត្រួតពិនិត្យ ។

មាត្រា១២.- រៀងរាល់ឆ្នាំ នៅដើមខែតុលា គណៈកម្មការត្រួតពិនិត្យត្រូវផ្តល់ការយល់ព្រមលើកម្មវិធីអភិវឌ្ឍន៍ និងគម្រោងថវិកាប្រចាំឆ្នាំរបស់អង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ តាមសេចក្តីស្នើរបស់ប្រធាន ហើយបញ្ជូនគម្រោងនេះ ដើម្បីសុំការយល់ព្រមពីប្រធានស្ថាប័ននីមួយៗ ។

មាត្រា១៣.- ធនធានបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ បានមកពី :

- វិភាគទានចំនួន ៧% នៃប្រាក់បៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់ផ្សេងៗរបស់អ្នករាជការ
- ភាគទានចំនួន ៦% នៃប្រាក់បៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់ផ្សេងៗរបស់អ្នករាជការ
- អំណោយមានបណ្តាំដោយសប្បុរសជននានា និង អំណោយពីប្រភពផ្សេងៗ
- ការប្រាក់ និង ប្រាក់ចំណេញដែលបានមកពីថវិកាវិនិយោគរបស់បេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ។

មាត្រា១៤.- ការចំណាយរបស់បេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ មានដូចខាងក្រោម :

- ប្រាក់សោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ
- ប្រាក់ឧបត្ថម្ភមរណភាពនៃនិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ
- ប្រាក់វិភាជន៍គ្រួសារប្រចាំខែនៃសពនិវត្តជន និង ជនបាត់បង់វិជ្ជាជីវៈ
- ប្រាក់ឧបត្ថម្ភពេលបុណ្យចូលឆ្នាំខ្មែរ និង ពេលបុណ្យភ្ជុំបិណ្ឌ
- ចំណាយបន្ទាប់បន្សំសម្រាប់ការងាររដ្ឋបាល
- ចំណាយលើការវិនិយោគ ។

ជំពូកទី ៥
របបសោធននិវត្តន៍

មាត្រា១៥.- អ្នករាជការទាំងពីរភេទអាចទទួលរបបសោធននិវត្តន៍ប្រចាំខែបាន លុះត្រាតែបំពេញតាមល័ក្ខខ័ណ្ឌ ដូចបានចែងក្នុងជំពូកទី ៩ ស្តីពីការចូលនិវត្តន៍នៃច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា១៦.- ប្រាក់សោធននិវត្តន៍ប្រចាំខែរបស់និវត្តជនម្នាក់ៗមានប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់ផ្សេងៗ ។

ប្រាក់បៀវត្សមូលដ្ឋានមានចែងក្នុងមាត្រា ១៧ និង មាត្រា ១៨ នៃសេចក្តីសម្រេចនេះ និង ប្រាក់បំណាច់ផ្សេងៗត្រូវកំណត់ត្រឹម ៨០% នៃប្រាក់បំណាច់ផ្សេងៗចុងក្រោយ ។

ចំពោះប្រាក់ឧបត្ថម្ភកូនអាចផ្តល់ជូនអាយុក្រោម ១៨ឆ្នាំ និង ចាប់ពីអាយុ ១៨ឆ្នាំ ដល់ ២១ឆ្នាំ ត្រូវមានលិខិតបញ្ជាក់ពីគ្រឹះស្ថានសិក្សា ។

មាត្រា១៧.- និវត្តជនត្រូវទទួលបានប្រាក់សោធននិវត្តន៍អតីតភាពស្មើនឹង ៨០% នៃប្រាក់បៀវត្សមូលដ្ឋានរបស់សាមីខ្លួនលុះត្រាតែបានបំពេញការងារយ៉ាងតិច ៣០ ឆ្នាំ ។

ប្រាក់សោធននិវត្តន៍អតីតភាពនេះត្រូវអនុវត្តតាមករណីដូចខាងក្រោម :

- អ្នករាជការដល់អាយុចូលនិវត្តន៍ និង មានអតីតភាពការងារ ៣០ ឆ្នាំ យ៉ាងតិច
- អ្នករាជការដែលមានអតីតភាពការងារ ៣០ឆ្នាំ ឡើងទៅ ហើយបានស្ម័គ្រចិត្តសុំចូលនិវត្តន៍មុនអាយុចូលនិវត្តន៍ ។

ចំពោះអ្នករាជការដែលមានអតីតភាពការងារគ្រប់ ៣០ ឆ្នាំឡើងទៅ មិនត្រូវកាត់ប្រាក់សម្រាប់ចូលនិវត្តន៍ទៀតឡើយ ។

មាត្រា១៨.- និវត្តជនត្រូវទទួលបានប្រាក់សោធនសមាមាត្រ គឺប្រាក់សោធននិវត្តន៍អប្បបរមាស្មើនឹង ៦០% នៃបៀវត្សមូលដ្ឋានរបស់សាមីខ្លួន លុះត្រាតែបានបំពេញការងារក្នុងចន្លោះពី ២០ ឆ្នាំ ដល់ក្រោម ៣០ ឆ្នាំ ។ បើនិវត្តជនមានអតីតភាពការងារលើសពី ២០ឆ្នាំឡើងទៅ ត្រូវបានទទួលប្រាក់សមាមាត្របន្ថែម ១%ក្នុង ៦ ខែ លើបៀវត្សមូលដ្ឋានរបស់សាមីខ្លួនទៀត ។ ប្រាក់សមាមាត្រនេះ គិតតាមករណី ២យ៉ាងដូចខាងក្រោម :

១- មិនត្រូវខ្ពស់ជាងប្រាក់សោធននិវត្តន៍អតីតភាព ៨០% ឡើយ

២- មិនត្រូវទាបជាងប្រាក់បៀវត្សមូលដ្ឋានអប្បបរមាប្រចាំខែនៃឋានន្តរសក្តិថ្នាក់ដំបូងរបស់សាមីខ្លួនឡើយ ។

មាត្រា១៩.- និវត្តជនដូចមានចែងក្នុងមាត្រា១៧ និង មាត្រា១៨នៃសេចក្តីសម្រេចនេះត្រូវបានទទួលប្រាក់ឧបត្ថម្ភម្តងគត់នៅគ្រាដំបូងនៃការចូលនិវត្តន៍ ដែលមានទឹកប្រាក់ស្មើនឹងបៀវត្សប្រចាំខែចុងក្រោយគុណ នឹង ៨ ។ ប្រាក់ឧបត្ថម្ភនេះជាបន្ទុករបស់រដ្ឋ ។

មាត្រា២០.- អ្នករាជការដែលដល់អាយុចូលនិវត្តន៍ ប៉ុន្តែមានអតីតភាពការងារតិចជាង ២០ឆ្នាំ មិនត្រូវផ្តល់ប្រាក់សោធននិវត្តន៍ឡើយ ។ក្នុងករណីនេះ រដ្ឋត្រូវផ្តល់ប្រាក់ឧបត្ថម្ភម្តងគត់ដោយគណនាតាមរូបមន្តដូចខាងក្រោម :

- អតីតភាពការងារចាប់ពី ៣ឆ្នាំចុះ ត្រូវទទួលប្រាក់ឧបត្ថម្ភស្មើនឹងបៀវត្សប្រចាំខែចុងក្រោយរបស់សាមីខ្លួនគុណនឹង៥ ព្រមទាំងបានទទួលប្រាក់សោធននិវត្តន៍ដែលបានកាត់ទុកក្នុងបេឡាផងដែរ ។
- អតីតភាពការងារលើសពី៣ ដល់៥ឆ្នាំ ត្រូវទទួលប្រាក់ឧបត្ថម្ភស្មើនឹងបៀវត្សប្រចាំខែចុងក្រោយរបស់សាមីខ្លួនគុណនឹង ១០ ព្រមទាំងបានទទួលប្រាក់សោធននិវត្តន៍ដែលបានកាត់ទុកក្នុងបេឡាផងដែរ ។
- អតីតភាពការងារលើសពី៥ឆ្នាំដល់ក្រោម ២០ឆ្នាំ ត្រូវទទួលប្រាក់ឧបត្ថម្ភបន្ថែមស្មើនឹងបៀវត្សប្រចាំខែចុងក្រោយគុណនឹង ១០ ព្រមទាំងប្រាក់សមាមាត្របន្ថែមស្មើនឹងបៀវត្សប្រចាំខែចុងក្រោយរបស់សាមីខ្លួន ១ខែ សម្រាប់ ១ឆ្នាំ (ប៉ុន្តែប្រាក់សមាមាត្របន្ថែមនេះ មិនត្រូវលើសពីបៀវត្សប្រចាំខែចុងក្រោយរបស់សាមីខ្លួនគុណនឹង ១៤ ទេ) និង ទទួលប្រាក់សោធននិវត្តន៍ដែលបានកាត់ទុកក្នុងបេឡាផងដែរ ។

ជំពូកទី៦
របបសោធនបាត់បង់សម្បទាវិជ្ជាជីវៈ

មាត្រា២១.- អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ ហើយមានអតីតភាពការងារចាប់ពី ២០ឆ្នាំ រហូតដល់ក្រោម ៣០ឆ្នាំ ហើយពុំគ្រប់អាយុចូលនិវត្តន៍ មានសិទ្ធិទទួលប្រាក់សោធននិវត្តន៍សមាមាត្រ និង ប្រាក់ឧបត្ថម្ភផ្សេងៗដូចមានចែងក្នុងមាត្រា ១៦ មាត្រា ១៨ និង មាត្រា១៩ នៃសេចក្តីសម្រេចរួមនេះ ។

មាត្រា២២.- អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ ហើយមានអតីតភាពការងារក្រោម ២០ឆ្នាំ ត្រូវបានទទួលប្រាក់ឧបត្ថម្ភម្តងគត់ដែលមានទឹកប្រាក់ស្មើនឹងបៀវត្សប្រចាំខែគុណនឹង ១០ ព្រមទាំងប្រាក់សោធននិវត្តន៍ដែលបានកាត់ទុកក្នុងបេឡាផងដែរ ។

ជំពូកទី៧
វិធីរាប់អតីតភាពការងារ

មាត្រា២៣.- របៀបគណនាអតីតភាពការងាររបស់អ្នករាជការ ត្រូវបានកំណត់ដូចខាងក្រោម ៖

រយៈពេលបម្រើការងាររួមនៃអ្នករាជការ គឺជារយៈពេលបម្រើការងារក្នុងក្របខ័ណ្ឌរដ្ឋគ្រប់របបសង្គម ។ ដោយឡែកចំពោះអ្នករាជការដែលធ្លាប់បានបម្រើការងាររដ្ឋមុនឆ្នាំ១៩៧៥ ហើយពុំបានបម្រើការងារក្នុងរបបប៉ុលពត ក៏ត្រូវបានគិតបន្ថែមរយៈពេលបម្រើការងារ ៣ឆ្នាំ ៨ ខែ និង ២០ថ្ងៃថែមទៀតដែរ ។

រយៈពេលបម្រើការងារនៃអ្នករាជការរួមមាន ៖

- រយៈពេលបម្រើការងាររដ្ឋនៅតាមក្រសួង ស្ថាប័ននានា គិតទាំងរយៈពេលកម្មសិក្សាផងដែរ
- រយៈពេលបណ្តុះបណ្តាលមុខវិជ្ជាជីវៈក្នុង ឬ ក្រៅប្រទេសក្នុងក្របខ័ណ្ឌរដ្ឋ
- រយៈពេលដែលរដ្ឋចាត់អោយទៅបម្រើការងារក្រៅប្រទេស
- រយៈពេលឃាត់ ឬ ឃុំខ្លួនតែក្រោយមករកឃើញថាគ្មានកំហុស
- រយៈពេលបម្រើការងារ ឬ ជាប់កាតព្វកិច្ចក្នុងក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ និង នគរបាលជាតិ
- រយៈពេលដែលទទួលតំណែងជាអ្នកនយោបាយ ឬ ស្ថិតក្រៅក្របខ័ណ្ឌដើម ។

មិនត្រូវចាត់ទុកជារយៈពេលបម្រើការងារគឺរយៈពេលត្រូវបានអនុញ្ញាតអោយឈប់ទំនេរដោយមិនទទួលប្រាក់បៀវត្ស ។

រយៈពេលបំពេញការងាររបស់អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈត្រូវគណនាដូចនិវត្តជនដែរ ។

ចំពោះរយៈពេលការងារចាប់ពី ១៦ថ្ងៃឡើងទៅ ត្រូវគិតបញ្ចូលថាស្មើនឹង១ខែ ហើយបើលើសពី៦ខែ ឡើងទៅត្រូវគិតបញ្ចូលថាស្មើនឹង ១ឆ្នាំ ។

ជំពូកទី៨
បទប្បញ្ញត្តិដោយឡែក

មាត្រា២៤.- និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈទទួលប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ ស្មើនឹង ៥០% នៃប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌរបស់អ្នករាជការក្នុងមុខតំណែង ។

មាត្រា២៥.- នៅពេលនិវត្តជនទទួលមរណភាពអង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវផ្តល់ប្រាក់ឧបត្ថម្ភមួយលើកស្មើនឹងប្រាក់សោធននិវត្តន៍ប្រចាំខែរបស់សាមីខ្លួនគុណនឹង ១២ ជូនគ្រួសារនៃសព និង ប្រាក់ ១.២០០.០០០៛ (មួយលានពីរសែនរៀលគត់) ដើម្បីធ្វើបុណ្យតាមប្រពៃណី ។ ដោយឡែកចំពោះភរិយានៃសពត្រូវបានបន្តទទួលប្រាក់ឧបត្ថម្ភប្រចាំខែរហូតដល់ពេលគាត់ស្លាប់ ឬ មានប្តីថ្មី ។ ចំណែកកូនរបស់សព ត្រូវទទួលប្រាក់ឧបត្ថម្ភប្រចាំខែ ដូចកូនសៃសពមន្ត្រីរាជការ រហូតដល់អាយុក្រោម ១៨ឆ្នាំ និងចាប់ពីអាយុ ១៨ឆ្នាំ ដល់ ២១ឆ្នាំ ដែលមានលិខិតបញ្ជាក់ពីគ្រឹះស្ថានសិក្សា ។

ក្នុងករណីសពពុំមានឪពុកម្តាយ សហព័ទ្ធ ឬ សាច់សារលោហិត ប្រាក់ឧបត្ថម្ភគ្រួសារសពចំនួន ១២ខែដែលចែងក្នុងវាក្យខ័ណ្ឌខាងលើ និង ប្រាក់ឧបត្ថម្ភចំនួន ១.២០០.០០០ ៛ (មួយលានពីរសែនរៀលគត់) ត្រូវប្រើប្រាស់ដោយអង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ដើម្បីធ្វើបុណ្យតាមប្រពៃណី ។

អ្នករាជការដែលទទួលប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ នៅពេលទទួលមរណភាពត្រូវទទួលប្រាក់ឧបត្ថម្ភផ្សេងៗដូចមន្ត្រីរាជការដែលដាក់ឱ្យចូលនិវត្តន៍ ហើយគ្រួសារសពត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចគ្រួសារសពជានិវត្តជនដែរ ។

ក្នុងករណីមានបណ្តាំរបស់សពអង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវអនុវត្តតាមបណ្តាំ ។

មាត្រា២៦.- ចំពោះគ្រួសារសពអ្នករាជការ ត្រូវបានទទួលបើកប្រាក់សោធនិវត្តន៍ដែលបានកាត់ទុកក្នុងបេឡា ។

មាត្រា២៧.- អ្នករាជការនៃក្រុមនីតិប្បញ្ញត្តិដែលកំពុងទទួលតំណែងជាអ្នកនយោបាយ នៅពេលចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវបានបើកផ្តល់ប្រាក់សោធនប្រចាំខែ ។

មាត្រា២៨.- អ្នករាជការដែលសុំឈប់ពីការងារហើយត្រូវប្រធានស្ថាប័នយល់ព្រមឱ្យឈប់ អ្នករាជការនោះត្រូវបានទទួលប្រាក់សោធននិវត្តន៍ដែលបានកាត់ទុកក្នុងបេឡា ។

មាត្រា២៩.- អ្នករាជការដែលត្រូវបញ្ឈប់ពីការងារដូចមានចែងក្នុងមាត្រា ៥១ និង មាត្រា ៦៤ នៃច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ត្រូវបានទទួលតែប្រាក់សោធននិវត្តន៍ដែលបានកាត់ទុកក្នុងបេឡាប៉ុណ្ណោះ ។

ជំពូកទី៩

អវសានប្បញ្ញត្តិ

មាត្រា៣០.- អគ្គលេខាធិការព្រឹទ្ធសភា អគ្គលេខាធិការរដ្ឋសភា និង អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលអនុវត្តឱ្យមានប្រសិទ្ធភាពនូវសេចក្តីសម្រេចនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ ២០០៧

ប្រធានព្រឹទ្ធសភា	ប្រធានរដ្ឋសភា	ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
ជា ស៊ីម	ហេង សំរិន	ឯក សំអុល

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ដូចមាត្រា ៣០
- កាលប្បវត្តិ -ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្រែក្លាយសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

* * * * * *

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤ /១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧ /៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣ ស្តីពីការប្រែក្លាយមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទៅជាសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០០៧

ស ម្រេ ច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សរសេរកាត់ "ស.ភ.ន.វ.ស" ត្រូវបានសម្រេចឱ្យទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស របស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ២.-

ស.ភ.ន.វ.ស ជានីតិបុគ្គល និងមានស្វ័យភាពហិរញ្ញវត្ថុ ។

ស.ភ.ន.វ.ស មានអាស័យដ្ឋាននៅមហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ។

មាត្រា ៣.-

ស.ភ.ន.វ.ស មានភារកិច្ចជាអាទិ៍ ដូចតទៅ ÷

- បណ្តុះបណ្តាលអ្នកឯកទេស រយៈពេលខ្លី និងឧត្តមសិក្សាគ្រប់កម្រិត ស្របតាមបេសកកម្មរបស់ ស.ភ.ន.វ.ស ធ្វើវិក្រឹតការអ្នកបច្ចេកទេស បង្កើនទាំងបរិមាណ និងគុណភាព ស្របតាមសំណូមពរនៃសេចក្តីត្រូវការ ទូទាំងព្រះរាជាណាចក្រកម្ពុជានិងផ្សព្វផ្សាយចំណេះដឹងតាមរយៈរៀបចំបើកសិក្ខាសាលា សន្និសីទផ្សេងៗតាមសំណូមពររបស់សង្គម
- បង្កើនសមត្ថភាពមុខជំនាញបច្ចេកទេសដល់គ្រូបង្រៀន សាស្ត្រាចារ្យ សម្រាប់ ស.ភ.ន.វ.ស
- រៀបចំកម្មវិធីសិក្សា ឱ្យស្របតាមតម្រូវការទីផ្សារការងារ និងស្តង់ដាអន្តរជាតិ
- សិក្សាស្រាវជ្រាវខ្លឹមសារសិក្សា វិធីសាស្ត្របង្រៀន និងចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រ ជាភាសាជាតិ និងភាសាបរទេស ឱ្យបានសមស្របសម្រាប់ប្រើប្រាស់
- រៀបចំ និងដំណើរការជ្រើសរើសនិស្សិតឱ្យចូលរៀន ប្រឡងចេញ និងស្វ័យវាយតម្លៃការសិក្សា ឱ្យបានត្រឹមត្រូវតាមគោលការណ៍ និងប្រកបដោយតម្លាភាព
- ធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រក្នុងឯកទេសរបស់ ស.ភ.ន.វ.ស
- កសាងផែនការអភិវឌ្ឍន៍សម្រាប់ ស.ភ.ន.វ.ស
- គ្រប់គ្រងមន្ត្រីរាជការ សាស្ត្រាចារ្យ និយោជិត កម្មករ និស្សិត និងទ្រព្យសម្បត្តិរបស់ ស.ភ.ន.វ.ស
- ធ្វើសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សា អង្គការជាតិ-អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័ននានាក្នុងគោលបំណងធ្វើឱ្យកាន់តែល្អប្រសើរ នូវការសិក្សា ការបង្រៀន និងការស្រាវជ្រាវ

ជំពូកទី ២
រដ្ឋបាល និង ការគ្រប់គ្រង

ផ្នែកទី ១
ក្រុមប្រឹក្សាភិបាល

មាត្រា ៤..

ស.ភ.ន.ទ.ស ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានសិទ្ធិទូលំទូលាយ ដើម្បីចាត់ចែងការងារក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវមានការយល់ព្រម ពីក្រសួងអាណាព្យាបាលទាំងពីរ ។

មាត្រា ៥..

៥.១.. ក្រុមប្រឹក្សាភិបាលមានសមាជិក ០៥ (ប្រាំ) រូប ដែលមានសមាសភាពដូចតទៅ ÷

- តំណាងក្រសួងអប់រំ យុវជន និងកីឡា ១ រូប ជាប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប ជាសមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ រូប ជាសមាជិក
- សាកលវិទ្យាធិការ ស.ភ.ន.ទ.ស ១ រូប ជាសមាជិកស្វ័យប្រវត្តិ
- តំណាងបុគ្គលិក ស.ភ.ន.ទ.ស ១រូប ជាសមាជិកស្វ័យប្រវត្តិ

៥.២.. តំណាងបុគ្គលិកនៃ ស.ភ.ន.ទ.ស ត្រូវជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោមបុគ្គលិក ស.ភ.ន.ទ.ស ។

៥.៣.. ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវតែងតាំងដោយអនុក្រឹត្យ សម្រាប់អាណត្តិ ៣ (បី) ឆ្នាំ ។ អាណត្តិនេះ អាចបន្តជាថ្មីទៀតបាន និងអាចបញ្ចប់បានគ្រប់ពេលវេលា ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួង ឬស្ថាប័នដែលខ្លួនតំណាងឱ្យ ។

មាត្រា ៦..

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីសកម្ម ដែលធ្លាប់បានបម្រើការងារយ៉ាងតិច៥(ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានបទពិសោធន៍គ្រប់គ្រាន់ និងមានចំណេះដឹងខ្ពស់ ក្នុងវិស័យអប់រំឧត្តមសិក្សា សេដ្ឋកិច្ច ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មកម្រិតធ្ងន់ ពីតុលាការឡើយ ។

មាត្រា ៧..

៧.១.. ប្រធានក្រុមប្រឹក្សាភិបាល មានតួនាទីកោះប្រជុំ និងកំណត់របៀបវារៈនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។

៧.២.. ក្រុមប្រឹក្សាភិបាល អាចអញ្ជើញឥស្សរជន នៅក្រៅក្រុមប្រឹក្សាភិបាល ដែលមានបទពិសោធន៍ លើការងារឧត្តមសិក្សា ឬតំណាងដៃគូអភិវឌ្ឍន៍ចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។ ឥស្សរជនទាំងនោះ មានសិទ្ធិផ្តល់យោបល់

តែពុំមានសិទ្ធិ បោះឆ្នោតអនុម័តឡើយ ។

មាត្រា ៨..

ក្រុមប្រឹក្សាភិបាល មានបេសកកម្មដឹកនាំតម្រង់ទិស និងធ្វើការត្រួតពិនិត្យលើដំណើរការរបស់ ស.ភ.ន.ទ.ស ។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាល ត្រូវ ៖

- ពិនិត្យ និងសម្រេចលើផែនការអភិវឌ្ឍន៍នៃ ស.ភ.ន.ទ.ស ស្របតាមទិសដៅកំណត់ របស់រាជរដ្ឋាភិបាល
- ពិនិត្យ និងសម្រេចលើចំណូល និងចំណាយជាប្រចាំ ព្រមទាំងទុនក្នុងថវិកាប្រចាំឆ្នាំ របស់ ស.ភ.ន.ទ.ស
- ពិនិត្យ និងសម្រេចលើរបាយការណ៍គ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ ការរៀបចំរចនាសម្ព័ន្ធ និងភារកិច្ចទូទៅរបស់ ស.ភ.ន.ទ.ស
- កំណត់ បែបបទ នៃការជ្រើសរើស ការដំឡើងឋានន្តរស័ក្តិ ការផ្តល់លាភការដល់បុគ្គលិក ស.ភ.ន.ទ.ស ដោយមិនប៉ះពាល់ ដល់បទប្បញ្ញត្តិនៃច្បាប់ ឬបទបញ្ជាផ្ទៃក្នុង ដែលអនុវត្តចំពោះ មន្ត្រីមុខងារសាធារណៈ
- សម្រេច លើក្របខ័ណ្ឌចំនួនបុគ្គលិក ដែលអនុញ្ញាតសម្រាប់ ស.ភ.ន.ទ.ស
- សម្រេច លើកិច្ចសន្យា ស្តីពីលទ្ធកម្ម
- កំណត់ បទបញ្ជាផ្ទៃក្នុងនៃ ស.ភ.ន.ទ.ស
- វាយតម្លៃ តាមចន្លោះពេលទៀងទាត់ លើកម្រិតលទ្ធផលសម្រេចបាន តាមគោលដៅកំណត់ ដោយ ស.ភ.ន.ទ.ស ហើយកំណត់វិធានការកែតម្រូវ ដើម្បីអនុវត្ត ។

មាត្រា ៩..

៩.១.. លាភការរបស់សមាជិកនៃក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់សាកលវិទ្យាធិការ ត្រូវសម្រេចជា គោលការណ៍ និងកំណត់ដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

៩.២.. លាភការ ឬប្រាក់បំណាច់ខាងលើ អាចត្រូវបញ្ឈប់ចំពោះសមាជិកណាម្នាក់ នៃក្រុមប្រឹក្សាភិបាល ដែលមិនមកបំពេញភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ តាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាភិបាល ។

មាត្រា ១០..

១០.១.. ក្រុមប្រឹក្សាភិបាលនៃ ស.ភ.ន.ទ.ស ត្រូវធ្វើការប្រជុំ យ៉ាងតិចមួយត្រីមាសម្តង តាមការអញ្ជើញរបស់ប្រធាន ឬ តាមការស្នើរបស់សមាជិកចំនួន២/៣ (ពីរភាគបី)ឡើងទៅ ឬ តាមការស្នើសុំពីសាកលវិទ្យាធិការ នៃ ស.ភ.ន.ទ.ស ។ ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកម្នាក់ដែលមានវ័យច្រើនជាងគេក្នុងចំណោមសមាជិករបស់ក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ តែមិនអាចជ្រើសរើស សមាជិកស្វ័យប្រវត្តិទេ។ ប្រធានអង្គប្រជុំ ត្រូវជ្រើសរើសលេខាធិការនៃអង្គប្រជុំ ១(មួយ)រូប ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល ។ លេខាធិការនេះ គ្មានសិទ្ធិបញ្ចេញមតិ និងបោះឆ្នោតអនុម័តទេ ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវចូលរួមប្រជុំ ក្នុងសម័យប្រជុំ របស់ក្រុមប្រឹក្សាភិបាល ។ របៀបវារៈ និងឯកសារនានា ត្រូវផ្ញើជូន គ្រប់សមាជិក នៃក្រុមប្រឹក្សាភិបាល និង

គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធដែលមានចែងក្នុងអនុក្រឹត្យនេះ យ៉ាងតិច ១០ (ដប់) ថ្ងៃ មុនថ្ងៃប្រជុំ ។

១០.២.. ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចនឹងយកជាការបាន លុះត្រាតែមានសមាជិកវត្តមាន ចំនួនលើសពី ៥០ (ហាសិប) ភាគរយ នៃសមាជិកទាំងអស់ ។ សមាជិកអវត្តមាន គ្មានសិទ្ធិបញ្ជូនតំណាង ឱ្យមកប្រជុំជំនួសខ្លួនបានឡើយ ។ បើសិនសំឡេងកូរ៉ុមមិនគ្រប់ចំនួន ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំ ម្តងទៀតយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះ មិនចាំបាច់តម្រូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈ នៃការអញ្ជើញប្រជុំ លើកទីមួយ ។ សមាជិកវត្តមាន ត្រូវចុះហត្ថលេខា លើបញ្ជីវត្តមានមួយ ដែលត្រូវភ្ជាប់ជាមួយកំណត់ហេតុប្រជុំ ។ សេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាល អាចយកជាការបាន លុះត្រាតែមានការអនុម័ត ដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានអង្គប្រជុំ ចាត់ទុកជាឧត្តមានុភាព ។

១០.៣.. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំ ដែលត្រូវចុះហត្ថលេខា ដោយប្រធានអង្គប្រជុំ និងលេខាធិការអង្គប្រជុំ នឹងតម្កល់ទុកនៅ **ស.ភ.ឧ.ទ.ស** ។ កំណត់ហេតុនេះ ត្រូវស្រង់អត្ថន័យនៃការពិភាក្សាឱ្យបានច្បាស់លាស់ និងត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងផ្ញើជូនក្រសួង ពាក់ព័ន្ធយ៉ាងយូរ ១០(ដប់) ថ្ងៃ ក្រោយពេលប្រជុំ ។

១០.៤.. **ស.ភ.ឧ.ទ.ស** ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវឯកសារដូចតទៅ ៖

- កំណត់ហេតុនៃការប្រជុំ របស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍន៍របស់ **ស.ភ.ឧ.ទ.ស**
- គម្រោងថវិកាប្រចាំឆ្នាំ
- របាយការណ៍គ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ។

១០.៥.. ឯកសារទាំងនេះ ត្រូវបញ្ជូនទៅអ្នកដែលត្រូវទទួល ក្នុងរយៈពេលមិនឱ្យហួសពី ១៥ (ដប់ប្រាំ) ថ្ងៃឡើយ ។

ជំពូកទី ២

អង្គការប្រតិបត្តិរបស់ ស.ភ.ឧ.ទ.ស

មាត្រា ១១..

ស.ភ.ឧ.ទ.ស ត្រូវគ្រប់គ្រងដោយសាកលវិទ្យាធិការមួយរូប ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ដោយមានការផ្តល់យោបល់ពីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។ សាកលវិទ្យាធិការ មានតួនាទីជានាយកប្រតិបត្តិ ។

មាត្រា ១២..

១២.១.. សាកលវិទ្យាធិការនៃ **ស.ភ.ឧ.ទ.ស** មានសិទ្ធិពេញលេញដើម្បីគ្រប់គ្រង និងអនុវត្តការងារ ដែលមានចែងក្នុងច្បាប់ និងអនុក្រឹត្យនេះ លើកលែងតែកិច្ចការ ដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល ។

សាកលវិទ្យាធិការមានភារកិច្ច ៖

ฑl

- រៀបចំការងារអង្គប្រជុំ របស់ក្រុមប្រឹក្សាភិបាល
- រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍**ស.ភ.ន.ទ.ស**ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច
- ទទួលបន្ទុកអនុវត្ត សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល និងដាក់ឱ្យដំណើរការនូវគោលនយោបាយ ដែលកំណត់ដោយក្រុមប្រឹក្សាភិបាលនេះ
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់ **ស.ភ.ន.ទ.ស** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល ពិនិត្យ និងសម្រេច
- ធ្វើរបាយការណ៍ស្តីពីគណនីគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ និងរាល់សកម្មភាពផ្សេងទៀត ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច
- ធ្វើការបញ្ជាក់ ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- បំពេញរាល់មុខតំណែងរបស់ **ស.ភ.ន.ទ.ស** ក្នុងកម្រិតក្របខ័ណ្ឌចំនួនបុគ្គលិក ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពតាមវិធានស្តីពីការគ្រប់គ្រងបុគ្គលិក
- បំពេញតួនាទី តាមឋានានុក្រម ចំពោះបុគ្គលិកទាំងមូលរបស់ **ស.ភ.ន.ទ.ស**
- សម្រេចលើការងារលទ្ធកម្ម និងចុះហត្ថលេខាលើអនុសញ្ញាផ្សេងៗ ដោយអនុលោមតាមសេចក្តីសម្រេច របស់ក្រុមប្រឹក្សាភិបាល ស្តីពីការបែងចែកសិទ្ធិអំណាច និងតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិដទៃទៀត ស្តីពីបញ្ហានេះ
- ជារួមគឺ បំពេញរាល់មុខងាររដ្ឋបាល និងគ្រប់គ្រងការងារទាំងឡាយ ដែលកំណត់ដោយបទបញ្ជាផ្ទៃក្នុង របស់ **ស.ភ.ន.ទ.ស** និងតាមសេចក្តីសម្រេច របស់ក្រុមប្រឹក្សាភិបាល ។

១២.២.. សាកលវិទ្យាធិការ នៃ **ស.ភ.ន.ទ.ស** ជាតំណាងរបស់ **ស.ភ.ន.ទ.ស** ក្នុងទំនាក់ទំនងជាមួយតតិយជន ។

១២.៣.. សាកលវិទ្យាធិការ នៃ **ស.ភ.ន.ទ.ស** ត្រូវស្នើទៅក្រសួងអាណាព្យាបាលបច្ចេកទេស សុំតែងតាំងសាកលវិទ្យាធិការរងមួយរូប ឬច្រើនរូប ជាជំនួយការតាមការចាំបាច់ ដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល ។

ជំពូកទី ៣
បុគ្គលិករបស់ ស.ភ.ន.ទ.ស

មាត្រា ១៣..

១៣.១.. បុគ្គលិកអចិន្ត្រៃយ៍របស់ **ស.ភ.ន.ទ.ស** រួមមាន មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ មកពីក្រសួងអប់រំ យុវជន និងកីឡា ឬជ្រើសរើសតាមសំណើរបស់សាកលវិទ្យាធិការនៃ **ស.ភ.ន.ទ.ស** ។ សម្រាប់មន្ត្រីទាំងនេះ ត្រូវបានរក្សាទុក នូវក្របខ័ណ្ឌ ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗ ដែលបានកំណត់ដោយមុខងារសាធារណៈ ពីអង្គភាពដើមរបស់ខ្លួន ។

១៣.២.. **ស.ភ.ន.ទ.ស** អាចជ្រើសរើសភ្នាក់ងារជាប់កិច្ចសន្យា ជំនួយការ និងបុគ្គលិកអណ្តែត ។ ភ្នាក់ងារទាំងនេះ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃបទបញ្ជាផ្ទៃក្នុង និងតាមសេចក្តីសម្រេច របស់ក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់

ស្តីពីការងារ។

១៣.៣.. បុគ្គលិកនៃ ស.ភ.ឧ.ទ.ស ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង នៃបទបញ្ជាស្តីពីបុគ្គលិក ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាល កំណត់ប្រាក់កម្រៃលើកទឹកចិត្ត ចំពោះបុគ្គលិក តាមបែបបទ នៃការទូទាត់ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង ។

ជំពូកទី ៤
ទ្រព្យសម្បត្តិរបស់ ស.ភ.ឧ.ទ.ស

មាត្រា ១៤..

១៤.១.. ស.ភ.ឧ.ទ.ស ទទួលដើមទុនដំបូង ពីរដ្ឋនូវផ្ទៃដីទំហំ ២៣.៦៣៥ម² ដែលមានទីតាំងស្ថិតនៅមហាវិថីព្រះមុនីវង្ស សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ។

១៤.២.. ក្រៅពីអចលនទ្រព្យខាងលើ ស.ភ.ឧ.ទ.ស មានចលនទ្រព្យ និង អចលនទ្រព្យដែលកំពុងប្រើប្រាស់ពេលបច្ចុប្បន្ន ។

១៤.៣.. អចលនទ្រព្យ និង ចលនទ្រព្យ របស់ ស.ភ.ឧ.ទ.ស មានចែងលំអិតក្នុងបញ្ជីសារពើភណ្ឌ ។

១៤.៤.. ស.ភ.ឧ.ទ.ស មានចលនទ្រព្យ និងអចលនទ្រព្យចាំបាច់សម្រាប់ដំណើរការរបស់ខ្លួនតាមរយៈការទិញ លក់ ជួល ការសាងសង់ថ្មី និងការទទួលអំណោយផ្សេងៗ។

ជំពូកទី ៥
ការគ្រប់គ្រងហិរញ្ញវត្ថុ និង គណនេយ្យរបស់ ស.ភ.ឧ.ទ.ស

មាត្រា ១៥..

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យ នៃ ស.ភ.ឧ.ទ.ស ត្រូវប្រព្រឹត្តទៅស្របតាមគោលការណ៍ នៃគណនេយ្យសាធារណៈ ដូចមានចែងក្នុងមាត្រា១២២ នៃអនុក្រឹត្យលេខ ៨២ អនក្រ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពី បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ឬកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការយល់ព្រម ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ១៦..

១៦.១.. សាកលវិទ្យាធិការ នៃ ស.ភ.ឧ.ទ.ស ជាអាណាប័កដើមខ្សែរបស់ ស.ភ.ឧ.ទ.ស និងមានភារកិច្ច ÷

- ពិនិត្យប្រាក់ និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ ។

១៦.២.. អាណាប័កដើមខ្សែ អាចផ្ទេរសិទ្ធិ ឱ្យអាណាប័កផ្ទេរសិទ្ធិ ឬអាចបង្កើតរដ្ឋទេយ្យចំណូល ឬបុរេប្រទាន បានដោយមានការព្រមព្រៀង ពីភ្នាក់ងារគណនេយ្យ ។

មាត្រា ១៧..

១៧.១.. ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុង របស់ **ស.គ.ន.ទ.ស** ក្រោមការទទួលខុសត្រូវផ្ទាល់ របស់ភ្នាក់ងារគណនេយ្យ ។ ភ្នាក់ងារគណនេយ្យនេះ ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ។ ភ្នាក់ងារគណនេយ្យនេះ ត្រូវទទួលខុសត្រូវចំពោះមុខសាកលវិទ្យាធិការនៃ **ស.គ.ន.ទ.ស** និងត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈ ជាអ្នកពិគ្រោះយោបល់ ។

១៧.២.. ភ្នាក់ងារគណនេយ្យមានភារកិច្ច ៖

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- រក្សាទុក និងចាត់ចែងប្រើប្រាស់មូលនិធិ និងធនធានរបស់ **ស.គ.ន.ទ.ស**
- រក្សាទុកលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ ។

១៧.៣.. ភ្នាក់ងារគណនេយ្យ អាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាជ្ញានុគារីរបស់ខ្លួន ។

មាត្រា ១៨..

១៨.១.. ប្រភពធនធានរបស់ **ស.គ.ន.ទ.ស** រួមមាន ៖

- ធនធានដំបូងដែលរដ្ឋផ្តល់ដល់ **ស.គ.ន.ទ.ស** នៅពេលបង្កើតដំបូង
- ឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធន ដែលមានចែងក្នុងថវិការដ្ឋ
- អំណោយ ជំនួយ និងអច្ច័យទាន ដែល **ស.គ.ន.ទ.ស** បានទទួល
- ប្រាក់ខ្ចីបុល ដោយ **ស.គ.ន.ទ.ស** ផ្ទាល់ និងប្រាក់ដែលរដ្ឋខ្ចីបុលឱ្យ **ស.គ.ន.ទ.ស**
- ផលការងារ និងកម្រៃនៃការផ្តល់សេវាផ្សេងៗ ដោយ **ស.គ.ន.ទ.ស**
- កម្រៃ នៃទ្រព្យសម្បត្តិ របស់ **ស.គ.ន.ទ.ស** និង ចំណូលនៃការលក់ទ្រព្យសម្បត្តិ ដែលបានទទួលការ-អនុញ្ញាតពីរាជរដ្ឋាភិបាល
- កម្រៃនៃទ្រព្យសម្បត្តិ ដែលបានប្រគល់ឱ្យ **ស.គ.ន.ទ.ស** ។

១៨.២.. ចំណូលចំណាយ ជាប្រចាំព្រមទាំងមូលធន របស់ **ស.គ.ន.ទ.ស** ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំ របស់ **ស.គ.ន.ទ.ស** ។ ក្រុមប្រឹក្សាភិបាលរបស់ **ស.គ.ន.ទ.ស** ត្រូវកំណត់អំពីបែបបទ នៃការរៀបចំការចាត់ចែង និងការ-អនុវត្តថវិកា ។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ដែលទាក់ទងដល់ទម្រង់បែបបទ នៃការរៀបចំការចាត់ចែង និងអនុវត្តថវិកាត្រូវមានការយល់ព្រម ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៨.៣.. អាណាប័កដើមខ្សែនៃ **ស.គ.ន.ទ.ស** ត្រូវរៀបចំផែនការយុទ្ធសាស្ត្រ ដោយមានបញ្ចូលទាំងគម្រោងថវិកាលំអិតសម្រាប់ឆ្នាំនីមួយៗ ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដែលត្រូវការសម្រេចយ៉ាងយូរត្រឹមថ្ងៃទី ៣០ ខែកញ្ញា នៃឆ្នាំនីមួយ ១ ។ ថវិកាត្រូវតែធ្វើឱ្យមានលំនឹង រវាងចំណូល និងចំណាយ ។

១៨.៤.. ក្នុងការរៀបចំថវិកាប្រចាំឆ្នាំសម្រាប់ **ស.គ.ន.ទ.ស** អាណាប័កដើមខ្សែត្រូវរាប់បញ្ចូលថវិកា ដែលឧបត្ថម្ភដោយរាជរដ្ឋាភិបាល ។ ថវិកាឧបត្ថម្ភនេះ ត្រូវផ្តល់ឱ្យ **ស.គ.ន.ទ.ស** ដោយអនុលោមតាមមាត្រា ៥១ និង ៥២ នៃ

ព្រះរាជក្រឹត្យលេខនស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តម-សិក្សា ។

មាត្រា ១៩..

១៩.១.. ការងារគណនេយ្យរបស់ **ស.ភ.ឧ.ទ.ស** រួមមាន ៖

- គណនេយ្យទូទៅ ត្រូវកាន់កាប់ជាគណនេយ្យទ្វេភាគ ដែលចែងអំពីប្រតិបត្តិការថវិកា រតនាគារ និងប្រតិបត្តិការ ដែលអនុវត្តជាមួយតតិយជន
- គណនេយ្យ អសង្ហារឹម រូបធាតុ និងគណនេយ្យតម្លៃ
- គណនេយ្យវិភាគ ប្រសិនបើជាការចាំបាច់ ។

គណនេយ្យរបស់ **ស.ភ.ឧ.ទ.ស** ត្រូវ ៖

១- ស្របតាមវិធាន ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

២- គោរពតាមប្លង់គណនេយ្យរបស់ **ស.ភ.ឧ.ទ.ស** ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ។
ប្លង់គណនេយ្យនេះ ត្រូវមានការយល់ព្រម ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៩.២.. គណនីហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ **ស.ភ.ឧ.ទ.ស** ត្រូវរៀបចំដោយភ្នាក់ងារគណនេយ្យ និងអាណាប័កដើមខ្សែ ដោយភ្ជាប់ជាមួយរបាយការណ៍ស្តីពីគណនីគ្រប់គ្រង និងគណនីហិរញ្ញវត្ថុ ដើម្បីជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចលើឯកសារទាំងនោះយ៉ាងយូរ ៣ (បី)ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ ។

មាត្រា ២០..

មូលនិធិរបស់ **ស.ភ.ឧ.ទ.ស** គឺជាមូលនិធិសាធារណៈ ដែលត្រូវដាក់ចូលក្នុងគណនីមួយ នៅរតនាគារជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិ ដែលត្រូវមានការយល់ព្រម ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ជំពូកទី ៦
របបសារពើពន្ធនៃ ស.ភ.ឧ.ទ.ស

មាត្រា ២១..

លើកលែងតែមានបដិប្បញ្ញត្តិ ដែលចែងដោយច្បាប់ **ស.ភ.ឧ.ទ.ស** ត្រូវស្ថិតនៅក្រោមនីតិរូប ចំពោះរបបសារពើពន្ធ ដូចដែលត្រូវបានអនុវត្តលើអង្គភាពនានារបស់រដ្ឋ ។

ជំពូកទី ៧
លទ្ធកម្មរបស់ ស.ភ.ឧ.ទ.ស

មាត្រា ២២..

ការសម្រេច ការអនុវត្ត និងការត្រួតពិនិត្យ លើលទ្ធកម្មរបស់ **ស.ភ.ឧ.ទ.ស** ត្រូវគ្រប់គ្រងតាមបទដ្ឋានគតិយុត្តទាំងឡាយជាធរមាន ពាក់ព័ន្ធនឹងបញ្ហានេះ ។

ៗ

ជំពូកទី ៣
អាណាព្យាបាល

ផ្នែកទី ១
អាណាព្យាបាលបច្ចេកទេស

មាត្រា ២៣..

២៣.១.. ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាល សាកលវិទ្យាធិការ នៃ **ស.ភ.ឧ.ទ.ស** ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍន៍ និងគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីសុំការយល់ព្រម ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ១ (មួយ) ខែ ចាប់ពីថ្ងៃដែលបានទទួលឯកសារ ត្រូវរៀបចំយោបល់របស់ខ្លួន ជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស មានពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារ ដែលបញ្ជូនដោយសាកលវិទ្យាធិការ ដើម្បីសម្រេចផ្តល់ការយល់ព្រម លើឯកសារទាំងនេះ ។

២៣.២.. លិខិតយល់ព្រមត្រូវចុះហត្ថលេខា ដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឬ តំណាង ហើយត្រូវផ្ញើជូនទៅសាកលវិទ្យាធិការ នៃ **ស.ភ.ឧ.ទ.ស** ដោយចម្លងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ សាកលវិទ្យាធិការ នៃ **ស.ភ.ឧ.ទ.ស** ត្រូវបញ្ជូនព័ត៌មាននេះ ទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណី ដែលរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍន៍ ឬគម្រោងថវិកាប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។ ប្រសិនបើរដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា ធ្វើការជំទាស់លើកម្មវិធីអភិវឌ្ឍន៍ ឬគម្រោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំ ការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សា និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ ។

កម្មវិធីអភិវឌ្ឍន៍នៃ **ស.ភ.ឧ.ទ.ស** និងថវិកាចំណាយជាមូលធន មិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយប្រធានស្ថាប័ន ឬអាណាព្យាបាលបច្ចេកទេស ។

ថវិកាចំណាយជាប្រចាំ អាចដាក់ឱ្យអនុវត្តត្រឹមលំនាំបំបែកជា ១២ (ដប់ពីរ) ប៉ុណ្ណោះ នៅពេលដែលមានការជំទាស់ពីប្រធានស្ថាប័ន ឬអាណាព្យាបាលបច្ចេកទេស ។

មាត្រា ២៤..

២៤.១.. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អាចមានយោបល់ជំទាស់លើឯកសារដែលត្រូវបានបញ្ជូន មកខ្លួនដូចមានចែងក្នុងមាត្រា១០ ខាងលើ ។ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មានរយៈពេល ១ (មួយ) ខែ សម្រាប់លើកឡើងការជំទាស់ទាំងអស់នេះ ។

២៤.២.. សាកលវិទ្យាធិការនៃ **ស.ភ.ឧ.ទ.ស** ត្រូវជូនព័ត៌មានទៅក្រុមប្រឹក្សាភិបាល នូវខ្លឹមសារនៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។ ក្រុមប្រឹក្សាភិបាល ត្រូវធ្វើការពិភាក្សាឱ្យបានឆាប់បំផុត លើការជំទាស់របស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ។ ប្រសិនបើក្រុមប្រឹក្សា-

ភិបាល សម្រេចពុំយកជាបានការនូវការជំទាស់ទាំងនេះ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវបញ្ជាក់ពីមូលហេតុហើយត្រូវជម្រាបជូនដំណឹងជាបន្ទាន់ស្តីពីបញ្ហានេះ ជាលាយលក្ខណ៍អក្សរ ដល់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ២៥.-

២៥.១.- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អាចលុប ឬផ្អាកទុកសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬសាកលវិទ្យាធិការ នៃ **ស.ភ.ន.ទ.ស** ក្នុងករណីដែលសេចក្តីសម្រេចនោះ ៖

- ផ្ទុយនឹងគោលដៅរបស់ **ស.ភ.ន.ទ.ស**
- ផ្ទុយនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- ផ្ទុយនឹងបែបបទនៃការប្រជុំដែលមានចែងក្នុងមាត្រា ១០ ។

២៥.២.- ការលុបចោល ឬការផ្អាកទុកទាំងនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដោយមានបញ្ជាក់ពីមូលហេតុ តាមគំនិតផ្ទាល់ខ្លួន ឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ ។ ការលុបចោល ឬការផ្អាក ទុកសេចក្តីសម្រេចនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់សាកលវិទ្យាធិការ នៃ **ស.ភ.ន.ទ.ស** ហើយសាកលវិទ្យាធិការត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាលក្នុងរយៈពេលដ៏ឆាប់បំផុត ។

មាត្រា ២៦.-

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អាចចាត់ឱ្យធ្វើអធិការកិច្ច ឬការត្រួតពិនិត្យការងាររបស់ **ស.ភ.ន.ទ.ស** ក្នុងករណីដែលយល់ថា ជាការចាំបាច់ស្របតាមល័ក្ខខ័ណ្ឌ និងបែបបទ ដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិ ដែលមានជាធរមាន ។

ជំពូកទី ២
អាណាព្យាបាលហិរញ្ញវត្ថុ

មាត្រា ២៧.-

២៧.១.- ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល សាកលវិទ្យាធិការនៃ **ស.ភ.ន.ទ.ស** ត្រូវធ្វើរបាយការណ៍ស្តីពីគណនីគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា ។ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មានរយៈពេល ១ (មួយ) ខែ គិតចាប់ថ្ងៃទទួលឯកសារ ដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃទទួលឯកសារ ដែលបញ្ជូនមកដោយសាកលវិទ្យាធិការ នៃ **ស.ភ.ន.ទ.ស** ដើម្បីផ្តល់ការយល់ព្រមលើឯកសារទាំងនេះ ។

២៧.២.- លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាងត្រូវផ្ញើទៅសាកលវិទ្យាធិការនៃ **ស.ភ.ន.ទ.ស** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។ សាកលវិទ្យាធិការ

ៗ។

នៃ ស.គ.ន.ទ.ស ត្រូវជូនព័ត៌មាននេះដល់ក្រុមប្រឹក្សាភិបាល យ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនបានឆ្លើយតបក្នុងរយៈពេលដូចបានកំណត់ខាងលើ របាយការណ៍ស្តីពីគណនីគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់រហ័សបំផុត ដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនេះ ។ របាយការណ៍ស្តីពីគណនីគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ មិនអាចត្រូវសម្រេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់ត្រូវបានលើកឡើង ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំត្រូវបានដោះស្រាយនៅឡើយនោះ ។

មាត្រា ២៨..

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬសាកលវិទ្យាធិការ ស.គ.ន.ទ.ស ដូចរៀបរាប់ខាងក្រោម ត្រូវដាក់សុំការអនុញ្ញាតជាមុនពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន ៖

- សេចក្តីសម្រេចស្តីពីការលក់ ឬ ការផ្ទេរសិទ្ធិអចលនទ្រព្យ
- សេចក្តីសម្រេចស្តីពីការលើកលែងឥណទេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់ នៃប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្តីសម្រេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសម្រាប់ការធានា ឬលិខិតស្រដៀងគ្នានេះ ។

មាត្រា ២៩..

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមួយរូបប្រចាំ ស.គ.ន.ទ.ស ។ មន្ត្រីនេះ មានភារកិច្ចធ្វើការត្រួតពិនិត្យជាមុន និងជាក្រោយលើ ស.គ.ន.ទ.ស ស្របតាមអនុក្រឹត្យលេខ៨១ អនក្រ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកា តាមក្រសួង អង្គភាពមូលដ្ឋាន តាមបណ្តាខេត្ត-ក្រុង និង តាមអង្គភាពសាធារណៈ ដែលមានលក្ខណៈរដ្ឋបាល ។

មាត្រា ៣០..

៣០.១.. ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែ នៃ ស.គ.ន.ទ.ស ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣០.២.. ការគ្រប់គ្រងរបស់ភ្នាក់ងារគណនេយ្យ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ភ្នាក់ងារគណនេយ្យកណ្តាលនៃរតនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ ។

៣០.៣.. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់អធិការកិច្ច ឬការត្រួតពិនិត្យ លើ ស.គ.ន.ទ.ស នៅពេលដែលយល់ថាចាំបាច់ស្របតាមល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធ និង បទប្បញ្ញត្តិ ដែលមានជាធរមាន ។

ៗ

ជំពូកទី ៥
អវសានប្បញ្ញត្តិ

មាត្រា ៣១.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៧

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៩០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១១៧ , ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- យោងលិខិតលេខ ១៤០៦ បទ.ថកហវ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៧ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១ : ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន: ១.០១២.០០០.០០០រៀល (មួយពាន់ដប់ពីរលានរៀលគត់) ពីជំពូក ៦០ (ការទិញ) ជំពូក ៦១ (សេវាខាងក្រៅ) មកជំពូក ៦២ (សេវាខាងក្រៅផ្សេងៗ) ជូនក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២ : ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបំពេញតំរូវការចំណាយជាក់ស្តែង របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីគោរពជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦០១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៛៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ផ្តល់ជូនលោកឧត្តមសេនីយ៍ត្រី **ហេង ទុន្ធី** នាយករងទីចាត់ការអភិវឌ្ឍន៍នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ដែលបានបរិច្ចាគថវិកាចំនួន ១២.៩០០ ដុល្លារអាមេរិក សំរាប់ជួយកសាងអគារដាក់កុំព្យូទ័រ ចំនួន ០១ខ្នង បន្ទប់ទឹក ០៣ និងទិញកុំព្យូទ័រ ចំនួន១០គ្រឿង ម៉ាស៊ីនភ្លើង ០១គ្រឿង និង ប៉ៅអ៊ី ២០ ផ្តល់ជូនវិទ្យាល័យ ហ៊ុន សែន កំពង់ភ្នំ ក្នុងស្រុកលើកដែក ខេត្តកណ្តាល ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ HVRT

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦០៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមហ៊ុន **AEON Fantasy Co.LTD** ដែលបានឧបត្ថម្ភថវិកា ចំនួន ៣៤.២៦៤ ដុល្លារអាមេរិក ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៥បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារឹមគ្រប់គ្រាន់ នៅសាលាបឋមសិក្សាអង្គក្តី ក្នុងឃុំព្រៃវិហារ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦០៧ អនក្រ.តត

អនុក្រឹត្យ
ស្ដីពី
ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស /រកត/០៧០៤/១២៤ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **សោ ពន្លក** អត្តលេខ ០២១៩៤ នាយនគរបាលជាតិជាន់ខ្ពស់ នៃ ក្រសួងមហាផ្ទៃ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង - ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦០៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

៙៚

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ជូនសប្បុរសជនចំនួន ១៨ រូប ដែលមានស្នាដៃល្អ ក្នុងការជួយកសាង និងអភិវឌ្ឍន៍ នៅក្នុងឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោមនេះ ÷

ក. មេដាយមាសការងារ :

១-លោកស្រី	ចាន់	ប៉ូរី	៦-លោក	អ៊ិត	សាន
២-លោក	ស៊ុន	សុត	៧-លោក	ឈួន	ចាន់ថន
៣-ឯកឧត្តម	ឈុំ	គង់ផល្លី	៨-លោក	អ៊ុច	សេង
៤-លោក	ជេត	ដាលី	៩-លោក	នូច	ស៊ុនណារី
៥-លោក	អ៊ុំ	ទិប្បុល	១០-លោក	ម៉ុក	សុខុម

ខ. មេដាយប្រាក់ការងារ :

១-លោក	ឆេង	សុវណ្ណារិទ្ធ	៥-កញ្ញា	សួន	ណារី
២-លោក	សេង	សក្តិសុយ	៦-លោក	ហៃ	វិចិត្រ
៣-លោក	ជុំ	សុវណ្ណគន្ធារស	៧-លោក	ប៊ិច	គ្រៀន
៤-លោកស្រី	ឡោ	គីមនី	៨-លោកស្រី	ម៉ម	វណ្ណា

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦០៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

១០៤

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនចំនួន ០៦ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងកុដិធំមួយខ្នង ធ្វើអំពីបេតុង របងព័ទ្ធជុំវិញវត្ត ផ្លូវចាក់បេតុង សួនច្បារខាងមុខព្រះវិហារ និង សមិទ្ធផលនានា នៅឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល ដូចមានរាយ នាមខាងក្រោមនេះ ÷

ក.មេដាយមាសស្ថាបនាជាតិ :

១-លោកតាព្រឹទ្ធាចារ្យ អ៊ុន សារឿន សប្បុរសជន
២-លោកស្រី ជាប សុផានី សប្បុរសជន
៣-លោក កែប សេខ សប្បុរសជន

ខ.មេដាយប្រាក់ស្ថាបនាជាតិ :

១-លោក ចាក់ សុខគឿន សប្បុរសជន
២-លោក ស្រ៊ុន ឡុ សប្បុរសជន
៣-លោក តិច ផាន់ណា សប្បុរសជន

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦០៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

១០៩

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជនចំនួន ១០ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងកុដិធំមួយខ្នង ធ្វើអំពីបេតុង របងព័ទ្ធជុំវិញវត្ត ផ្លូវចាក់បេតុង សួនច្បារខាងមុខព្រះវិហារ និង សមិទ្ធផលនានា នៅក្នុងវត្តព្រែកអំបិល ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ +

ក_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ **ធិបឌិន្ទ :**

១-ព្រះតេជគុណឥន្ទញ្ញាណោ **យឹម អុន** ២-លោកជំទាវ **ចាប ចំនួម៉ានីកា**

ខ_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

១-លោក **ទ៉ាន់ ចំនួផេន** ៣-លោកយាយ **ពៅ ទ៉ោ**

២-លោក **សេខ សុខុម** ៤-លោក **អ៊ុខ ផេខ**

គ_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ **អស្សឫទ្ធិ :**

១-លោក **ហុខ សំអាខ** ៣-លោក **ឈឹម ឈាខហួខ**

២-លោក **អៀ ខេខ** ៤-លោក **ឡៀម សុគិរៈ**

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ [illegible], ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>**កន្លែងទទួល :**</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ..៦០៣..អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិ ដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិ នៃប្រាសាទព្រះវិហារ

******

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/១៨៣ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិ នៃប្រាសាទព្រះវិហារ

-យោងតាមតម្រូវការចាំបាច់នៃការងារ

សម្រេច

មាត្រា១.-

ត្រូវបានតែងតាំងក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិ ដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិ នៃប្រាសាទព្រះវិហារ ដែលមានសមាសភាពដូចខាងក្រោម ÷

១- ឯកឧត្តម **ទី យ៉ាវ**	អនុប្រធានក្រុមសង្គ្រោះការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌	ប្រធាន
២- ឯកឧត្តម **ប្រាជ្ញ ចាន់**	អភិបាលខេត្តព្រះវិហារ	សមាជិក
៣- ឯកឧត្តម **សោម សុគន្ធ**	អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក

៤- ឯកឧត្តម **សូ ម៉ារ៉ា** អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

៥- ឯកឧត្តម **នូ កឿង** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៦- ឯកឧត្តម **លឹម ស៊ីដេនីន** អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៧- ឯកឧត្តម **ញាណ ឡេង** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៨- ឯកឧត្តម **ឆា ដុម** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

៩- ឯកឧត្តម **ម៉ម សុផាណា** អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

១០-ឯកឧត្តម **សួស យ៉ារ៉ា** អគ្គលេខាធិការរងនៃអាជ្ញាធរជាតិទេសចរណ៍កម្ពុជា សមាជិក

១១-ឯកឧត្តមអគ្គនាយកនៃអាជ្ញាធរជាតិ ដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិ នៃប្រាសាទព្រះវិហារ សមាជិក និងលេខាធិការ ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ប្រធានអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ អភិបាលខេត្តព្រះវិហារ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦០៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជនទៅក្នុង និងក្រៅប្រទេស ចំនួន១៣រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ នៅវត្តលក្ខរាជា ស្ថិតនៅឃុំកំពង់ចក ស្រុករំដួល ខេត្តស្វាយរៀង ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ព្រះពេជគុណ យឹម សារិន	ចៅអធិការវត្តលក្ខរាជា	បច្ច័យចំនួន ២០.៧៩៥ ដុល្លារ
២-លោក ម៉ៅ ឈន់	សប្បុរសជននៅទីក្រុងភ្នំពេញ	ថវិកា ចំនួន ១៤.៥៨២ ដុល្លារ
៣-ឯកឧត្តម ជូ ទិជិត្ត	អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	ថវិកា ចំនួន ១៣.៥៨២ ដុល្លារ
៤-អ្នកស្រី សុខ ឈុន	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ១២.៤៦១ ដុល្លារ

ខ-មេដាយសំរឹទ្ធស្ថាបនាជាតិ :

១-អ្នកស្រី សរ សុផា	សប្បុរសជននៅទីក្រុងភ្នំពេញ	ថវិកា ចំនួន ៣.៧៨៨ ដុល្លារ
២-ឯកឧត្តម ញ៉ូ សារណន	មេបញ្ជាការរងភូមិភាគទី៤	ថវិកា ចំនួន ១.៨៥៦ ដុល្លារ
៣-លោក ហ៊ាន ម៉ុនធឿន	អគ្គនាយកក្រុមហ៊ុនសំភារៈក្រសួងកសិកម្ម	ថវិកា ចំនួន ៣.៦២៨ ដុល្លារ
៤-លោក ខោល ស៊ុន	សប្បុរសជននៅទីក្រុងភ្នំពេញ	ថវិកា ចំនួន ៣.២១៦ ដុល្លារ
៥-ឧបាសិកា កែវ សាម៉ន	សប្បុរសជននៅទីក្រុងភ្នំពេញ	ថវិកា ចំនួន ១.៩៣៥ ដុល្លារ

៦-អ្នកស្រី កៅ សន	សប្បុរសជននៅទីក្រុងភ្នំពេញ	ថវិកា ចំនួន ១.០០០ ដុល្លារ
៧-លោកព្រឹទ្ធាចារ្យ ឡាយ ស៊ុំ	សប្បុរសជននៅទីក្រុងភ្នំពេញ	ថវិកា ចំនួន ១.០០០ ដុល្លារ
៨-លោក ទឹម សាខុន	សប្បុរសជននៅខេត្តស្វាយរៀង	ថវិកា ចំនួន ១.០០០ ដុល្លារ
៩-ឧបាសិកា ហ៊ួត សេយ៉ោន	សប្បុរសជននៅទីក្រុងភ្នំពេញ	ថវិកា ចំនួន ២.៧២៥ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦០៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០៤រូប ដែលបានបរិច្ចាគថវិកាជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៨បន្ទប់ និងបង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ នៅសាលាបឋមសិក្សាវត្តកោះកែវ ក្នុងឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

១-ឧបាសិកា **ស៊ុយ ជីម**	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១០.៥០០ ដុល្លារ
២-លោក **ហ៊ិន ទី**	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១០.៥០០ ដុល្លារ
៣-លោក **ហ៊ិន ទិច**	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១០.០០០ ដុល្លារ
៤-អ្នកស្រី **ណាំ សារេឿន**	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១០.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែសីហា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៧០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ប្រគេនព្រះគ្រូព្រហ្មគិរីធម្មបាលសង្ឃ យោគី **កែវ ចន្ថា** ព្រះអនុគណស្រុកភ្នំស្រួច និងជាព្រះចៅអធិការវត្តដំណាក់ត្រាច ដែលបានចូលរួមយ៉ាងសកម្មក្នុងការកសាងអភិវឌ្ឍន៍វិស័យព្រះពុទ្ធសាសនា ដោយបានចលនាពុទ្ធបរិស័ទ និងចំណាយបច្ច័យសរុបចំនួន ២០០.៦២២.៧៥ ដុល្លារអាមេរិក ជួយកសាងសមិទ្ធផលនានាជាច្រើន នៅវត្តដំណាក់ត្រាច ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦១១ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកណ្តាល

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកជំទាវ ឧកញ៉ា **សុគន្ធ ថាវី** ទីប្រឹក្សាផ្ទាល់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ដែលបានឧបត្ថម្ភថវិកា ចំនួន ១០.០០០ ដុល្លារ សំរាប់ជួយចាក់ដីបំពេញបរិវេណទីស្នាក់ការ ច្រកទ្វារព្រំដែន ជ្រៃធំ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបាន លទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៦៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ៌ណ្ឌ

៙

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ៌ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនលោក **ចាប ម៉ុច** ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកណ្តាល ដែលមានស្នាដៃល្អក្នុងការដឹកនាំការងារ ជីកអណ្តូង នៅកោះពូលូវ៉ៃ និងកោះតាង សម្រេចបានលទ្ធផលល្អ ប្រសើរ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងនាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។ល។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៦៣ អនក្រ.ចត

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

៚

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនក្រុមការងារជីកអណ្តូង នៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកណ្តាល ចំនួន ០៥រូប ដែលមានស្នាដៃល្អក្នុងការចុះជួយជីកអណ្តូង នៅកោះពូលូវៃ និងកោះតាង ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសការងារ :

-លោក **សន ស៊ុន** ប្រធានក្រុមការងារ ជីកអណ្តូង

ខ-មេដាយប្រាក់ការងារ :

១-លោក ឡុង រ៉ុំ កម្មករជីកអណ្តូង

២-លោក អ៊ឹម អេះ កម្មករជីកអណ្តូង

៣-លោក អ៊ុំ សារុធ កម្មករជីកអណ្តូង

៤-លោក ម៉ន គង់ កម្មករជីកអណ្តូង

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងនាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ៚

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦១៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងពតិមាន

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនមន្ត្រីរាជការ នៃក្រសួងពតិមាន ចំនួន២៦រូប ដែលមានស្នាដៃ និងគុណបំណាច់ចំពោះការប្រតិបត្តិការងារសំរាប់ក្រសួងព័ត៌មាន ជាពិសេសក្នុងការឃោសនាផ្សព្វផ្សាយ ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម :-

១-លោកជំទាវ	គិត គឹមហួន	អគ្គនាយក AKP
២-ឯកឧត្តម	គន់ យ៉ាន	អគ្គនាយក RNK
៣-ឯកឧត្តម	ចាន់ គឹមសឺ	អគ្គនាយក រដ្ឋបាល-សោតទស្សន៍
៤-ឯកឧត្តម	ភឹម គុណវឌ្ឍន៍	អគ្គនាយក TVK
៥-លោក	ប៊ុត បូទុត	អគ្គនាយករងរដ្ឋបាល-សោតទស្សន៍
៦-លោក	ឆី សារ៉ាន	អគ្គនាយករងរដ្ឋបាល-សោតទស្សន៍
៧-លោក	សេង ម៉ាឈីស	អគ្គនាយករងរដ្ឋបាល-សោតទស្សន៍
៨-លោក	តាក់ លីហុក	អគ្គនាយករង AKP
៩-លោក	ឈឿន យួន	អគ្គនាយករង AKP
១០-លោក	ហ៊ឹម សួង	អគ្គនាយករង TVK
១១-លោក	ឌី សុខណាត	អគ្គនាយករង TVK
១២-លោក	នួច ឆដ្ឋា	អគ្គនាយករង RNK
១៣-លោក	គឹម នី	អគ្គនាយករង RNK
១៤-លោក	យឿន នារ៉ា	អគ្គនាយករង

១៥-លោក	មួង	សុខន្តី	អគ្គនាយករង
១៦-លោក	ស៊ីន	សុខ	ប្រធាននាយកដ្ឋានរដ្ឋបាល
១៧-លោកស្រី	នង	ហ៊ឿន	ប្រធាននាយកដ្ឋានបុគ្គលិក
១៨-លោកស្រី	លឹម	ម៉ុំ	ប្រធាននាយកដ្ឋានគណនេយ្យ
១៩-លោក	សេង	សារុន	ប្រធាននាយកដ្ឋានសោតទស្សន៍
២០-លោក	ឈាង	ម៉ុនរិទ្ធ	ប្រធាននាយកដ្ឋានសម្ភារៈ
២១-លោក	យួន	ទិចត្រ	ប្រធាននាយកដ្ឋានផ្សាយទៅបរទេស AKP
២២-លោក	សោម	សារុន	ប្រធាននាយកដ្ឋាន RNK
២៣-លោក	សម	សារិន	ប្រធាននាយកដ្ឋាន TVK
២៤-លោក	គាត	ចន្ទ្រា	ប្រធាននាយកដ្ឋាន TVK
២៥-លោក	គី	ឡុង	ប្រធាននាយកដ្ឋាន TVK
២៦-លោក	អ៊ុយ	ឌួន	ប្រធាននាយកដ្ឋាន TVK

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងពត៌មាន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦១៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ និងនាយទាហានជាន់ខ្ពស់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលបានប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលបានប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានប្រគល់ភារកិច្ច ជូនមន្ត្រីរាជការ និងនាយទាហានជាន់ខ្ពស់ចំនួន ០២រូប ជាអភិបាលរងខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :

១-លោក **ជឹម សុខខុន** ឋានន្តរសក្តិ អនុមន្ត្រីថ្នាក់លេខ ៥

២-លោក **ជួន សុខណ្ណ** មន្ត្រីកងយោធពលខេមរភូមិន្ទ

មាត្រា២ : លោក **ឌឹម សុខខុន** និង លោក **ជួន សុវណ្ណ** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងតំណែងថ្មីនេះស្រប តាមព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវ ដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

មាត្រា៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- -ដូចមាត្រា៤ (ដើម្បីអនុវត្ត)
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦១៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការសំរួលភារកិច្ចមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ :ត្រូវបានសំរួលភារកិច្ចមន្ត្រីរាជការចំនួន ០២រូប ពីអភិបាលរងខេត្តកណ្តាល អោយមកបំរើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ដដែល ដូចមានរាយនាមខាងក្រោម :

១- លោក ហេ ការន់ ឋានន្តរសក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ១

២- លោក ទេខ ញ៉ាន់ ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៧ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៣ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ* ✓

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦១៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៣០៦/១២២ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន០២រូប អោយទទួលមុខតំណែងជាអភិបាលរងខេត្ត នៅខេត្តកំពត និង ខេត្តពោធិ៍សាត់ ដូចមានរាយនាមខាងក្រោម :

១- លោក **សួង ផល្លី** ឋានន្តរសក្តិឧត្តមសេនីយ៍ត្រី នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ជាអភិបាលរងខេត្តកំពត

២- លោក **ភាន់ ខេមរា** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ ជាអភិបាលរង ខេត្តពោធិ៍សាត់ ។

មាត្រា ២ : លោក **សួន ឧល្លី** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួន ត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧១៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- យោងអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងដំណើរការ នៃការដាក់មន្ត្រីរាជការស៊ីវិល ឱ្យចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធព័ត៌មានវិទ្យា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានដាក់ឱ្យលោក **សយ សុខត្ថិ** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៤ អភិបាលស្រុកកំពង់ត្រាច ខេត្តកំពត ចូលនិវត្តន៍ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ដើម្បីជូនដំណឹង*
- *ដូចមាត្រា ៣ ដើម្បីអនុវត្ត*
- *[illegible]*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧១៨ អនក.បក

អនុក្រឹត្យ

ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **អ៊ុម ស៊ុណារ៉ាត** ឋានន្តរសក្តិ នាយក្រមការ ថ្នាក់លេខ ៣ ជាអភិបាលស្រុកកំពង់ត្រាច ខេត្តកំពត ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចមាត្រា ៣ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧០ អនក្រ.បក

អនុក្រឹត្យ

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន នៅក្នុងនិងក្រៅប្រទេស ចំនួន១៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ ចេតិយ សាលាធម្មសភា កុដិ សាលាធម្មវិន័យ របងវត្ត និង ឧបដ្ឋានសាលា ព្រមទាំងសមិទ្ធផលនានាជាច្រើនទៀត នៅវត្តបាគង និងវត្តឥន្ទនិមិត្ត ស្ថិតក្នុងឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក_មេដាយមាសស្ថាបនាជាតិ :

១-ព្រះគ្រូ	ខាត់	អ៊ុច	អនុគណស្រុកកំពង់ស្វាយ	បច្ច័យចំនួន ១០.៦៥០ ដុល្លារ
២-ព្រះគ្រូ	ឈិត	សាផ្ទះ	ចៅអធិការវត្តបាគង	បច្ច័យចំនួន ១០.០៤២ ដុល្លារ
៣-លោក	ហុក	ឈាងហុង	សប្បុរសជននៅទីក្រុងភ្នំពេញ	ថវិកា ចំនួន ៣៣.០០០ដុល្លារ
៤-ឧបាសិកា	សោម	ឡាយ	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ៣៣.៤៥០ ដុល្លារ
៥-លោក	ឆាំង	វណ្ណថន	មន្ត្រីគយ ប្រចាំខេត្តតាកែវ	ថវិកា ចំនួន ១០.១៥០ ដុល្លារ
៦-លោក	ឆាំង	វ៉ាន់ថា	មន្ត្រីគយ ទីក្រុងភ្នំពេញ	ថវិកា ចំនួន ១០.១៥០ ដុល្លារ
៧-លោក	យក់	ឆយ	មន្ត្រីមន្ទីរហិរញ្ញវត្ថុ ខេត្តកំពង់ធំ	ថវិកា ចំនួន ១០.៦០៥ ដុល្លារ
៨-ឧបាសិកា	អ៊ិន	វណ្ណា	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ២១.១២០ ដុល្លារ

ខ_មេដាយប្រាក់ស្ថាបនាជាតិ :

១-ឧបាសក	យក់	ឆន	អាចារ្យវត្តបាគង	ថវិកា ចំនួន ៨.១២០ ដុល្លារ
២-ឧបាសក	គល់	ឈុត	គណៈកម្មការវត្តបាគង	ថវិកា ចំនួន ៦.២៥៧ ដុល្លារ
៣-ឧបាសក	តន់	ផាត់	សប្បុរសជននៅខេត្តកំពង់ធំ	ថវិកា ចំនួន ៦.៥៧១ ដុល្លារ

គ-មេដាយសេរីវឌ្ឍស្ថាបនាជាតិ :

១-ឧបាសក ថៃ ឆៃ	គណៈកម្មការវត្តឥន្ទនិមិត្ត	ថវិកា ចំនួន ៣.៥០០ ដុល្លារ
២-ឧបាសក ឈិត ព្រីង	គណៈកម្មការវត្តឥន្ទនិមិត្ត	ថវិកា ចំនួន ៣.៣១០ ដុល្លារ
៣-ឧបាសក ឆាង	អាចារ្យវត្តឥន្ទនិមិត្ត	ថវិកា ចំនួន ៣.២០០ ដុល្លារ
៤-ឧបាសិកា សូ យូ	សប្បុរសជននៅខេត្តកំពង់ធំ	ថវិកា ចំនួន ៣.១០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

អន្លែងទទួល:

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចក្នុងមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៣ . សរ

សារាចរ

ស្តីពី

វិធានការពង្រឹងប្រព័ន្ធគ្រប់គ្រង និង ត្រួតពិនិត្យការធ្វើអាជីវកម្មសម្ភារៈកសិកម្ម

កន្លងមករាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹងប្រសិទ្ធភាពដល់ការគ្រប់គ្រងសម្ភារៈកសិកម្មរួមមាន : ជីគីមី ថ្នាំកសិកម្ម គ្រាប់ពូជ និង បំណែកពូជដំណាំ បសុឱសថ ចំណីសត្វ និង ចំណីបន្ថែម ដើម្បីសម្រួលដល់អ្នកប្រើប្រាស់ និង កសិករឱ្យមានសមត្ថភាពយល់ដឹងក្នុងការប្រើប្រាស់សម្ភារៈកសិកម្មទាំងអស់ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព តាមរយៈលិខិតបទដ្ឋាននានាជាអាទិ៍ ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និង សេវា ដែលប្រកាសឱ្យប្រើតាមរយៈព្រះរាជក្រម លេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ អនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៨ ស្តីពីបមាណី និង ការគ្រប់គ្រងសម្ភារៈកសិកម្ម សារាចរណែនាំលេខ ៣៤៥ សរណន.កសក ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការអនុវត្តអនុក្រឹត្យ លេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៨ ស្តីពីបមាណី និង ការគ្រប់គ្រងសម្ភារៈកសិកម្ម និង បណ្តាប្រកាស សេចក្តីណែនាំអនុវត្តផ្សេងទៀតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

ទោះជាមានមូលដ្ឋានលិខិតបទដ្ឋានច្បាប់សម្រាប់គ្រប់គ្រងសម្ភារៈកសិកម្ម និង មានវិធានការអនុវត្តន៍ដោយសមត្ថកិច្ចពាក់ព័ន្ធហើយក្តី រាជរដ្ឋាភិបាលនៅតែសង្កេតឃើញថាការគ្រប់គ្រង និង ការត្រួតពិនិត្យលើការនាំចូល ការផលិត ការកែច្នៃ ការចែកចាយ និង ការលក់ដូរសម្ភារៈកសិកម្មនៅមិនទាន់មានប្រសិទ្ធភាពពេញលេញនៅឡើយ ដូចជានៅមានការហូរចូលដោយល្មើសច្បាប់នូវជីគីមី ថ្នាំកសិកម្ម និង សម្ភារៈកសិកម្ម

ផ្សេងទៀតដែលងាយបង្កគ្រោះថ្នាក់។ល។ ទន្ទឹមនេះមានជនមួយចំនួនបានធ្វើអាជីវកម្មកេងប្រវ័ញ្ច តាមរយៈការផលិតកែច្នៃជីគីមីក្លែងគុណភាព ឬ លាយផ្សំដោយគ្មានមូលដ្ឋានបច្ចេកទេសត្រឹមត្រូវ ឬ ក្លែងសំបកវេចខ្ចប់ និង បានធ្វើការលក់ ចែកចាយតាមរយៈឈ្មួញកណ្តាល ដោយដឹកជញ្ជូនដល់ភូមិ ឃុំ ក្រោមរូបភាពលក់បណ្តាក់ ដោយយកការប្រាក់ទាប ឬ លក់ក្នុងតម្លៃថោក។ សកម្មភាពអសីលធម៌នេះបាននាំមកនូវសម្ពាធកាន់តែធ្ងន់ធ្ងរថែមទៀត ចំពោះកសិករក្រីក្រព្រមទាំងបាននាំមកនូវផលប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅជនបទ ដែលជាទង្វើផ្ទុយទៅនឹងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

ឆ្លងតាមសកម្មភាពដ៏គ្រោះថ្នាក់នេះ ដើម្បីពង្រឹងឡើងវិញនូវប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និង ត្រួតពិនិត្យការធ្វើអាជីវកម្មសម្ភារៈកសិកម្មឱ្យបានត្រឹមត្រូវ ធានានូវបមាណគុណភាពដល់អ្នកប្រើប្រាស់ រក្សានូវសុវត្ថិភាពស្បៀង សុខភាពសាធារណៈ ក្សេត្របរិស្ថាន និង រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់កសិករ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការបន្ថែមដូចខាងក្រោម :

១-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវបន្តអនុវត្តការផ្សព្វផ្សាយ អប់រំណែនាំអំពីគ្រោះថ្នាក់ និង ហានិភ័យដែលអាចបង្កឡើងដោយការប្រើប្រាស់សម្ភារៈកសិកម្ម។

២-ក្រសួងព័ត៌មានត្រូវជួយតាមដាន ត្រួតពិនិត្យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងស្រុក លើការផ្សព្វផ្សាយពាណិជ្ជកម្មស្តីពីសម្ភារៈកសិកម្មជាអាទិ៍ ជីគីមី ថ្នាំកសិកម្ម ចំណីសត្វ ដែលនាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាដោយល្មើសច្បាប់ គ្មានការត្រួតពិនិត្យ និង គ្មានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

៣-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវសហការជាមួយក្រសួងព័ត៌មាន និង អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ដើម្បី :

-ធ្វើការផ្សព្វផ្សាយ អប់រំដល់អាជីវករសម្ភារៈកសិកម្មឱ្យទទួលយកវិធានការបច្ចេកទេសជាចាំបាច់ និង ត្រូវស្នើសុំលិខិតអនុញ្ញាតពីសមត្ថកិច្ចកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ស្របតាមនីតិវិធី និង បទប្បញ្ញត្តិច្បាប់ជាធរមាន។

-ធ្វើការផ្សព្វផ្សាយ អប់រំណែនាំកសិករក្នុងមូលដ្ឋាន ឱ្យបានយល់ដឹង និង ត្រូវមានស្មារតីប្រុងប្រយ័ត្នអំពីគ្រោះថ្នាក់ និង ហានិភ័យ ដែលអាចបង្កឡើងដោយ

សម្ភារៈកសិកម្ម ដោយប្រើប្រាស់សម្ភារៈកសិកម្មណាដែលធានាគុណភាពច្បាស់លាស់ ហើយនៅលើសំបកវេចខ្ចប់មានស្លាកសញ្ញាព័ត៌មានបច្ចេកទេសត្រឹមត្រូវជាអក្សរខ្មែរដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នៅក្រោយពេលនាំចូល និង នៅពេលចរាចរចែកចាយ ប្រើប្រាស់។

៤-ទីចាត់ការគយ និង រដ្ឋាករ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ចាំបាច់ត្រូវជំរុញការអនុវត្តអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ រួមមានការបង្កើតកិច្ចព្រមព្រៀងអន្តរស្ថាប័ន ពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យលើទំនិញនាំចេញនាំចូល ជាពិសេសសម្ភារៈកសិកម្ម។

៥-សមត្ថកិច្ចគយ និង រដ្ឋាករ សមត្ថកិច្ចកាំកុងត្រូល និង អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៅតាមបណ្តាច្រកព្រំដែន រួមទាំងអាជ្ញាធរដែនដីដែលមានព្រំដែនជាប់ប្រទេសជិតខាងត្រូវពង្រឹងការត្រួតពិនិត្យការនាំចូលសម្ភារៈកសិកម្មគ្រប់ប្រភេទ ជាពិសេសត្រូវចាត់វិធានការបន្ទាន់ចំពោះការហូរចូលនូវសម្ភារៈកសិកម្មក្លែងគុណភាព និង ខូចគុណភាព សម្ភារៈកសិកម្មនាំចូលដោយគ្មានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឬ មានប្រភពល្មើសច្បាប់ផ្សេងទៀត ព្រមទាំងចាត់វិធានការផងដែរចំពោះការហូរចូលសម្ភារៈកសិកម្មល្មើសច្បាប់តាមច្រករបៀងដោយប្រើរូបភាពតូចៗ។

៦-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវចាត់វិធានការចាំបាច់នានាជាបន្ទាន់ សំដៅពង្រឹងការអនុវត្តច្បាប់ជាធរមាន លើការធ្វើអាជីវកម្មសម្ភារៈកសិកម្ម ជាពិសេសត្រូវចាត់វិធានការបង្ក្រាបចំពោះមូលដ្ឋានអាជីវកម្មដែលនាំចូល ផលិត កែច្នៃ ចែកចាយសម្ភារៈកសិកម្មក្លែងគុណភាព និង ខូចគុណភាព ឬ មានប្រភពនាំចូលដោយល្មើសច្បាប់។

៧-អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និង អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវសហការឱ្យបានល្អប្រសើរជាមួយសមត្ថកិច្ចកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងការអនុវត្តច្បាប់ និង បង្ក្រាបរាល់អំពើល្មើសច្បាប់ក្នុងការធ្វើអាជីវកម្មលក់ដូរសម្ភារៈកសិកម្ម ជាពិសេសត្រូវចាត់វិធានការដ៏តឹងរ៉ឹងលុបបំបាត់ការធ្វើអាជីវកម្ម ឬ ការបង្កើតមូលដ្ឋានអាជីវកម្មសម្ភារៈកសិកម្មក្លែងគុណភាពនៅក្នុងមូលដ្ឋានខេត្ត ក្រុងសាមី ឱ្យទទួលបានប្រសិទ្ធភាពខ្ពស់។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និង ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមព្រះរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
-គ្រប់សាលាខេត្ត-ក្រុង
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :.០៤.សរណន

សារាចរណែនាំ
ស្តីពី
ការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨

I. បរិការណ៍នៃការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨

ក- <u>*ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច*</u>

១- ឆ្នាំ ២០០៦ គឺជាឆ្នាំទីមួយនៃការចាប់ផ្តើមអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ របស់រាជរដ្ឋាភិបាលនីតិកាលទី ៣ នៃរដ្ឋសភា ហើយក៏ជាឆ្នាំទីបីនៃការដាក់អោយអនុវត្ត យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព ក្នុងគោលបំណងធានាអោយបាននូវកំណើនសេដ្ឋកិច្ចកំរិតខ្ពស់ប្រកបដោយចិរភាព និង សមធម៌ ដែលជាកត្តាគន្លឹះដ៏សំខាន់បំផុតសំរាប់សំរេចបានជោគជ័យនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ទន្ទឹមនឹងនេះ វាក៏ជាឆ្នាំនៃការបន្តជំរុញការលើកកំពស់អភិបាលកិច្ចល្អតាមរយៈកម្មវិធីកែទំរង់ស៊ីជំរៅលើគ្រប់វិស័យ ជាពិសេស ការកែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ការកែទំរង់រដ្ឋបាលសាធារណៈ និង ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទំរង់កងកម្លាំងប្រដាប់អាវុធ និង ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។

២- តាមការប៉ាន់ស្មានចុងក្រោយរបស់វិទ្យាស្ថានជាតិស្ថិតិ កំណើនសេដ្ឋកិច្ចគិតតាមថ្លៃថេរសំរាប់ឆ្នាំ ២០០៦ សំរេចបាន ១០,៨% ធៀបនឹងការព្យាករណ៍ប្រមាណ ៦,១% នៅដើមឆ្នាំ ។ កំណើននេះ បានមកដោយសារ វិស័យកសិកម្មបានកើនប្រមាណ ៥,៥% ដែលក្នុងនោះ ដំណាំស្រូវបានកើនប្រមាណ ៥,៣% វិស័យឧស្សាហកម្មបានកើនប្រមាណ ១៨,៣% ដែលក្នុងនោះ ផលិតកម្មវាយនភ័ណ្ឌបានកើនប្រមាណ ២០,៤% និង ផលិតកម្មសំណង់បានកើនប្រមាណ ២០% និង វិស័យសេវាកម្មបានកើនប្រមាណ ១០,៣% ដែលក្នុងនោះ សកម្មភាពទេសចរណ៍បានកើនប្រមាណ ១១,៧% ។ គួរកត់សំគាល់ថា នេះគឺជាស្ថានភាពសេដ្ឋកិច្ចដែលកម្ររកបាន គឺកំណើនសេដ្ឋកិច្ចខ្ពស់ អតិផរណាទាបប្រមាណ ៣% ហើយអត្រាប្តូរប្រាក់ក៏មានស្ថេរភាពល្អថែមទៀតគឺស្ថិតនៅក្នុងរង្វង់ប្រមាណ ៤ ១០០ រៀល ក្នុង ១ ដុល្លារអាមេរិក ទោះជាត្រូវរងឥទ្ធិពលនៃការឡើងថ្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិក៏ដោយ ។

៣- ក្នុងឆ្នាំ ២០០៧ នេះ តាមការព្យាករណ៍ចុងក្រោយ កំណើនសេដ្ឋកិច្ចអាចនឹងសំរេចបានប្រមាណ ៨,៥% ធៀបនឹងការព្យាករណ៍ដើមឆ្នាំត្រឹម ៦,៥% ។ សេណារីយោសុទិដ្ឋិនិយមជាងមុននេះ គឺក្រោយពីសង្កេតឃើញថា ផលិតកម្មវាយនភណ្ឌ និង សកម្មភាពទេសចរណ៍នៅតែបន្តកើនឡើង ហាក់ដូចជាពុំទាន់ទទួលឥទ្ធិពលប្រកួតប្រជែងពីប្រទេសវៀតណាម និង ចិននៅឡើយ ។ ម្យ៉ាងទៀត ផលិតភាពកសិកម្មក៏ត្រូវបាន និង កំពុងបន្តបង្កើនជាបន្តបន្ទាប់ ជាពិសេស តាមរយៈការបង្កើនផ្ទៃដីដាំស្រូវដោយប្រព័ន្ធស្រោចស្រព និង ការបង្កើនទិន្នផលស្រូវ ។ ទន្ទឹមនឹងនេះ ឆ្នាំនេះភ្លៀងធ្លាក់ដើមឆ្នាំ ប្រសិនបើមានភ្លៀងគ្រប់គ្រាន់រហូតដល់ចុងឆ្នាំដោយមិនជួបប្រទះគ្រោះទឹកជំនន់នោះទេ កំណើនវិស័យកសិកម្ម និង កំណើនសេដ្ឋកិច្ចអាចសំរេចបានខ្ពស់ជាងការព្យាករណ៍នេះ ។ ទោះជាយ៉ាងណា តាមសេណារីយ៉ូខាងលើនេះ វិស័យកសិកម្មនឹងមានកំណើនប្រមាណ ៤,៧% (ក្នុងនោះផលិតផលស្រូវនឹងកើនប្រមាណ ៥,៥% ហើយផលិតផលជលផលនឹងកើនប្រមាណ ២,៥%) វិស័យឧស្សាហកម្មនឹងមានកំណើនប្រមាណ ១០,៧% (ក្នុងនោះផលិតផលវាយនភ័ណ្ឌនឹងកើនប្រមាណ ១២,៣% ហើយផលិតផល សំណង់នឹងកើនប្រមាណ ៩,៨%) និង វិស័យសេវាកម្មនឹងមានកំណើនប្រមាណ ៩,៦% (ក្នុងនោះសកម្មភាពទេសចរណ៍នឹងកើនប្រមាណ ១៣%) ។ អត្រាអតិផរណានឹងនៅតែអាចរក្សាបាននៅក្នុងរង្វង់ ៣,៥% ហើយអត្រាប្តូរប្រាក់នឹងនៅតែរក្សាបានស្ថេរភាពដែលគឺក្នុងរង្វង់ ៤ ១០០ រៀល ក្នុង ១ ដុល្លាអាមេរិក ។

៤- ទោះជាយ៉ាងណាក៏ដោយ នៅក្នុងរយៈពេលមធ្យម (២០០៨-២០១០) សេដ្ឋកិច្ចនឹងនៅតែអាចរក្សាកំណើនជាមធ្យមប្រមាណពី ៦% ទៅ ៧% ស្របតាមគោលដៅ **យុទ្ធសាស្ត្រចតុកោណ** ក៏ដូចជា **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ។ តាមការព្យាករណ៍ដែលមានលក្ខណៈប្រុងប្រយ័ត្ន កំណើនសេដ្ឋកិច្ចជាមធ្យមសំរាប់រយៈពេលមធ្យមពី ឆ្នាំ ២០០៨ ដល់ ២០១០ ខាងមុខ គឺអាចនឹងសំរេចបានប្រមាណ ៧% ដោយសារវិស័យកសិកម្មនឹងកើនជាមធ្យម ៤% ដែលក្នុងនោះ ផលិតផលស្រូវនឹងកើនជាមធ្យមប្រមាណ ៤,៧% វិស័យឧស្សាហកម្មនឹងកើនជាមធ្យម ៨% ដែលក្នុងនោះ ផលិតកម្មវាយនភ័ណ្ឌនឹងកើនជាមធ្យមប្រមាណ ៩% និង ផលិតកម្មសំណង់នឹងកើនជាមធ្យមប្រមាណ ៧,៦% និង វិស័យសេវាកម្មនឹងកើនជាមធ្យម ៨,៤% ដែលក្នុងនោះ សកម្មភាពទេសចរណ៍នឹងកើនជាមធ្យមប្រមាណ ១០% ។ រីឯអត្រាអតិផរណានឹងនៅតែអាចរក្សាបាននៅក្នុងរង្វង់ ៣,៥% ហើយអត្រាប្តូរប្រាក់នឹងអាចរក្សាស្ថេរភាពបានក្នុងរង្វង់ ពី ៤ ១០០ ទៅ ៤២០០ រៀល ក្នុង ១ ដុល្លាអាមេរិក ។

ខ- *ស្ថានភាពហិរញ្ញវត្ថុសាធារណៈ និង ថវិកា*

៥- ការអនុវត្តន៍គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពប្រុងប្រយ័ត្ន គួបផ្សំនឹងការអនុវត្តន៍គោលនយោបាយរូបិយវត្ថុសមស្រប និង ជាពិសេសការអនុវត្តន៍កម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈយ៉ាងមោះមុត គ្រប់ជ្រុងជ្រោយ និង ជាជំហានៗយ៉ាងច្បាស់លាស់ បានធ្វើអោយលទ្ធផលកំណើនសេដ្ឋកិច្ច លទ្ធផលវិស័យហិរញ្ញវត្ថុ និង ធនាគារ ព្រមទាំងលទ្ធផលនៃការអនុវត្តន៍ថវិកាឆ្នាំ ២០០៦ សំរេចបានយ៉ាងល្អប្រសើរគួរជាទីមោទនៈ ។ ជាក់ស្តែង កំណើនសេដ្ឋកិច្ចឆ្នាំ ២០០៦ សំរេចបានរហូតដល់ ១០,៨% ធៀបនឹងការព្យាករណ៍ដើមឆ្នាំ ៦,១% ។ វិស័យហិរញ្ញវត្ថុ

និង ធនាគារបាន និង កំពុងមានការរីកចំរើនគួរអោយកត់សំគាល់ តាមរយៈការរីកដុះដាលនៃធនាគារពាណិជ្ជ ការកើនឡើងនៃប្រាក់បញ្ញើធនាគារ ការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធ និង សេវាធនាគារ និង ការពង្រឹងការគ្រប់គ្រងធនាគារ ដែលជាមូលដ្ឋានដ៏សំខាន់សំរាប់ឈានទៅរកការរៀបចំមូលបត្ររដ្ឋ និង មូលបត្រឯកជន និង ការបង្កើតទីផ្សារភាគហ៊ុននៅកម្ពុជា ។

៦- នៅឆ្នាំ ២០០៦ កន្លងទៅនេះ ចំណូលក្នុងស្រុកសរុបសំរេចបាន ១១៦,៩% គឺមានកំនើន ២៤,៧% ធៀបនឹងឆ្នាំ ២០០៥ ហើយស្មើនឹង ១១,៤% នៃផសស ដែលក្នុងនោះ ចំណូលសារពើពន្ធសំរេចបាន ១១១,៥% ស្មើនឹង ៨,៦% នៃផសស មានកំណើន ២១,៣% ធៀបនឹងឆ្នាំ ២០០៥ និង ចំណូលមិនមែនសារពើពន្ធសំរេចបាន ៩៨,៣% ស្មើនឹង ២,២% នៃផសស ថយចុះប្រមាណ ៩,៧% ធៀបនឹងឆ្នាំ ២០០៥ ។ រីឯការអនុវត្តន៍ចំណាយវិញក៏មានលក្ខណៈល្អប្រសើរផងដែរ ជាក់ស្តែងចំណាយសរុបឆ្លងកាត់រតនាគារជាតិអនុវត្តបាន ៩៦,៤% មានកំនើន ១៧,១% ធៀបនឹងឆ្នាំ ២០០៥ ស្មើនឹង ៩,៩% នៃផសស ដែលក្នុងនោះ ចំណាយចរន្តអនុវត្តន៍បាន ៩៩,៤% មានកំណើន ១៨,៨% និង ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងប្រទេសអនុវត្តន៍បាន ៨២,៤% មានកំណើន ៨,៤% ធៀបនឹង ឆ្នាំ ២០០៥ រីឯចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសអនុវត្តបាន ១៥៥,៧% មានកំណើន ១៧,៧% ធៀបនឹង ឆ្នាំ ២០០៥ ។ ទន្ទឹមនឹងនេះ ចំណាយតាមវិស័យដែលអនុវត្តបានគឺ វិស័យរដ្ឋបាលទូទៅសំរេចបាន ១៣១,៥% កើនឡើង ២២,៥% ធៀបនឹងឆ្នាំ ២០០៥ ស្មើនឹង ១,៥% នៃផសស វិស័យការពារជាតិ និង សន្តិសុខសំរេចបាន ១០៦,៦% កើនឡើង ១៥,៣% ធៀបនឹងឆ្នាំ ២០០៥ ស្មើនឹង ១,៧% នៃផសស វិស័យសេដ្ឋកិច្ចសំរេចបាន ១០៣,៥% កើនឡើង ៣៤,៩% ធៀបនឹងឆ្នាំ ២០០៥ ស្មើនឹង ០,៨% នៃផសស និង វិស័យសង្គមកិច្ចសំរេចបាន ១០០% កើនឡើង ២២,៧% ធៀបនឹងឆ្នាំ ២០០៥ ស្មើនឹង ៣% នៃផសស ។ លទ្ធផលនៃការអនុវត្តន៍ចំណូល និង ចំណាយនេះ បានធ្វើអោយមានអតិរេកចរន្តស្មើនឹង ១,៩% និង ឱនភាពថវិកាសរុបស្មើនឹង ៣% នៃផសស ។

៧- ទោះជាកំណើនសេដ្ឋកិច្ចឆ្នាំ ២០០៧ អាចនឹងសំរេចបានរហូតដល់ ៨,៥% ធៀបនឹងការព្យាករណ៍ដើមឆ្នាំត្រឹម ៦,៥% ក៏ដោយ តែកំណើននេះទាបជាងការអនុវត្តន៍បានជាក់ស្តែងក្នុងឆ្នាំ ២០០៦ ដែលមានរហូតដល់ ១០,៨% ។ នេះជាសេណារីយ៉ូប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ជាពិសេស កម្ពុជាអាចនឹងរងឥទ្ធិពលនៃការប្រកួតប្រជែងលើទីផ្សារវាយនភ័ណ្ឌពីប្រទេសវៀតណាម និង ចិន និង កត្តាឱនភាពថវិកា និង ការធ្លាក់ចុះនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក ។ ទោះជាយ៉ាងណាក៏ដោយ យើងសង្ឃឹមថានឹងមិនមាន ឥទ្ធិពលជាអវិជ្ជមានធ្ងន់ធ្ងរមកលើស្ថានភាពហិរញ្ញវត្ថុសាធារណៈ និង ពិសេស លើការអនុវត្តន៍ថវិកាឡើយ លើកលែងតែមានគ្រោះទឹកជំនន់ ឬ គ្រោះរាំងស្ងួត ដែលអាចនឹងតំរូវអោយមានចំណាយបន្ថែមឥតគ្រោងទុកកើនឡើង ។ ចំណូលក្នុងស្រុកសរុបអាចនឹងសំរេចបាន ១០,៥% នៃផសស ថយចុះប្រមាណ ០,៩% នៃផសស ធៀបនឹងឆ្នាំ ២០០៦ (ដោយសារចំណូលមូលធនក្នុងស្រុកថយចុះគឺចំណូលពីឯកជនភាវូបនីយកម្ម) ដែលក្នុងនោះ ចំណូលសារពើពន្ធនឹងសំរេចបាន ៨,៧% នៃផសស កើនប្រមាណ ០,១% នៃផសស ចំណូលមិនមែនសារពើពន្ធនឹងសំរេចបាន ១,៨% នៃផសស កើនឡើងប្រមាណ ០,២% នៃផសស ធៀបនឹងឆ្នាំ ២០០៦ និង ចំណូលមូលធននឹងសំរេចបានប្រមាណ ៤,៧% នៃផសស ថយចុះប្រមាណ ១,៤% នៃផសស ធៀបនឹងឆ្នាំ ២០០៦ ។

ចំណាយសរុបអាចនឹងសំរេចបាន ១៤,៥% នៃផសស កើនឡើង ០,២% នៃផសស ធៀបនឹងឆ្នាំ ២០០៦ ដែលក្នុងនោះ ចំណាយចរន្តនឹងសំរេចបាន ៨,៧% នៃផសស កើនឡើង ០,៣% នៃផសស ធៀបនឹង ឆ្នាំ ២០០៦ និង ចំណាយមូលធនអាចនឹងសំរេចបាន ៥,៨% នៃផសស ថយចុះប្រមាណ ០,១% នៃ ផសស ធៀបនឹងឆ្នាំ ២០០៦ ។ ការអនុវត្តន៍ចំណូល និង ចំណាយនេះអាចនឹងធ្វើអោយមានអតិរេកចរន្តប្រមាណ ១,៨% នៃផសស និង ឱនភាពថវិកាសរុបប្រមាណ ៣,៩% នៃផសស ។

៨- ការបន្តពង្រឹង និង បង្កើនសមត្ថភាព និង ប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូល និង ចំណាយ ក្នុងក្របខ័ណ្ឌ **កម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ការអនុវត្តន៍ចំណូល និង ចំណាយឆ្នាំ ២០០៧ សង្ឃឹមថានឹងទទួលបានលទ្ធផលល្អប្រសើរជាងឆ្នាំ ២០០៦ មួយកំរិតបន្ថែមទៀត ។ ជាក់ស្តែង លទ្ធផលនៃការប្រមូលចំណូលត្រីមាសទី១ បានបង្ហាញអោយឃើញថា ចំណូលក្នុងស្រុកសរុបសំរេចបាន ២៥% នៃផែនការឆ្នាំ មានកំណើនប្រមាណ ២% ធៀបនឹងឆ្នាំ ២០០៦ ដែលក្នុងនោះចំណូលគយ និង រដ្ឋាករសំរេចបាន ២៣% មានកំណើន ៣% ធៀបនឹងឆ្នាំ ២០០៦ ពន្ធដារសំរេចបាន ៣០% ស្មើនឹងឆ្នាំ ២០០៦ និង ចំណូលមិនមែនសារពើពន្ធសំរេចបាន ២៥% មានកំណើន ៤% ធៀបនឹងឆ្នាំ ២០០៦ ។ ទោះជាការដាក់អោយអនុវត្តប្លង់គណនេយ្យថ្មី មាតិកាថវិកាថ្មី ព្រមទាំងការកែលំអនិតិវិធីចំណាយ និង លទ្ធកម្មសាធារណៈ បានជះឥទ្ធិពលខ្លះដល់ការចំណាយនៅក្នុងត្រីមាសទី១ ឆ្នាំ ២០០៧ នេះក៏ដោយ ក៏ពុំមានលក្ខណៈធ្ងន់ធ្ងរដែរ ព្រោះចំណាយសរុបឆ្លងកាត់រតនាគារជាតិត្រីមាសទី១ នៅតែសំរេចបានប្រមាណ ១៥% នៃផែនការឆ្នាំ គឺទាបជាងតែប្រមាណ ២% ប៉ុណ្ណោះបើធៀបនឹងត្រីមាសទី១ ឆ្នាំ ២០០៦ ហើយចំណាយនៅក្នុងត្រីមាសទី២ នេះ ប្រាកដជានឹងកើនឡើង បន្ទាប់ពីគោលការណ៍ និង នីតិវិធីថ្មីទាំងនោះត្រូវបានអនុវត្តដោយរលូន ។

II. ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច ហិរញ្ញវត្ថុសាធារណៈ និង ថវិកាឆ្នាំ ២០០៨

ក. *ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច*

៩- ឆ្នាំ ២០០៨ គឺជាឆ្នាំទី ៣ នៃការបន្តអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង ជាឆ្នាំទី ៤ នៃការបន្តអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព របស់រាជរដ្ឋាភិបាល ជាពិសេស ការបន្តរក្សាអោយបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យម ពី ៦ ទៅ ៧ ភាគរយ ប្រកបដោយចិរភាព និង បន្តរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានគន្លឹះ និង ចាំបាច់បំផុតក្នុងការឈានទៅសំរេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលគឺ ***ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន*** ។ ទន្ទឹមនឹងនេះ វាក៏ជាឆ្នាំដែលត្រូវបន្តជំរុញការអនុវត្តន៍កម្មវិធីកែទំរង់ស៊ីជំរៅលើគ្រប់វិស័យ ដូចជា ការកែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ការកែទំរង់រដ្ឋបាលសាធារណៈ និង ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទំរង់កងកម្លាំងប្រដាប់អាវុធ និង ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និង ជាពិសេសគឺជាឆ្នាំដែលត្រូវរៀបចំការបោះឆ្នោតសកលលើកទី ៤ ដើម្បីបន្តពង្រឹងការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។

១០- ឆ្នាំ ២០០៨ គឺជាឆ្នាំដែលសេដ្ឋកិច្ចកម្ពុជាកំពុងតែបន្តវិវត្តផ្លាស់ប្តូររចនាសម្ព័ន្ធ ដើម្បីឈានទៅរកដំណាក់កាលនៃការអភិវឌ្ឍន៍មួយខ្ពស់ជាងមុន ដែលឆ្លុះបញ្ចាំងតាមរយៈការរីកធំធាត់ជាលំដាប់នៃសមាមាត្រវិស័យឧស្សាហកម្ម និង សេវាកម្ម នៅក្នុងរចនាសម្ព័ន្ធផលិតផលក្នុងស្រុកសរុប ។ ប្រការនេះ ទាមទារអោយមានការបន្តពង្រីកមូលដ្ឋាននៃកំណើន តាមរយៈការលើកស្ទួយវិស័យកសិកម្ម និង ការពង្រឹងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម និង សេវាកម្ម ដើម្បីបង្កើនតំលៃបន្ថែមលើផលិតកម្ម និង ស្រូបយកពលកម្មដែលត្រូវបន្តផ្ទេរជាបន្តបន្ទាប់ពីវិស័យកសិកម្ម ។ ធ្វើយ៉ាងនេះ ទើបអាចធានាការបន្តរក្សាបាននូវចិរភាព និង សមធម៌នៃកំណើនសេដ្ឋកិច្ចបាន ។ ដូច្នេះ នៅក្នុងរយៈពេលមធ្យម (២០០៨-២០១០) កំណើនសេដ្ឋកិច្ចកម្ពុជានឹងបន្តកើនឡើង ក៏ប៉ុន្តែនឹងកើនក្នុងល្បឿនមួយយឺតជាងមុន ហើយល្បឿននេះអាស្រ័យដោយល្បឿននៃការបង្កើនផលិតភាពកសិកម្ម និង ការពង្រីក និង ពង្រឹងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម និង សេវាកម្ម ។ ទោះជាយ៉ាងណាក៏ដោយ មូលដ្ឋានសេដ្ឋកិច្ចនឹងនៅតែអាចរក្សាកំណើនជាមធ្យមប្រមាណពី ៦% ទៅ ៧% នៅក្នុងរយៈពេលមធ្យមនេះ ។ តាមការព្យាករណ៍ ដែលមានលក្ខណៈប្រុងប្រយ័ត្ន កំណើនសេដ្ឋកិច្ចនៅឆ្នាំ ២០០៨ ខាងមុខនេះ អាចនឹងសំរេចបានប្រហែល ៧% ដោយសារវិស័យកសិកម្មនឹងកើនឡើង ៤,១% ដែលក្នុងនោះ ផលិតផលស្រូវនឹងកើនឡើងប្រមាណ ៤,៩% វិស័យឧស្សាហកម្មនឹងកើនឡើង ៨,៣% ដែលក្នុងនោះ ផលិតផលវាយនភ័ណ្ឌនឹងកើនឡើងប្រមាណ ៨,៨% និង ផលិតផលសំណង់នឹងកើនឡើង ៨,៦% និង វិស័យសេវាកម្មនឹងកើនឡើង ៨,២% ដែលក្នុងនោះ ទេសចរណ៍នឹងកើនឡើងប្រមាណ ១០% ។

ខ- ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ថវិកា

១១- ដោយផ្អែកលើមូលដ្ឋាននៃ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង **យុទ្ធសាស្ត្រចតុកោណ** ជាពិសេស គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ថវិកាឆ្នាំ ២០០៨ មានគោលដៅសំខាន់ៗ ដូចតទៅ៖

- ធានាអោយបាននូវការអនុវត្តន៍គោលនយោបាយអាទិភាពតាមវិស័យ នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តន៍ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ជាពិសេស គោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។
- ធានាការបន្តអនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** របស់រាជរដ្ឋាភិបាល ។
- ធានាការអនុវត្តន៍គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ដើម្បីរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និង បង្កើនភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។
- ធានាបំរើអោយការបន្តសកម្មភាពកែទំរង់ស៊ីជំរៅរបស់រាជរដ្ឋាភិបាល លើគ្រប់មុខសញ្ញា ដូចជា កំណែទំរង់រដ្ឋបាលសាធារណៈ កំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទំរង់អភិវឌ្ឍវិស័យឯកជន កំណែទំរង់ប្រព័ន្ធច្បាប់ និង តុលាការ កំណែទំរង់វិស័យកងទ័ព កំណែទំរង់ការគ្រប់គ្រងដីធ្លី និង ការពង្រឹងអភិបាលកិច្ចល្អ ។
- ធានាការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល ៣ ឆ្នាំ (២០០៨-២០១០)

• ធានាបំពីអោយការរៀបចំបោះឆ្នោតសកលលើកទី ៤ ដើម្បីបន្តពង្រឹងការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ ។

• ធានាបន្តផ្តល់អាទិភាពដល់ការបង្កើន និង លើកកំពស់សេវាកម្មនៅក្នុងវិស័យសង្គមកិច្ច ជាពិសេស វិស័យអប់រំ និង សុខាភិបាល ។

• ធានាបន្តផ្តល់អាទិភាពដល់ការបង្កើន និង លើកកំពស់សកម្មភាពដែលបំពីអោយវិស័យសេដ្ឋកិច្ច ជាពិសេស វិស័យកសិកម្ម ធារាសាស្ត្រ ការអភិវឌ្ឍន៍ជនបទ និង ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ។

១២- ដើម្បីសំរេចបានតាមគោលដៅនៃគោលនយោបាយខាងលើ រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តន៍បណ្តាគោលនយោបាយ និង កម្មវិធីកែទំរង់សំខាន់ៗ ដូចខាងក្រោម៖

ក. បន្តអនុវត្តនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និង ប្រុងប្រយ័ត្ន គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏សមស្រប ដើម្បីធានាបន្តសំរេចអោយបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និង ប្រកបដោយចិរភាព ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប ។

ខ. បន្តអនុវត្តកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ការឈានទៅសំរេចអោយបាននូវគោលដៅជំហានទី១ គឺការធានាភាពជឿទុកចិត្តបាននៃថវិកា តាមរយៈការបន្តជំរុញការកាត់បន្ថយនិតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបង្កើនភាពគ្រប់ជ្រុងជ្រោយ និង ធ្វើសមាហរណកម្មថវិកា ដើម្បីធានាអោយការបើកផ្តល់ថវិកាបានទាន់ពេលវេលា និង ការកសាងក្របខ័ណ្ឌគោលនយោបាយចំណូលដើម្បីរក្សាស្ថេរភាព និង និរន្តរភាពចំណូល ។ ទន្ទឹមនឹងនេះ បន្តជំរុញការរៀបចំផែនការសកម្មភាព និង បន្តអនុវត្តន៍នូវបណ្តាសកម្មភាពការងារសំរាប់ត្រៀមឈានទៅជំហានទី ២ និង ទី ៣ គឺការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ និង ការពង្រឹងការឆ្លើយតបនៃថវិកាទៅនឹងគោលនយោបាយ ដែលរួមមាន ការបន្តពង្រឹង និង កែលំអការអនុវត្តន៍ប្លង់គណនេយ្យ និង មាតិកាថវិកាថ្មី ការបន្តពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និង ថវិកាតាមកម្មវិធី និង ការបន្តជំរុញការធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដើម្បីអោយស្របទៅនឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈថ្មី ដែលបាន និង កំពុងកសាង និង ដាក់អោយអនុវត្តដោយផ្នែកៗ និង ជាបណ្តើរៗ ក្រោមកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ ។

គ. បន្តអនុវត្តកំណែទម្រង់រចនាសម្ព័ន្ធ ដើម្បីពង្រឹងបរិស្ថានអំណោយផលសម្រាប់ការអភិវឌ្ឍន៍ផ្នែកឯកជន ជាពិសេសលើកស្ទួយវិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម និង ជួយគាំទ្រសហគ្រាសធុនតូច និង មធ្យម ព្រមទាំងជំរុញការសំរួលពាណិជ្ជកម្មតាមរយៈការបង្កើតបញ្ជរតែមួយ និង ជំរុញផ្នែកឯកជនអោយចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធ ដោយនឹងមានច្បាប់សម្បទានធានា ក្នុងខណៈដែលរាជរដ្ឋាភិបាលខ្លួនឯងបាន និង កំពុងទិតទំកសាងដោយផ្ទាល់នូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសប្រព័ន្ធស្រោចស្រព ។ ប្រការទាំងនេះ ទាមទារការពង្រឹងអភិបាលកិច្ចល្អ ពិសេសវិធានការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ការកាត់បន្ថយការិយាធិបតេយ្យ ការអនុវត្តន៍កម្មវិធីសកម្មភាពកំណែទំរង់ច្បាប់ និង ប្រព័ន្ធតុលាការ ការពង្រឹងនីតិរដ្ឋ និង ការពង្រឹងទីផ្សារពលកម្ម ។

ឃ. បន្តអនុវត្តនូវកំណែទម្រង់ការគ្រប់គ្រងដីធ្លី ដើម្បីជួយគាំទ្រដល់វិស័យកសិកម្មអោយសមស្រប តាមច្បាប់ភូមិបាល ដើម្បីឱ្យវិស័យនេះក្លាយទៅជាមូលដ្ឋានរឹងមាំនៃកំណើនសេដ្ឋកិច្ច និង បំពីគោលដៅនៃការ កាត់បន្ថយភាពក្រីក្រ ។

ង. បន្តពង្រឹងប្រព័ន្ធធនាគារ និង វិស័យធានារ៉ាប់រង និង បន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុទាំងមូល ដើម្បី កៀងគរធនធានហិរញ្ញវត្ថុសម្រាប់ការធ្វើហិរញ្ញប្បទានគម្រោងរបស់ផ្នែកឯកជន ។

ច. កសាង និង ពង្រឹងការអនុវត្តន៍ច្បាប់ និង លិខិតបទដ្ឋាននានា ជាពិសេសពង្រឹងចេនាសម្ព័ន ស្ថាប័ន និង បំពេញភាតព្វកិច្ចកម្ពុជា ក្នុងឋានៈជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីទាញ ប្រយោជន៍ពីសមាជិកភាពនេះអោយបានជាអតិបរមា ។

ឆ. បន្តជម្រុញអនុវត្តកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ពិសេស ធានាពង្រឹងសមត្ថភាព រដ្ឋបាលបច្ចេកទេស និង ហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាឃុំ- សង្កាត់ សម្រាប់ការអភិវឌ្ឍន៍មូលដ្ឋាន និង ពង្រីក មូលដ្ឋាននៃការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបវិសហមជ្ឈការ ពិសេសគឺដើម្បីបម្រើឱ្យគោលការណ៍ «រដ្ឋបាលឯក ភាព» ដូចមានកំណត់នៅក្នុងឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ។ ក្នុង កម្មវិធីនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំ និង អនុវត្តផែនការបង្កើនប្រសិទ្ធភាពនៃការផ្ទេរ និង ការផ្តល់ថវិកាជូនមូលនិធិឃុំ- សង្កាត់ រួមមានទាំងលទ្ធភាពនៃការពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារផងដែរ ។ លើសពីនេះទៀត ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបន្តសិក្សាដើម្បីដាក់ឱ្យអនុវត្តសាកល្បងនូវការប្រមូល ចំណូលផ្ទាល់ដោយក្រុមប្រឹក្សាឃុំ- សង្កាត់ ។

ជ. បន្តជម្រុញការអនុវត្តន៍កំណែទម្រង់រដ្ឋបាលសាធារណៈ រួមមានការពង្រីកការអនុវត្តន៍កន្សោម អាទិភាព ជាពិសេស កម្មវិធីផ្តល់លាភការទៅតាមសមត្ថភាព និង លទ្ធផលការងារ និង ការវិភាគមុខងារ ដើម្បីបង្កើនផលិតភាព និង ប្រសិទ្ធភាពការងារ ។

III. ការគណនា និង ទិសដៅថវិកាឆ្នាំ ២០០៨

ក- គំរោងចំណាយថវិកា

១៣- ដើម្បីធានាបាននូវការអនុវត្តន៍ទៅតាមគោលដៅទាំងអស់ខាងលើ និង ដោយផ្អែកលើ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈដែលបានគូសបញ្ជាក់ខាងលើ ថវិកាឆ្នាំ ២០០៨ ត្រូវគ្រោង លើមូលដ្ឋានយុទ្ធសាស្ត្រ និង វិធានការដូចខាងក្រោម៖

- បន្តការរឹតត្បិតចំណាយចរន្ត ជាពិសេស ការបន្តសន្សំសំចៃលើមុខសញ្ញាចំណាយអគ្គិសនី ទូរស័ព្ទ និង ប្រេងឥន្ធនៈ ដើម្បីរក្សាចំណាយសរុបអោយស្ថិតនៅក្នុងកំរិត ១៥,៥% នៃផសស គឺកើនឡើង ប្រមាណ ១% នៃផសស ដែលក្នុងនោះ ចំណាយចរន្តសរុបនឹងត្រូវបានរក្សាអោយនៅត្រឹមប្រមាណ ៩,៧% នៃផសស និង ចំណាយមូលធននឹងត្រូវបានរក្សានៅត្រឹមប្រមាណ ៥,៧% នៃផសស ក្នុងទិសដៅរក្សាអតិរេក ចរន្តក្នុងរង្វង់ ១,២% នៃផសស និងឱនភាពថវិកាសរុបក្នុងរង្វង់ ៤,៣% នៃផសស ។ ដោយឡែក ចំណាយ មូលធនដោយហិរញ្ញប្បទានក្នុងស្រុកត្រូវកំណត់ក្នុងចំនួន ១,១% នៃផសស ហើយចំណាយមូលធនដោយ ហិរញ្ញប្បទានក្រៅប្រទេសត្រូវកំណត់ក្នុងចំនួន ៤,៣% នៃផសស ។ ទន្ទឹមនឹងនេះ ចំណាយសំគប់រំលស់

ចំណុលត្រូវកំណត់ត្រឹម ០,៣% នៃផសស ។ ទន្ទឹមនឹងនេះ រដ្ឋាភិបាលនឹងបន្តគោលនយោបាយឧបត្ថម្ភថ្លៃអគ្គិសនីដល់អ្នកប្រើប្រាស់ ជាពិសេស ចំពោះអ្នកក្រីក្រ តាមរយៈការចេញពន្ធលើតំលៃបន្ថែមជំនួសអគ្គិសនីកម្ពុជា ។

• ត្រូវវិភាជន៍ចំណាយចរន្តទៅតាមវិស័យនីមួយៗដូចតទៅ: វិស័យសង្គមកិច្ចស្មើនឹង ៣,៤% នៃផសស មានកំណើន ១៧% ធៀបនឹងឆ្នាំ ២០០៧ វិស័យសេដ្ឋកិច្ច ០,៨% នៃផសស មានកំណើន ២០% ធៀបនឹងឆ្នាំ ២០០៧ វិស័យរដ្ឋបាលទូទៅ ១,៣% នៃផសស មានកំណើន ១៤% ធៀបនឹងឆ្នាំ ២០០៧ វិស័យការពារជាតិ និង សន្តិសុខ ១,៥% នៃផសស មានកំណើន ១០% ធៀបនឹងឆ្នាំ ២០០៧ និង ថវិកាផ្ទាល់របស់ខេត្ត-ក្រុងប្រមាណ ០,៥% នៃផសស មានកំណើន ៦០% ធៀបនឹងឆ្នាំ ២០០៧ ។

១៤- ថវិកាឆ្នាំ ២០០៨ ខាងមុខនេះ ត្រូវបំពេញគោលនយោបាយរាជរដ្ឋាភិបាល ក្នុងវិស័យសង្គមកិច្ច និង សេដ្ឋកិច្ច និង ការលើកស្ទួយជីវភាពនៅទីជនបទ សំដៅសំរេចនូវការអភិវឌ្ឍន៍ប្រកបដោយចិរភាព និង ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ថវិកាឆ្នាំ ២០០៨ ត្រូវផ្តល់ការវិភាជន៍ជាក់ស្តែងទៅតាមគោលនយោបាយអាទិភាពរបស់វិស័យនីមួយៗដូចខាងក្រោម÷

• បន្តបង្កើនថវិកាសំរាប់វិស័យអប់រំ និង សុខាភិបាលអោយស្របទៅតាមគោលដៅនៃកម្មវិធីចំណាយរយៈពេលមធ្យមសំរាប់វិស័យអប់រំ និង សុខាភិបាលឆ្នាំ ២០០៨-២០១០ ។

• បន្តបង្កើនថវិកាសម្រាប់ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រព ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍន៍កសិកម្ម និង ការអភិវឌ្ឍន៍ជនបទ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញវិស័យសេដ្ឋកិច្ចដើម្បីកំណើន សមធម៌ និង ការកាត់បន្ថយភាពក្រីក្រ ។

• បង្កើនមូលនិធិថវិកាឃុំ-សង្កាត់ឆ្នាំ ២០០៨ ដល់ ២,៧% នៃចំណូលចរន្តថវិកាជាតិឆ្នាំ ២០០៧ ដែលបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ស្របតាមគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ ។

• បន្តផ្តល់អាទិភាពនៃការវិភាជន៍ថវិកាដល់ថវិកាតាមកម្មវិធី និង ផ្អែកលើផែនការយុទ្ធសាស្ត្រថវិកា ដែលបានបញ្ជាក់ពីគោលបំណង ទិសដៅគោលនយោបាយ កម្មវិធី និង/ឬ យុទ្ធសាស្ត្រអាទិភាព ផែនការសកម្មភាព ព្រមទាំងលទ្ធផលរំពឹងទុក និង សូចនាករច្បាស់លាស់ ដើម្បីធានាការអនុវត្តន៍គោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និង បង្កើនប្រសិទ្ធភាពថវិកា ជាពិសេស ការបន្តពង្រឹង និង ការកែលំអការរៀបចំ និង ការអនុវត្តន៍ថវិកាតាមកម្មវិធី ។

ខ- គំរោងចំណូលថវិកា

១៥- ដើម្បីឆ្លើយតបទៅនឹងតំរូវការនៃគំរោងចំណាយខាងលើ ត្រូវបន្តពង្រឹងការគ្រប់គ្រងចំណូល និង ជំរុញការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ជាពិសេស ការកសាងគោលនយោបាយចំណូល និង ការអនុវត្តន៍អោយបានសំរេចទៅតាមផែនការសកម្មភាព និង គោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាសំរេចអោយបាននូវកំរិតចំណូលក្នុងស្រុកសរុបប្រមាណ ១១% នៃផសស គឺមានកំណើន ០,៥% នៃផសស ធៀបនឹងឆ្នាំ ២០០៧ ដែលក្នុងនោះ ចំណូលសារពើពន្ធ

ត្រូវសំរេចអោយបាន ៩,១% នៃផសស គឺមានកំណើន ០,៤% នៃផសស ធៀបនឹងឆ្នាំ ២០០៧ ចំណូលមិនមែនសារពើពន្ធត្រូវសំរេចអោយបាន ១,៧% នៃផសស ស្មើនឹងឆ្នាំ ២០០៧ និង ចំណូលមូលធនក្នុងស្រុកត្រូវសំរេចអោយបាន ០,៣% នៃផសស គឺមានកំណើន ០,២% ធៀបនឹងឆ្នាំ ២០០៧ ។

១៦- ដើម្បីសំរេចបានតាមគោលដៅនៃការប្រមូលចំណូលសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨ ដែលបានកំណត់ខាងលើនេះ ត្រូវបន្តអនុវត្តសកម្មភាពការងារ និង បណ្តាវិធានការទាំងឡាយនៅក្នុងកម្មវិធីសកម្មភាពកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ត្រូវផ្តោតទៅលើបណ្តាវិធានការសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

ទី១- ផ្នែកចំណូលពន្ធដារៈ

- បន្តពង្រឹង និង កែលំអរដ្ឋបាលពន្ធដារ ពង្រឹងការងារសវនកម្មពន្ធ ពង្រីកមូលដ្ឋានយកពន្ធ បង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធ និង ការធ្វើវិចារណកម្មប្រព័ន្ធលើកទឹកចិត្ត ។

- បន្តពង្រឹងការអនុវត្តន៍កម្មវិធីកែលំអរចនាសម្ព័ន្ធ ជាពិសេស ការពង្រឹងការអនុវត្តន៍តួនាទី ភារកិច្ច និង ប្រតិបត្តិការរបស់នាយកដ្ឋានពន្ធដារ ស្របតាមប្រកាសស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃនាយកដ្ឋានពន្ធដារ ។

- បន្តបញ្ចប់ការកសាង និង ចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន ជាពិសេស ខាងផ្នែកប្រមូលពន្ធ ដូចជាការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម និង ការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា ។

- បន្តពង្រឹងការអនុវត្តន៍អោយបានគ្រប់ជ្រុងជ្រោយ និង ឱ្យបានហ្មត់ចត់នូវរាល់បទប្បញ្ញត្តិទាំងឡាយ នៃច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និង វិសោធនកម្មទាំងឡាយនៃច្បាប់នេះ ។

- បន្តអនុវត្តគោលនយោបាយពង្រីកមូលដ្ឋានយកពន្ធ តាមរយៈការពង្រីក និង ពង្រឹងការអនុវត្តន៍របបពិតនៅតាមបណ្តា ខេត្ត- ក្រុង និង បន្តពង្រឹងសវនកម្មលើអ្នកបង់ពន្ធតាមរបបម៉ៅការ ។

- បន្តបណ្តុះបណ្តាល និង បង្កើនសមត្ថភាពវិជ្ជាជីវៈ និង សីលធម៌របស់មន្ត្រីពន្ធដារ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និង រដ្ឋបាលពន្ធដារឱ្យបានរឹងមាំ ក្នុងគោលដៅគ្រប់គ្រងឱ្យបានល្អនូវអ្នកបង់ពន្ធធំ និង មធ្យម ។

- បន្តពង្រឹងលិខិតបទដ្ឋានស្តីពីពន្ធក្នុងវិស័យប្រេង និង ឧស្ម័ន ដើម្បីធានាឱ្យបាននូវការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាពពីវិស័យនេះ ជាពិសេស ការបន្តពិនិត្យពិចារណាលើការធ្វើវិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) ដើម្បីរៀបចំបញ្ចូលពន្ធលើប្រេង និង ឧស្ម័ន ។

- បន្តធ្វើការសិក្សាអំពីវិចារណកម្មបន្ត និង លទ្ធភាពវិសោធនកម្មបន្តលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និង បណ្តាច្បាប់ពាក់ព័ន្ធ ក្នុងគោលដៅបង្កើនចំណូលថវិកាជាតិ ។

- បន្តពង្រឹងអភិបាលកិច្ចរបស់នាយកដ្ឋានពន្ធដារ ។

ទី២- ផ្នែកចំណូលពន្ធគយៈ

- ជំរុញការអនុម័តសេចក្តីព្រាងច្បាប់គយ និង ត្រៀមរៀបចំឱ្យបានចប់សព្វគ្រប់នូវលិខិតបទដ្ឋានដើម្បីជំរុញការអនុវត្តន៍ច្បាប់នេះ ។

- បន្តកែលំអនីតិវិធីក្នុងការគ្រប់គ្រងអ្នកនាំទំនិញចេញ- ចូល ដោយតម្រូវឱ្យមានការរៀបចំជាក្រុម-ហ៊ុននាំចេញ- ចូល និង ក្រុមហ៊ុនជើងសារច្បាស់លាស់ ដើម្បីធានានូវតម្លាភាព និង ភាពងាយស្រួល ក្នុងការត្រួតពិនិត្យ និង ក្នុងការយកពន្ធ និង អាករផ្សេងៗ ។

- បន្តរៀបចំកែលំអ និងដាក់អោយអនុវត្តនូវរចនាសម្ព័ន្ធចាត់តាំងថ្មីរបស់ទីចាត់ការគយ និងរដ្ឋាករ ។

- អនុវត្តវិធានការតឹងរឹងក្នុងការបង្កើនចំណូលពន្ធគយរួមមាន៖

ក. បន្តពង្រឹងការអនុវត្តន៍បណ្តាវិធានការទប់ស្កាត់ និង បង្ក្រាបអំពើរត់គេចពន្ធ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាល អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរដែនដី ។ គណៈកម្មាធិការបង្ក្រាបអំពើរត់ពន្ធ ត្រូវបន្តពង្រឹងការអនុវត្តន៍ការងាររបស់ខ្លួនឱ្យកាន់តែខ្លាំងក្លា និង ប្រកបដោយប្រសិទ្ធភាពថែមទៀត ក្នុងការទប់ស្កាត់ និង បង្ក្រាបអំពើរត់គេចពន្ធ ។ ក្នុងការអនុវត្តន៍ភារកិច្ចនេះ ត្រូវយកចិត្តទុកដាក់ ជាពិសេស លើវិធានការកែលំអផែនការសកម្មភាពបង្ក្រាបអំពើរត់ពន្ធ ដោយផ្តោតលើមុខទំនិញមួយចំនួនដែលមានវេយិទភាព ដូចជា ប្រេងឥន្ធនៈ មធ្យោបាយដឹកជញ្ជូនបរិក្ខារ អេឡិចត្រូនិច និង ការដាក់ចេញនូវនីតិវិធីត្រួតពិនិត្យថ្មី ។

ខ. បន្តពង្រឹងការសហការជាមួយនាយកដ្ឋានពន្ធដារក្នុងការចែករំលែក និង ផ្លាស់ប្តូរពត៌មាន រួមទាំងការប្រើប្រាស់មធ្យោបាយអេឡិចត្រូនិចស្តីពីសហគ្រាសធំៗ ដើម្បីពង្រឹងវិន័យ និង កាតព្វកិច្ចពន្ធដារ ។

គ. បន្តរិះរក និង ដាក់អោយអនុវត្តនូវវិធានការច្បាស់លាស់ និង ទន់ភ្លន់ លើមុខទំនិញមួយចំនួនដើម្បីរក្សាប្រភពចំណូល ។

- បន្តអនុវត្តយ៉ាងហ្មឹងម៉ាត់នូវវិធានការពង្រឹងស្ថាប័នគយ និង រដ្ឋាករ មានជាអាទិ៍ៈ បន្តការបណ្តុះ-បណ្តាល និង ការបង្កើនសមត្ថភាពវិជ្ជាជីវៈ ការបំពាក់ឧបករណ៍ការងារ និង សីលធម៌របស់មន្ត្រីគយ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និង រដ្ឋបាលគយ ឱ្យបានរឹងមាំ ។

- បន្តពង្រឹង និង កែលំអរដ្ឋបាលគយ តាមរយៈការជំរុញអនុវត្តស្វ័យប្រវត្តិកម្មនីតិវិធីគយ និងយន្តការគ្រប់គ្រងហានិភ័យ ដើម្បីកែលំអប្រព័ន្ធការងារ បង្កើនប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និង លើកកំពស់គុណភាពសេវាកម្មជូនដល់អតិថិជន ។

- បន្តពង្រឹងយន្តការអធិការកិច្ចមុនពេលផ្ទុក ការត្រួតពិនិត្យទំនិញ ការត្រួតពិនិត្យនាវាឆ្លងកាត់ការបញ្ជូនទំនិញ ការធ្វើអធិការកិច្ចនៅនឹងកន្លែង និង ការប្រមូលចំណូល ។

- បន្តពង្រឹងអភិបាលកិច្ចរបស់រដ្ឋបាលគយ និង រដ្ឋាករ ។

ទី៣- ផ្នែកចំណូលមិនមែនសារពើពន្ធ:

- បន្តជំរុញការអនុវត្តន៍ឱ្យមានប្រសិទ្ធភាពនូវច្បាប់ និង លិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ពិសេសបទបញ្ជារបស់នាយករដ្ឋមន្ត្រី លេខ ០២ បប ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

- បន្តស្រាវជ្រាវ និង កំណត់ឱ្យបានច្បាស់នូវបំណុលពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ ហើយបន្ត ជំរុញការអនុវត្តន៍នូវផែនការសកម្មភាព និង បណ្តាវិធានការ ដើម្បីតឹងទារបំណុលទាំងអស់នេះតាមគ្រប់ មុខសញ្ញាទាំងអស់ ។ ក្នុងនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ ជាពិសេសទៅលើការគ្រប់គ្រងចំណូល

ពីប្រៃសណីយ៍ និង ទូរគមនាគមន៍ អាកាសចរណ៍ស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលទិដ្ឋាការ និង ចំណូលពីការជួលរោងចក្រសហគ្រាស និង ទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត ។

- បន្តជំរុញដើម្បីបញ្ចប់ការងារធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ហើយចាប់ផ្តើមធ្វើបញ្ជីសារពើភ័ណ្ឌដីរបស់រដ្ឋជាបណ្តើរៗ ដើម្បីពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង ការប្រមូលចំណូល។

- បន្តពង្រឹងការគ្រប់គ្រងចំណូលពីផលទុនប្រៃសណីយ៍ និង ទូរគមនាគមន៍ តាមរយៈការពង្រឹងយន្តការតឹងទារចំណូល ដោយតំរូវឱ្យក្រុមហ៊ុនទូរស័ព្ទទាំងអស់បង់ចំណូលដោយត្រង់ទៅក្នុងគណនីរបស់រាជរដ្ឋាភិបាលនៅធនាគារជាតិ ហើយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ការបង់ចំណូលនេះ ។

១៧- ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ នេះ គឺជាឧបករណ៍ដ៏សំខាន់បំផុតសំរាប់ឈានទៅសម្រេចឱ្យបាននូវបណ្តាគោលដៅជាអាទិភាពខាងលើ ។ នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលា នូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ។ នៅក្នុងកិច្ចដំណើរការនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមការចរចា និង ពិភាក្សារៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ជាមួយក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុងទាំងអស់ចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៧ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៧ ។ ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ និង ធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ហើយផ្ញើជូនគណៈរដ្ឋមន្ត្រីអោយបាននៅក្នុងសប្តាហ៍ទី១ នៃ ខែតុលា ឆ្នាំ ២០០៧ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និង សំរេច ហើយផ្ញើជូនរដ្ឋសភាអោយបានក្នុងសប្តាហ៍ទី១ នៃ ខែវិច្ឆិកា ឆ្នាំ ២០០៧ ដើម្បីស្ថាប័ននីតិប្បញ្ញត្តិមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យ ពិភាក្សា និង អនុម័តសេចក្តីព្រាងច្បាប់នេះអោយបានមុនថ្ងៃ ២៥ ខែធ្នូ ២០០៧ ។

គ- បណ្តាបញ្ហាប្រឈមក្នុងការអនុវត្តន៍ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨

១៨- ទោះជាត្រូវបាន និង កំពុងតែធ្វើអោយប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ លើការគ្រប់គ្រងចំណូល និង ចំណាយ តាមរយៈការអនុវត្តន៍កម្មវិធីកែទំរង់ការគ្រប់គងហិរញ្ញវត្ថុសាធារណៈ ក្នុងរយៈកាលពីរឆ្នាំកន្លងទៅក៏ដោយ រាជរដ្ឋាភិបាលនៅតែបន្តប្រឈមមុខនឹងបញ្ហាមួយចំនួន ជាពិសេស ភាពចាំបាច់ក្នុងការបង្កើនចំណូល ដើម្បីសងបំណុលចាស់ផង និង ដើម្បីបំពេញតម្រូវការចំណាយ ដែលចេះតែកើនឡើងជាលំដាប់ផង ដែលរួមមានដូចជាៈ

ទី១- ការបន្តជំរុញការយកចិត្តទុកដាក់លើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា អោយបានសមស្របដើម្បីធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ហើយពង្រឹងការរៀបចំថវិកាអោយបានគ្រប់ជ្រុងជ្រោយ និង សុក្រឹត ដើម្បីកាត់បន្ថយជាអតិបរិមានូវចំណាយមិនបានគ្រោងទុក និង សំដៅបំបាត់ចំណាយក្រៅគម្រោងថវិកា និង ចំណាយដែលមិនចាំបាច់ ដើម្បីសម្រេចបាននូវការគ្រប់គ្រងថវិកាជាតិប្រកបដោយប្រសិទ្ធភាព និង ប្រកបដោយភាពជឿទុកចិត្តបាន ។

ទី២- ការបន្តជំរុញការរៀបចំកម្មវិធីចំណូល- ចំណាយអោយបានសុក្រឹត និង ការអនុវត្តន៍អោយបានហ្មត់ចត់ ដើម្បីជាមូលដ្ឋានក្នុងការកសាងផែនការសាច់ប្រាក់ សំដៅពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ដើម្បីកាត់បន្ថយបំណុលសាច់ប្រាក់កកស្ទះនៅរតនាគារ ក្នុងគោលដៅបង្កើនភាពជឿទុកចិត្តបាននៃការអនុវត្តន៍ថវិកា ។ លើសពីនេះ ការបង្កើនការគោរពយ៉ាងហ្មត់ចត់នូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ជាពិសេស ចៀសវាងនូវការផ្ទេរឥណទានថវិកាដែលនៅសល់ទៅឆ្នាំបន្ទាប់ ព្រមទាំងការចេញអាណត្តិបម្រុងទុក និង ការចេញអាណត្តិច្រើនហួសទៅបង្គរនៅរតនាគារជាតិដែលជាប្រការធ្វើឱ្យកើតមានឡើងនូវបំណុលសាច់ប្រាក់ថ្មីទៀត ។

ទី៣- បន្តពង្រឹងការគ្រប់គ្រងបំណុល ជាពិសេស ការកសាងទិន្នន័យ និង ការរៀបចំកម្មវិធីសងបំណុលអោយបានច្បាស់លាស់ និង ដោយផ្សារភ្ជាប់ទៅនឹងក្របខ័ណ្ឌនៃការរៀបចំថវិកា និង ការបន្តអនុវត្តយ៉ាងហ្មត់ចត់នូវការខ្ចីតែឥណទានដែលបំរើអោយគោលនយោបាយអាទិភាព ។

ទី៤- បន្តបង្កើនចំណាយលើវិស័យសង្គមកិច្ច និង សេដ្ឋកិច្ច ជាពិសេស ចំពោះគោលនយោបាយអាទិភាព ដូចជា អប់រំ សុខាភិបាល កសិកម្ម អភិវឌ្ឍន៍ជនបទ និង ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មានផ្លូវថ្នល់ ស្ពាន និង ប្រព័ន្ធស្រោចស្រព ដែលជាគោលបំណងនៃគោលនយោបាយ និង ជាទិសដៅយុទ្ធសាស្ត្រអាទិភាពខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលនីតិកាលទី ៣ នៃរដ្ឋសភា ។

III- និតិវិធី និង បច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០០៨

ក- ការគ្រោងចំណូលថវិកាឆ្នាំ ២០០៨

១៩- ការគ្រោងគិតចំណូលចរន្តរបស់ថវិកា អាស្រ័យលើប្រភពធនធាននៃផលិតផល ឬ ផលទុនដែលជាប្រភពចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និង បណ្តាលក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ÷

- ចំណូលសារពើពន្ធត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ÷
  - លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
  - ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ
  - ការប៉ាន់ស្មានលើការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅពេលខាងមុខ
  - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និង ពិចារណាទៅលើអត្រា និង មូលដ្ឋានប្រមូលពន្ធ
  - ចំណូលបន្ថែមដែលសង្ឃឹមថាប្រមូលបាន ដោយសារការពង្រឹង និង កែលំអរដ្ឋបាល និង គោលនយោបាយពន្ធដារ គយ និង រដ្ឋាគរ ការធ្វើវិចារណកម្មសារពើពន្ធ និង ការប្រមូលបំណុលពន្ធដែលត្រូវទារ ។

- ចំពោះចំណូលពុំមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឱ្យមានផលទុន ដូចជា កិច្ចសន្យាជួលសេវាកម្ម ការពង្រឹង និង កែលំអការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម ។ល។

ចំណូលទាំងអស់នេះ ត្រូវផ្អែកលើមូលដ្ឋានតួរលេខស្ថិតិដែលសំរេចបានទៅក្នុងឆ្នាំកន្លងមក និងការ-អភិវឌ្ឍន៍សេដ្ឋកិច្ច ។ *គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ទាំងអស់ ត្រូវរៀបចំគំរោងចំណូលនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអោយបានត្រឹមថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៧* ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ត្រូវរៀបចំកិច្ចប្រជុំពិភាក្សាកំរិតជំនាញលើគំរោងចំណូលនេះជា មួយគ្រប់ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញ ខេត្ត-ក្រុង និង ធ្វើការបូកសរុបអោយបានចប់សព្វគ្រប់មុនការចាប់ផ្តើមចរចាថវិកានៅដើមខែសីហា ។

ខ-ការគ្រោងចំណាយថវិកាឆ្នាំ ២០០៨

២០- ការរៀបចំគំរោងឥណទានចំណាយថវិកា ត្រូវផ្អែកលើផែនការយុទ្ធសាស្ត្រថវិកា ដែលបានផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីគណនាតំរូវការថវិកាដោយលំអិតទៅតាម ជំពូក គណនី និង អនុគណនី និង ទៅតាមនាយកដ្ឋាន និង អង្គភាព ឬ ផ្នែកនីមួយៗ ដែលចំណុះអោយក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង (តាមគំរូដែលភ្ជាប់មកជាមួយស្រាប់) ដោយផ្អែកលើតំរូវការជាក់ស្តែង និង ដោយផ្ទាល់ សំរាប់បំពេញអោយការអនុវត្តន៍កម្មវិធីសកម្មភាពចាំបាច់ ដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។ រីឯការគណនាឥណទានចំណាយ ត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជាតារាងបុគ្គលិក បញ្ជីប៉ាន់ស្មានតំលៃសំភារៈនៃការផ្គត់ផ្គង់ និង ត្រូវផ្អែកទៅតាមធម្មនិយាមចំណាយ ដែលបានកំណត់នៅក្នុងប្រកាស ឬ សេចក្តីណែនាំ ដូចជា ចំណាយបេសកកម្ម ចំណាយមធ្យមភាគលើគ្រែមួយរបស់អ្នកជំងឺនៅមន្ទីរពេទ្យ ចំណាយខាងការសិក្សា សំរាប់សិស្ស ឬ និស្សិតម្នាក់ ឬ ត្រូវផ្អែកទៅតាមតួលេខស្ថិតិជាមធ្យមភាគរបស់គណនេយ្យថវិកាសំរាប់ការគ្រប់គ្រងកន្លងមក ។ ជាពិសេស តំរូវការចំណាយនីមួយៗត្រូវមានការវិភាគយ៉ាងល្អិតល្អន់ និង មានឯកសារគាំទ្រភ្ជាប់មកជាមួយ ដើម្បីពន្យល់ទៅតាមជំពូក គណនី និង អនុគណនីនីមួយៗ ។

គ- ការកំណត់កញ្ចប់ថវិកាឆ្នាំ ២០០៨

២១- រាជរដ្ឋាភិបាលបានធ្វើការកំណត់នូវកញ្ចប់ថវិកា ដោយកំណត់គោលការណ៍ចំណាយទៅតាមប្រភេទ និង ជំពូក ដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ថវិកា សំរាប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ធ្វើជាមូលដ្ឋានក្នុងការរៀបចំគំរោងចំណាយលំអិតទៅតាម គណនី និង អនុគណនី និង ទៅតាមនាយកដ្ឋាន និង អង្គភាព ឬ ផ្នែកនីមួយៗ ដែលចំណុះអោយក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ដើម្បីបំពេញអោយតំរូវការជាក់ស្តែងក្នុងការអនុវត្តន៍កម្មវិធីសកម្មភាពចាំបាច់ ដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។ ដូចជាឆ្នាំមុនៗដែរ ក្នុងរយៈពេលអនុវត្តថវិកានៃត្រីមាសទី ១ ឆ្នាំ ២០០៨ នេះ នឹងមិនមានការអនុញ្ញាតឱ្យធ្វើនិយ័តភាពផ្ទៃក្នុងថវិការបស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញ នៅតាមខេត្ត-ក្រុងទេ ។

២២- ក្រសួង-ស្ថាប័ននិងមន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវគ្រោងចំណាយទៅតាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា និង បណ្តាវិធានការដូចខាងក្រោម៖

ក- ចំណាយបន្ទុកបុគ្គលិក ត្រូវគ្រោងដោយបង្កើន ២០% លើបៀវត្សមូលដ្ឋាន ទៅតាមតារាងប្រព័ន្ធប្រាក់បៀវត្សថ្មីនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និង តាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០០៧ ។ ចំពោះចំនួនមន្ត្រីរាជការបន្ថែមថ្មី ត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និង តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង ដែលមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬ លាឈប់ពីក្របខ័ណ្ឌរដ្ឋ និង មរណៈភាព ត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន ។ ប្រសិនបើមានការតម្លើងឋានៈ ឬ មានមន្ត្រីថ្មី ត្រូវគ្រោងដោយឡែក ។ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង មិនត្រូវគិតអតិថិជនណានៅក្នុងចំណាយបៀវត្សនេះទេ ។ ចំពោះ បុគ្គលិកអណ្តែត និង ភ្នាក់ងារជាតិជាប់កិច្ចសន្យា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវស្នើសុំការធានា ចំណាយថវិកាពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាមុន មុននឹងចេញលិខិតអនុញ្ញាតឱ្យក្រសួង -ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ជ្រើសរើស និង ប្រើប្រាស់ ។

ខ- ចំណាយដំណើរការលើការទិញ និង សេវា ត្រូវគ្រោងប្រកបដោយលក្ខណៈត្បិតត្បៀត និង សន្សំសំចៃបំផុត ជាពិសេស ចំពោះសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សំភារៈការិយាល័យ ប្រេងឥន្ធនៈ និង ការទទួលភ្ញៀវ មិនត្រូវបង្កើនចំណាយលើសពីឆ្នាំកំពុងអនុវត្តទេ ។ នៅពេលអនុវត្តថវិកា ហាមដាច់ខាតមិនអោយមានចំណាយលើសពីឥណទានថវិកាដែលបានគ្រោងសំរាប់មុខសញ្ញានេះ និង ហាមដាច់ខាតមិនឱ្យមានការជំពាក់បំណុលដោយខ្ចីទំនិញ ឬ សេវាមកប្រើប្រាស់នៅក្រៅបរិបថនៃថវិកាទេ ។ កន្លងមកចំណាយសំរាប់មុខសញ្ញាអគ្គិសនី ទូរស័ព្ទ ទឹក ប្រេងឥន្ធនៈ និង ការទទួលភ្ញៀវមានលក្ខណៈខ្ជះខ្ជាយ ។ ចំណាយសំរាប់មុខសញ្ញាទាំងនេះចេះតែកើនឡើង ហើយការទូទាត់មិនបានទាន់ពេលវេលាដែលនាំអោយមានបំណុលកកស្ទះពីមួយឆ្នាំទៅមួយឆ្នាំ ។ ដើម្បីដោះស្រាយបញ្ហានេះ ចំពោះចំណាយអគ្គិសនី ទូរស័ព្ទ និង ទឹក ត្រូវអនុវត្តនូវវិធានការដូចខាងក្រោមៈ

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នទាំងអស់ ត្រូវសហការត្រួតពិនិត្យលើការប្រើប្រាស់បច្ចុប្បន្ន ដើម្បីរៀបចំយន្តការ និង ប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និង ទឹក អោយបានត្រឹមត្រូវ ម៉ត់ចត់ និង ប្រកបដោយប្រសិទ្ធភាព ។ ក្នុងករណីរកឃើញការលួចបន្តចរន្តអគ្គិសនី ទូរស័ព្ទ និង ទឹក ប្រើបាស់ផ្ទាល់ខ្លួនខុសមុខសញ្ញា របស់ក្រសួង ស្ថាប័នណាមួយ រដ្ឋមន្ត្រីក្រសួងនោះជាអ្នកទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី និង ចំពោះមុខរដ្ឋសភា ។ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និង ក្រុមហ៊ុនទូរស័ព្ទ ត្រូវកាត់ផ្តាច់បណ្តាញលួចលាក់ទាំងនោះភ្លាម ហើយធ្វើរបាយការណ៍ជូនក្រសួងអាណាព្យាបាលបច្ចេកទេស និង ក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ និង ចំលងជូនទីស្តីការគណៈរដ្ឋមន្ត្រី ។

-. ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នទាំងអស់ ត្រូវសហការគ្រោងឥណទានសំរាប់អគ្គិសនី ទូរស័ព្ទ និង ទឹក ប្រកបដោយភាពសន្សំសំចៃខ្ពស់ ដោយយកចំណាយជាក់ស្តែងពីឆ្នាំមុនធ្វើជាពិដាន ហើយកាត់បន្ថយចំណាយមុខសញ្ញានេះអោយចុះមកនៅក្នុងកំរិតមួយសមស្រប តាមការចាំបាច់ពិតប្រាកដរបស់ក្រសួងស្ថាប័ន ។

- ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និង ក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទ ត្រូវផ្តល់វិក័យប័ត្រប្រចាំខែនីមួយៗ អោយបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់ ។ ក្រសួង-ស្ថាប័ន និង

មន្ទីរជំនាញខេត្ត- ក្រុងទាំងអស់ត្រូវធ្វើការផ្ទៀងផ្ទាត់វិក័យប័ត្រ និង រៀបចំទូទាត់អោយបានទៀងទាត់ និង ទាន់ពេលវេលារៀងរាល់ខែ ។ ហាមដាច់ខាតមិនអោយមានការពន្យាការទូទាត់លើមុខសញ្ញាចំណាយនេះ ដោយយកឥណទាននេះទៅប្រើប្រាស់លើមុខសញ្ញាផ្សេង ហើយផ្ទេរបន្ទុកនេះមកលើថវិការួមទេ ។

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវស្នើឡើងនូវវិធានការជាក់លាក់ ក្នុងការត្រួតពិនិត្យ និង គ្រប់គ្រងការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និង ទឹក ដើម្បីដាក់ជូនប្រមុខនៃរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ហើយដាក់ឱ្យគ្រប់ក្រសួង- ស្ថាប័នរបស់រាជរដ្ឋាភិបាលអនុវត្តឱ្យបានខ្ជាប់ខ្ជួន និង ហ្មឺងម៉ាត់បំផុត ។

គ- ចំពោះចំណាយសំរាប់ជំពូក គណនី និង អនុគណនីផ្សេងៗទៀត ត្រូវគ្រោងទៅតាមតំរូវការ ចាំបាច់ដោយផ្អែកលើមូលដ្ឋានផែនការសកម្មភាពដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ក្នុងករណី តំរូវអោយមានកំណើន ដោយមានការវិភាគ និង ពន្យល់ច្បាស់លាស់ ក៏កំណើននោះមិនត្រូវអោយលើសពី ៣% នៃកញ្ចប់ថវិកាដែលបានអនុម័តឆ្នាំ ២០០៧ ដែរ ។ ចំពោះក្រសួងដែលត្រូវបន្ត ឬ ចាប់ផ្តើមអនុវត្ត សាកល្បងថវិកាតាមកម្មវិធី ត្រូវញែកគំរោងចំណាយជាពីរផ្នែកសំរាប់ថវិកាតាមកម្មវិធី និង ថវិកាតាមមាតិកា ទៅតាមគ្រប់ជំពូក គណនី និង អនុគណនីនីមួយៗ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវអញ្ជើញក្រសួងទាំង នេះមកការពារគំរោងថវិកាតាមកម្មវិធីដោយឡែក ។

ឃ- ឯកសារផែនការយុទ្ធសាស្ត្រថវិកា គំរោងចំណូល និង គំរោងចំណាយថវិកា ដែលក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺជាមូលដ្ឋានសំរាប់ការពិភាក្សា នៅក្នុងកិច្ចប្រជុំការពារថវិកា ដើម្បីការពារកញ្ចប់ថវិការបស់ខ្លួន ។ ដូច្នេះ ក្នុងករណីដែលក្រសួង ស្ថាប័ន ឬ មន្ទីរជំនាញខេត្ត- ក្រុង ដែលមិនបានបំពេញ និង ផ្តល់ពត៌មានគ្រប់គ្រាន់សំរាប់ការប្រជុំការពារថវិកាទេនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវជូនពត៌មានទៅអង្គភាពអោយបានទាន់ពេលវេលា ដើម្បីបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការ យកមូលដ្ឋាននៃថវិកាឆ្នាំ ២០០៧ ហើយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូក គណនី និង អនុគណនីខាង លើ សំរាប់កំណត់គំរោងថវិការបស់អង្គភាពនោះ ដើម្បីជាមូលដ្ឋានសំរាប់ការប្រជុំការពារថវិកា និង រៀបចំ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុអោយបានទាន់ពេលវេលា ។

ឃ- ការរៀបចំ និង ការវិភាគសំណើនានា

២៣- ថវិកាកំពុងប្រព្រឹត្តទៅឆ្នាំ (ក-1) ឆ្នាំ ២០០៧ តាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកម/១២០៦ /០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ត្រូវធ្វើជាមូលដ្ឋាននៃការរៀបចំថវិកាឆ្នាំ ២០០៨ ឆ្នាំ (ក) ដើម្បីធានាឱ្យសេវាសាធារណៈនានាអាចដំណើរការ ទៅបាន ។ ក្រសួង- ស្ថាប័ន ត្រូវតែផ្អែកលើថវិកានៃឆ្នាំកំពុងប្រព្រឹត្តទៅ និង ការណែនាំទាំងឡាយខាងលើនេះ សម្រាប់ធ្វើជាមូលដ្ឋាន ដោយគ្រាន់តែសម្រួលទៅតាមតំរូវការចាំបាច់ដែលទាក់ទងទៅនឹងបណ្តាមូលហេតុ ដូចខាងក្រោម៖

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងប្រព្រឹត្តដូចជា:
  - ការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬ ពីជំពូកមួយទៅជំពូកមួយទៀត ដែលធ្វើឱ្យការបែង ចែកឥណទានដើមនៃក្រសួង- ស្ថាប័ន ព្រមទាំងមន្ទីរជំនាញខេត្ត- ក្រុងមានការប្រែប្រួល ។

- ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ។
- ផលប៉ះពាល់ជាយថាហេតុនៃអតិផរណានៅក្នុងឆ្នាំទៅលើថ្លៃនៃផលិតផលចាំបាច់ ដូចជា អគ្គិសនី ទឹក ប្រេងឥន្ធនៈ សោហ៊ុយដឹកជញ្ជូន និង ចំណាយរដ្ឋបាល ។ ល ។

២៤- គំរោងថវិការបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ត្រូវតែបញ្ជាក់នូវមូលហេតុច្បាស់លាស់ ដូចមានចែងខាងលើនេះ ហើយរាល់សំណើបន្ថែមត្រូវតែមានការពន្យល់បញ្ជាក់ភ្ជាប់មកជាមួយនូវរាល់កង្វះខាតឥណទានថវិកានៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ ដែលអាចយកមកពិភាក្សាបាន លុះត្រាតែមាននៅក្នុងក្របខ័ណ្ឌកម្មវិធីសកម្មភាពនៃឆ្នាំផែនការ ។

២៥- ឥណទានថវិកាដែលបានគិតគូរដោយផ្អែកលើមូលដ្ឋានខាងលើនេះ នឹងមានការប្រែប្រួលអាស្រ័យដោយមានការពង្រីកសកម្មភាពនៃឆ្នាំកំពុងប្រព្រឹត្តទៅ ឬ មានកម្មវិធីសកម្មភាពថ្មី ដែលត្រូវចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំនៃផែនការ ។

២៦- បច្ចេកទេសវិភាគដ៏ទៃទៀត គឺយកចំណាយថវិកាឆ្នាំមុន ដូចជា ចំណាយដំណើរការរដ្ឋបាលសម្រាប់មន្ត្រីរាជការម្នាក់ៗ ទ្រង់ទ្រាយនៃចំណាយ ប្រភពនៃចំណាយ និង អត្ថប្រយោជន៍នៃចំណាយចាំបាច់មួយចំនួន សម្រាប់ធ្វើជាមូលដ្ឋានគ្រោងគិតសម្រាប់ឆ្នាំផែនការ ។ ជាពិសេស ឥណទានថវិកាចាំបាច់របស់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុងនីមួយៗ ត្រូវតែបំពីទៅលើ÷

- គោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ក្រសួង- ស្ថាប័ន និង មន្ទីរ ជំនាញខេត្ត- ក្រុងនីមួយៗ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា
- កម្មវិធី និង យុទ្ធសាស្ត្រអាទិភាពដែលបានកំណត់ច្បាស់លាស់ ដើម្បីសំរេចបាននូវគោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ខ្លួន
- ផែនការសកម្មភាព និង រាល់មធ្យោបាយដំណើការ ដើម្បីអនុវត្តកម្មវិធី និង យុទ្ធសាស្ត្រអាទិភាព
- ការគ្រប់គ្រង ការតាមដាន ការវាយតំលៃ និង ការធ្វើរបាយការណ៍ដើម្បីបង្ហាញពីលទ្ធផលនៃការអនុវត្តន៍កម្មវិធី និង យុទ្ធសាស្ត្រអាទិភាព ដែលជាមូលដ្ឋានសំរាប់សំរេចបានគោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ខ្លួន ។

IV- សេចក្តីសន្និដ្ឋាន

២៧- ដើម្បីសំរេចបានតាមគោលដៅ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង ជាពិសេស ការបន្តអនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** របស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យ ការរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និង កំណើនខ្ពស់ជាមធ្យម ពី ៦ ទៅ ៧ ភាគរយ ប្រកបដោយចិរភាពគឺជាធនធានចាំបាច់ និង មិនអាចខ្វះបាន ។ ដើម្បីអោយធនធាននេះអាចប្រើប្រាស់ប្រកបដោយភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពខ្ពស់ នោះគឺ ទាមទារអោយគ្រប់ក្រសួង- ស្ថាប័នទាំងអស់

ត្រូវមានគោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ខ្លួនយ៉ាងច្បាស់លាស់ ដែលផ្សារភ្ជាប់ទៅនឹង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** មានកម្មវិធី និង យុទ្ធសាស្ត្រអាទិភាពជាក់លាក់ ព្រមទាំងផែនការសកម្មភាពត្រឹមត្រូវក្នុងការអនុវត្តន៍ឆ្ពោះទៅសំរេចអោយបាននូវគោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ខ្លួន ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញការលើកកំពស់អភិបាលកិច្ចល្អ តាមរយៈកម្មវិធីកែទំរង់ស៊ីជំរៅលើគ្រប់វិស័យ ជាពិសេស ការកែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ការកែទំរង់រដ្ឋបាលសាធារណៈ និង ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទំរង់កងកម្លាំងប្រដាប់អាវុធ និង ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។

២៨- ពេលទទួលសារាចរណែនាំនេះ ***គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវរៀបចំជាបន្ទាន់នូវតំរោងចំណូល-ចំណាយថវិការបស់ខ្លួន សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ចំនួនពីរច្បាប់យ៉ាងយូរ បំផុតត្រឹមថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៧*** ដើម្បីមានពេលវេលាគ្រប់គ្រាន់សំរាប់ការពិភាក្សាកំរិតជំនាញ និង បូកសរុបសំរាប់ការចរចាចាប់ពីថ្ងៃទី ០១ ដល់ ៣១ ខែសីហា ឆ្នាំ ២០០៧ ។ តួរលេខតំរោងចំណូល-ចំណាយ ថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1.2.3) ហើយឯកតាទាបបំផុតគិតត្រឹម 0.1 លានរៀល ។

២៩- ក្នុងការអនុវត្តន៍សារាចរណែនាំនេះ បើក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងមានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>**កន្លែងទទួល**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា

"ដើម្បីជូនជ្រាប"

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់អភិបាលខេត្ត-ក្រុង
- គ្រប់មន្ទីរជំនាញខេត្ត-ក្រុង

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: [illegible] សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៧

សូមគោរពជូន

សម្តេចនាយករដ្ឋមន្ត្រី

កម្មវត្ថុ: សំណើសុំពិនិត្យសំរេចលើសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨

យោង: - ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ ថ្មី នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦ /០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ។

- សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ ២០០៨ ចុះថ្ងៃទី ១៣ មេសា ឆ្នាំ ២០០៧ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបសម្តេចនាយករដ្ឋមន្ត្រីមេត្តាជ្រាបថា: ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ អោយបានទាន់ពេលកំណត់ ជាពិសេស ដើម្បីអោយក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ មានពេលវេលាគ្រប់គ្រាន់សំរាប់រៀបចំគំរោងចំណូល-ចំណាយរបស់ខ្លួន ប្រកបដោយសុក្រឹតភាព និង ប្រសិទ្ធភាព មាត្រា ២៦ ថ្មី នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុតំរូវអោយចេញសារាចរណែនាំនេះនៅក្នុងសប្តាហ៍ទី១ នៃខែ មិថុនា ។

អាស្រ័យហេតុនេះ សូមសម្តេចនាយករដ្ឋមន្ត្រី មេត្តាពិនិត្យសំរេច និង ចុះហត្ថលេខាដ៏ខ្ពង់ខ្ពស់លើសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ដូចមានជូនភ្ជាប់មកជាមួយនេះ ដើម្បីអោយក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានមូលដ្ឋានក្នុងការចាប់ផ្តើមរៀបចំគំរោងចំណូល-ចំណាយ ហើយចរចារ និង ពិភាក្សារៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ អោយបានទាន់ពេលវេលា ។

សូមសម្តេចនាយករដ្ឋមន្ត្រី មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតរបស់ខ្ញុំ

8-6-2007

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៤៦៥.....សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ ២០០៧

ប្រកាស
ស្តីពី
ការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជា ឆ្នាំ២០០៧

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/001 ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក.ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០ នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែ ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០២ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥, ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៦
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០៣ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone. 855-23-724 664 Fax: 855-23-427 798

- បានឃើញក្រឹត្យលេខ៥៧ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញ នាំចេញនាំចូល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២*ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ដែលបានប្រកាស ឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០០១
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាអន្តរជាតិ ស្តីពីការធ្វើឱ្យស៊ីចង្វាក់គ្នានៃការកំណត់មុខទំនិញ និងប្រព័ន្ធលេខកូដ
- បានឃើញពិធីសារស្តីពីការអនុវត្តនាមវលី នៃតារាងពន្ធគយស៊ីចង្វាក់គ្នារបស់អាស៊ាន ដែលចុះហត្ថលេខា ដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៣ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១ ស្តីពីការកែសម្រួលអត្រាពន្ធ និងអាករគយលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ អាករពិសេស លើទំនិញ និងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ ១ : ដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ២០០៧ ដូចមានភ្ជាប់ជាមួយនេះ ដែលបានរៀបចំដោយអនុលោមតាមប្រព័ន្ធស៊ីចង្វាក់ នៃការកំណត់មុខទំនិញ និងប្រព័ន្ធលេខកូដ និងស្របទៅតាមតារាងពន្ធគយ នៃប្រព័ន្ធស៊ីចង្វាក់របស់អាស៊ាន (AHTN 2007) ចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០០៧ តទៅ ។

ប្រការ ២ : រាល់មុខទំនិញនាំចេញ នាំចូលត្រូវជាប់ពន្ធនាំចូល អាករពិសេស អាករលើតម្លៃបន្ថែម និងអាករនាំចេញ ដូចមានចែងលំអិតក្នុងតារាងពន្ធគយនេះ ។

ប្រការ ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៧ ខាងមុខនេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន ខេត្តក្រុង "ដើម្បីជូនជ្រាប"
- សភាពាណិជ្ជកម្ម
- ទីចាត់ការគយ និងរដ្ឋាករ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ត មកពីរាជកិច្ចលេខ ៥៩ .... ៥៧

Head.	Tariff Code	បរិយាយមុខទំនិញ	Description of Goods	Unit	Duty and Tax (%)				Reference
					Imp.			Exp.	
					CD	ST	VAT	ET	
38.01		ក្រាហ្វិតសិប្បនិម្មិត ក្រាហ្វិតអង្គិល ពាក់កណ្តាលអង្គិល ផលិតផលចេញពីក្រាហ្វិត ឬធ្យូងផ្សេងទៀតក្នុងទំរង់ជាម្សៅខាប់ ដុំ បន្ទះឬផលិតផលពាក់កណ្តាលសំរេច ផ្សេងទៀត ។	Artificial graphite; colloidal or semi - colloidal graphite; preparations based on graphite or other carbon in the form of pastes, blocks, plates or other semi-manufactures.						
	3801.10.00	- ក្រាហ្វិតសិប្បនិម្មិត	- Artificial graphite	kg	7	0	10	0	
	3801.20.00	- ក្រាហ្វិតអង្គិល ឬពាក់កណ្តាលអង្គិល	- Colloidal or semi-colloidal graphite	kg	7	0	10	0	
	3801.30.00	- ម្សៅខាប់ធ្វើពីធ្យូងសំរាប់អេឡិចត្រូដ និងម្សៅខាប់ប្រហាក់ប្រហែលសំរាប់ពាសឡខាងក្នុង	- Carbonaceous pastes for electrodes and similar pastes for furnace linings	kg	7	0	10	0	
	3801.90.00	- ផ្សេងទៀត	- Other	kg	7	0	10	0	
38.02		ធ្យូងធ្វើឱ្យសកម្ម ផលិតផលខនិជធម្មជាតិធ្វើឱ្យសកម្មធ្យូងសត្វ រាប់បញ្ចូលទាំងធ្យូងសត្វកម្រ ។	Activated carbon; activated natural mineral products; animal black, including spent animal black.						
	3802.10.00	- ធ្យូងធ្វើឱ្យសកម្ម	- Activated carbon	kg	7	0	10	0	
	3802.90	- ផ្សេងទៀត :	- Other :						
	3802.90.10	- - បូកស៊ីតធ្វើឱ្យសកម្ម	- - Activated bauxite	kg	7	0	10	0	
	3802.90.20	- ដីឥដ្ឋ និង ដីធ្វើឱ្យសកម្ម	- - Activated clays and activated earths	kg	7	0	10	0	
	3802.90.90	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
38.03	3803.00.00	ប្រេងតាលទោះចំរាញ់ឬមិនទាន់ចំរាញ់ក៏ដោយ	Tall oil, whether or not refined.	kg	7	0	10	0	

38.04		ទឹកក្បុងសំណល់ពីការផលិតម្សៅក្រដាស ទោះខាប់ ឬមិនខាប់ យកស្ករចេញ ឬ ទទួលប្រព្រឹត្តកម្មគីមីរាប់បញ្ចូលទាំងលីញ៉ូនីងស៊ុលហ្វូណាត ប៉ុន្តែមិនរាប់បញ្ចូល ប្រេងតាល់ នៃទីតាំងលេខ ៣៨.០៣ ។	Residual lyes from the manufacture of wood pulp, whether or not concentrated, desugared or chemically treated, including lignin sulphonates, but excluding tall oil of heading No. 38.03.						
	3804.00.10	- ទឹកក្បុង ស៊ុលហ្វីតខាប់	- Concentrated sulphite lye	kg	7	0	10	0	
	3804.00.90	- ផ្សេងទៀត	- Other	kg	7	0	10	0	
38.05		ស្ករកៅស៊ូ ប្រេងគេរ៉េបង់ទីនឈើស្រល់ ឬសារធាតុស៊ុលហ្វាត និងប្រេងទែរប៉េនិចផ្សេងទៀតបានមកពីការបិទឬប្រព្រឹត្តិកម្មឈើ កូនីហ្វែទីប៉ង់តែនមិនទាន់ចំរាញ់ ប្រេងរោងចក្រក្រដាសមានប៉ីស៊ុលហ្វីត និងប៉ារ៉ាស៊ីមែនមិនទាន់ចំរាញ់ប្រេងស្រល់មានអាល់ហ្វាទែពីនុលជាអង្គធាតុសំខាន់ ។	Gum, wood or sulphate turpentine and other terpenic oils produced by the distillation or other treatment of coniferous woods; crude dipentene; sulphite turpentine and other crude para-cymene; pine oil containing alpha-terpineol as the main constituent.						
	3805.10.00	- ជ័រកាវ ប្រេងគេរ៉េបង់ទីន ឈើស្រល់ ឬសារធាតុស៊ុលហ្វាត	- Gum, wood or sulphate turpentine oils	kg	7	0	10	0	
	3805.90.00	- ផ្សេងទៀត	- Other	kg	7	0	10	0	
38.06		ជ័រស្រល់ និងអាស៊ីដជ័រឈើ ព្រមទាំងផលិតផលចេញពីនេះ ប្រេងជ័រស្រល់ និង ជ័ររលាយ ។	Rosin and resin acids, and derivatives thereof; rosin spirit and rosin oils; run gums.						
	3806.10.00	- ជ័រស្រល់ និង អាស៊ីដជ័រឈើ	- Rosin and resin acids	kg	7	0	10	0	
	3806.20.00	- អំបិលជ័រស្រល់ ឬអាស៊ីដជ័រឈើព្រមទាំងផលិតផលចេញពីជ័រស្រល់ និង អាស៊ីតជ័រឈើ ក្រៅពីអំបិលជ័រស្រល់ ។	- Salts of rosin, of resin acids or of derivatives of rosin or resin acids, other than salts of rosin adducts	kg	7	0	10	0	
	3806.30	- ជ័រ អេស្ទែរ	- Ester gums						
	3806.30.10	- - ទាំងដុំ	- - In blocks	kg	7	0	10	0	
	3806.30.90	- - ក្នុងទម្រង់ផ្សេងទៀត	- - In other forms	kg	7	0	10	0	

	3806.90	- ផ្សេងទៀត :	- Other :						
	3806.90.10	- - ជ័រទាំងដុំ	- - Run gums in bloks	kg	7	0	10	0	
	3806.90.90	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
38.07	3807.00.00	ជ័រស្រល់ និងអាស៊ីដជ័រឈើ ជាតិទឹកលាយប្រេងចំរាញ់ពីឈើម៉េទីឡែនជាតិខាប់ចំរាញ់ពីជ័រឈើ ជាតិខាប់បានមកពីរោងចក្រផលិតស្រាបៀរ ផលិតផលប្រហាក់ប្រហែលពីជ័រស្រល់ពីអាស៊ីដជ័រឈើ ឬជាតិខាប់ពីជ័រឈើ ។	Wood tar; wood tar oils; wood creosote; wood naphtha; vegetable pitch; brewers' pitch and similar preparations based on rosin, resin acids or on vegetable pitch.	kg	7	0	10	0	
38.08		ថ្នាំសំលាប់សត្វល្អិត ថ្នាំសំលាប់សត្វកកេរ ថ្នាំកំចាត់ផ្សិត ថ្នាំសំលាប់ស្មៅ ថ្នាំបន្ទួយ និងគីតការលូតលាស់នៃរុក្ខជាតិ ថ្នាំកំចាត់មេរោគ និងផលិតផលប្រហាក់ប្រហែល បង្ហាញឬដាក់ក្នុងកញ្ចប់សំរាប់លក់រាយ ឬក្នុងសភាពជាផលិតផល(ដូចជាខ្សែបង់ប្រេះ និងទៀនមានស្ពាន់ធ័រនិងក្រដាសសំលាប់រុយ) ។	Insecticides, rodenticides, fungicides, herbicides, anti-sprouting products and plant-growth regulators, disinfectants and similar products, put up in forms or packings for retail sale or as preparations or articles (for example, sulphur-treated bands, wicks and candles, fly-papers).						
	3808.50	- ទំនិញដែលចែងក្នុងកំណត់សំគាល់១នៃទីតាំងរងក្នុងជំពូកនេះ	- Goods specified in Subheading Note 1 to this Chapter:						
		- - ថ្នាំសំលាប់សត្វល្អិត :	- - Insecticides :						
	3808.50.11	- - - ការពារលើការសម្រាប់ផលិតថ្នាំសម្លាប់សត្វល្អិត :	- - - Intermediate preparations for the manufacture of insecticides :	kg	0	0	10	0	
	3808.50.12	- - - ជាទម្រង់ធូបមូស ឬម្សៅធូបមូស	- - - In the form of mosquito coils or mosquito coil powder	kg	0	0	10	0	
	3808.50.13	- - - ដាក់ក្នុងកំប៉ុងស្ព្រៃ	- - - In aerosol containers	kg	7	0	10	0	
	3808.50.19	- - - ផ្សេងទៀត :	- - -Other :	kg	7	0	10	0	
	3808.50.20	- - ថ្នាំសំលាប់ផ្សិត	- - Fungicides	kg	7	0	10	0	
	3808.50.30	- - ថ្នាំសំលាប់ស្មៅ ថ្នាំបន្ទួយ និងគីតការលូតលាស់នៃរុក្ខជាតិ :	- -Herbicides, anti-sprouting products and plant-growth regulators :	kg	0	0	10	0	
		- - ផ្សេងទៀត	- - Other						
	3808.50.40	- - ថ្នាំកំចាត់មេរោគ	- -Disinfectants	kg	0	0	10	0	

		- - ផ្សេងទៀត	- - Other						
	3808.50.91	- - - សម្រាប់ការពារឈើ សម្រាប់លាបមានជាតិសម្រាប់សម្លាប់សត្វល្អិត ឬផ្សិត	- - -Wood preservatives, being preparations other than surface coatings, containing insecticides or fungicides	KG	7	0	10	0	
	3808.50.99	- - - ផ្សេងទៀត	- - - Other	kg	7	0	10	0	
		- ផ្សេងទៀត	- Other						
	3808.91	- - ថ្នាំសំលាប់សត្វល្អិត	- - Insecticides :						
	3808.91.10	- - - វត្ថុធាតុដើមពាក់កណ្តាលសំរេចសម្រាប់ផលិតថ្នាំសំលាប់សត្វល្អិត	- - - Intermediate preparations for the manufacture of insecticides :	kg	7	0	10	0	
	3808.91.20	- - - ជាទម្រង់ធូបមូស ឬម្សៅធូបមូស	- - - In the form of mosquito coils or mosquito coil powder	kg	7	0	10	0	
	3808.91.30	- - - ដាក់ក្នុងកំប៉ុងស្ព្រៃ	- - - In aerosol containers	kg	7	0	10	0	
	3808.91.90	- - - ផ្សេងទៀត	- - - Other	kg	7	0	10	0	
	3808.92.00	- - ថ្នាំសំលាប់ផ្សិត	- - Fungicides	kg	7	0	10	0	
	3808.93.00	- - ថ្នាំសំលាប់ស្មៅ ថ្នាំបន្ថយ និងកំរិតការលូតលាស់នៃរុក្ខជាតិ :	- - Herbicides, anti-sprouting products and plant-growth regulators :	kg	7	0	10	0	
	3808.94.00	- - ថ្នាំកំចាត់មេរោគ	- - Disinfectants	kg	7	0	10	0	
	3808.99	- - ផ្សេងទៀត	- - Other						
	3808.99.10	- - - សម្រាប់ការពារឈើ សម្រាប់លាបមានជាតិសម្រាប់សម្លាប់សត្វល្អិត ឬផ្សិត	- - - Wood preservatives, containing insecticides or fungicides	kg	7	0	10	0	
	3808.99.90	- - - ផ្សេងទៀត	- - - Other	kg	7	0	10	0	
38.09		អង្គធាតុសំរាប់បញ្ចប់ឬបង្ហើយ ធាតុសំរាប់ពន្លឿន ការចាប់ពណ៌ និងផលិតផលផ្សេងទៀត (ឧទាហរណ៍សំរាប់តុបតែងលំអ) នៃប្រភេទប្រើក្នុងឧស្សាហកម្មវាយនភ័ណ្ឌ ក្រដាសស្បែក ឬឧស្សាហកម្មប្រហាក់ប្រហែលដែលមិនមានចែងឬបញ្ចូលនៅទីណាផ្សេងទៀត ។	Finishing agents, dye carriers to accelerate the dyeing or fixing of dyestuffs and other products and preparations (for example, dressings and mordants), of a kind used in the textile, paper, leather or like industries, not elsewhere specified or included.						

	3809.10.00	- ដែលមានវត្ថុធាតុ អាមីឡាសជាមូលដ្ឋាន	- With a basis of amylaceous substances	kg	7	0	10	0	
		- ផ្សេងទៀត :	- Other :						
	3809.91.00	- - ប្រភេទប្រើប្រាស់ក្នុងឧស្សាហកម្មវាយនភ័ណ្ឌ ឬឧស្សាហកម្មប្រហាក់ប្រហែល ។	- - Of a kind used in the textile or like industries	kg	7	0	10	0	
	3809.92.00	- - ប្រភេទប្រើប្រាស់ក្នុងឧស្សាហកម្មក្រដាស ឬឧស្សាហកម្មប្រហាក់ប្រហែល	- - Of a kind used in the paper or like industries	kg	7	0	10	0	
	3809.93.00	- - ប្រភេទប្រើប្រាស់ក្នុងឧស្សាហកម្មស្បែក ឬឧស្សាហកម្មប្រហាក់ប្រហែល	- - Of a kind used in the leather or like industries	kg	7	0	10	0	
38.10		ផលិតផលសំរាប់ត្រាំសំអាតលោហធាតុ ផលិតផលសំរាប់បន្ទរផ្សារ និង ផលិតផលជំនួយផ្សេងទៀតសំរាប់ផ្សារ លោហធាតុម្សៅខាប់ និងម្សៅសំរាប់ផ្សារដែលមានលោហធាតុ និងផលិតផលផ្សេងទៀត ផលិតផលសំរាប់ស្រោបធូបផ្សារ ។	Pickling preparations for metal surfaces; fluxes and other auxiliary preparations for soldering, brazing or welding; soldering, brazing or welding powders and pastes consisting of metal and other materials; preparations of a kind used as cores or coatings for welding electrodes or rods.						
	3810.10.00	- ផលិតផលសំរាប់ត្រាំសំអាតលោហធាតុ ម្សៅខាប់ និងម្សៅសំរាប់ផ្សារដែលមានលោហធាតុ និងផលិតផលផ្សេងទៀត ។	- Pickling preparations for metal surfaces, soldering, brazing or welding powders and pastes consisting of metal and other materials	kg	7	0	10	0	
	3810.90.00	- ផ្សេងទៀត	- Other	kg	7	0	10	0	
38.11		ផលិតផលការពារផ្ទុះ ផលិតផលការពារច្រេះ វត្ថុធាតុបន្ថែមអោយស្អិត វត្ថុធាតុកែលំអភាពខាប់ វត្ថុធាតុបន្ថែមសំរាប់ការពារការពុក និងវត្ថុធាតុបន្ថែមផ្សេងទៀតសំរាប់ប្រេងខនិជ (រាប់បញ្ចូលទាំងប្រេងសាំង) ឬសំរាប់វត្ថុរាវផ្សេងទៀតប្រើក្នុងទិសដៅតែមួយដូចប្រេងខនិជ។	Anti-knock preparations, oxidation inhibitors, gum inhibitors, viscosity improvers, anti-corrosive preparations and other prepared additives, for mineral oils (including gasoline) or for other liquids used for the same purposes as mineral oils.						
		- ប្រេងការពារការបះទង្គិច :	- Anti - knock preparations :						

	3811.11.00	- - មានមូលដ្ឋានសំណ	- - Based on lead compounds	kg	7	0	10	0	
	3811.19.00	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
		- វត្ថុធាតុបន្ថែមសំរាប់ប្រេងរំអិល :	- Additives for lubricating oils :						
	3811.21	- - មានប្រេងឥន្ធនៈ ឬប្រេងបានមកពីប៊ីទីមមនិជ	- - Containing petroleum oils or oils obtained from bituminous minerals						
	3811.21.10	- - - វេចខ្ចប់សម្រាប់លក់រាយ	- - - Put up for retail sale	kg	7	10	10	0	
	3811.21.90	- - - ផ្សេងទៀត មិនដាក់ក្នុងកំប៉ុងស្ព្រៃ	- - - Other	kg	7	10	10	0	
	3811.29.00	- - ផ្សេងទៀត	- - Other	kg	7	10	10	0	
	3811.90	- ផ្សេងទៀត :	- Other :						
	3811.90.10	- - សម្រាប់ការពារច្រែះ ឬស្នឹម	- - Rust preventatives and corrosion inhibitors	kg	7	0	10	0	
	3811.90.90	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
38.12		ធាតុពន្លឿនកៅស៊ូ ផលិតផលធ្វើឱ្យកៅស៊ូ ឬប្លាស្ទិកទន់ដែលមិនមានចែង ឬបញ្ចូលនៅទីណាមួយ ផលិតផលការពារច្រែះផលិតផលសំរាប់ស្ថេរភាពកៅស៊ូ និងប្លាស្ទិក	Prepared rubber accelerators; compound plasticisers for rubber or plastics, not elsewhere specified or included; anti-oxidising preparations and other compound stabilisers for rubber or plastics.						
	3812.10.00	- ផលិតផល ពន្លឿនកៅស៊ូកៅឡូ	- Prepared rubber accelerators	kg	7	0	10	0	
	3812.20.00	- ផលិតផល ធ្វើឱ្យកៅស៊ូ និងប្លាស្ទិកយឺតល្អ	- Compound plasticisers for rubber or plastics	kg	7	0	10	0	
	3812.30	- ផលិតផលការពារច្រែះ និងផលិតផលសំរាប់ធ្វើអោយមានលំនឹងកៅស៊ូ និងប្លាស្ទិក ។	- Anti-oxidising preparations and other compound stabilisers for rubber or plastics						
	3812.30.10	- - កាបោនស	- - White carbon	kg	7	0	10	0	
	3812.30.90	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
38.13	3813.00.00	ផលិតផល និងបន្ទុកសំរាប់ពន្លត់ភ្លើង គ្រាប់បែកដៃ និងគ្រាប់បែកសំរាប់ពន្លត់អគ្គិភ័យ ។	Preparations and charges for fire-extinguishers; charged fire-extinguishing grenades.	kg	7	0	10	0	

38.14	3814.00.00	វត្ថុរំលាយសរីរាង្គមិនមានចែង ឬរៀបរាប់នៅកន្លែងផ្សេង ផលិតផលសំអាតថ្នាំលាប និងវ៉ែនីចេញ ។	Organic composite solvents and thinners, not elsewhere specified or in cluded: prepared paint or varnish removers.	kg	35	0	10	0	
38.15		វត្ថុធាតុផ្តើមប្រតិកម្ម កន្សៀនប្រតិកម្ម និងផលិតផលជំនួយប្រតិកម្ម ដែលមិនបានចែងឬបញ្ចូលនៅទីណាផ្សេង ។	Reaction initiators, reaction accelerators and catalytic preparations, not elsewhere specified or included.						
		- កាតាលីករទ្រទ្រង់ :	- Supported catalysts:						
	3815.11.00	- - ដែលមាននីកែល ឬល្បាយនីកែលជាវត្ថុធាតុសកម្ម	- - With nickel or nickel compounds as the active substance	kg	7	0	10	0	
	3815.12.00	- - ដែលមានលោហធាតុមានតំលៃឬល្បាយលោហធាតុមានតំលៃជាវត្ថុធាតុសកម្ម	- - With precious metal or precious metal compounds as the active substance	kg	7	0	10	0	
	3815.19.00	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
	3815.90.00	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
38.16		ស៊ីម៉ងត៍ធន់នឹងកំដៅ បាយអរ បេតុង និងសមាសភាពប្រហាក់ប្រហែលមានកំដៅ ក្រៅពីផលិតផលនៃទីតាំងលេខ ៣៨.០១ ។	**Refractory cements, mortars, concretes and similar compositions, other than products of heading No. 38.01.**						
	3816.00.10	- ស៊ីម៉ងត៍រឹង	- Refractory cements	kg	7	0	10	0	
	3816.00.90	- ផ្សេងទៀត	- Other	kg	7	0	10	0	
38.17	3817.00.00	អាល់គីលបង់ហ្សែនជាល្បាយ និងអាល់គីលណាហ្វតាឡែនជាល្បាយ ក្រៅពីផលិតផលនៃទីតាំងលេខ ២៧.០៧ ឬ ២៩.០២ ។	Mixed alkylbenzenes and mixed alkylnaphthalenes, other than those of heading No. 27.07 or 29.02.	kg	7	0	10	0	
38.18	3818.00.00	ធាតុគីមីបន្ថែមប្រើក្នុងអេឡិចត្រូនិកជាថាស បន្ទះស្តើង ឬរាងប្រហាក់ប្រហែល ល្បាយគីមីបន្ថែមប្រើក្នុងអេឡិចត្រូនិក ។	Chemical elements doped for use in electronics, in the form of discs, wafers or similar forms; chemical compounds doped for use in electronics.	kg	7	0	10	0	
38.19	3819.00.00	ប្រេងហ្វ្រាំងអ៊ីដ្រូលិច ឬវត្ថុរាវផ្សេងទៀតសំរាប់បញ្ជូនបែបអ៊ីដ្រូលិចមានឬគ្មានប្រេងមកពីតេលៈសិលា ឬប្រេងមកពីរ៉ែប៊ីទុំមតិចជាង ៧០% គិតជាទំងន់	Hydraulic brake fluids and other prepared liquids for hydraulic transmission, not containing or containing less than 70 % by weight of petroleum oils or oils obtained from bituminous minerals.	kg	35	10	10	0	

38.20	3820.00.00	ផលិតផលប្រឆាំងនឹងការកក និងផលិតផលកំចាត់ទឹកកក	Anti-freezing preparations and prepared de-icing fluids.	kg	35	0	10	0	
38.21		វត្ថុធាតុរៀបចំឡើង សំរាប់បណ្តុះ ឬថែរក្សាអតិសុខុមប្រាណរួមទាំងមេរោគ ឬរុក្ខជាតិ និងកោសិកាមនុស្ស ឬសត្វ ។	**Prepared culture media for development or maintenance of micro-organisms (including viruses and the like) or of plant, human or animal cells.**						
	3821.00.10	- វត្ថុធាតុរៀបចំឡើង សំរាប់បណ្តុះអតិសុខុមប្រាណ	- Prepare culture media for the development of micro-organisms	kg	7	0	10	0	
	3821.00.90	- ផ្សេងទៀត	- Other	kg	7	0	10	0	
38.22		ប្រតិករផ្សំឡើងសំរាប់រោគវិនិច្ឆ័យ ឬមន្ទីរពិសោធន៍ មានវត្ថុធាតុទ្រទ្រង់និងប្រតិករផ្សំឡើងសំរាប់រោគវិនិច្ឆ័យ ឬមន្ទីរពិសោធន៍ទោះមាន ឬគ្មានវត្ថុធាតុទ្រទ្រង់ក្រៅពីផលិតផលនៃទីតាំងលេខ ៣០.០២ ឬ ៣០.០៦ ។	**Diagnostic or laboratory reagents on a backing and prepared diagnostic or laboratory reagents whether or not on a backing, other than those of heading No. 30.02 or 30.06.Certified reference materials.**						
	3822.00.10	- អង្គធាតុរឺវត្ថុធាតុក្នុងទីពិសោធន៍ជា បន្ទះ សន្លឹក ហ្វីល ម្សៅ និងអង្កត់ ប្លាស្ទិក	- Plates, sheets, film, foil and strip of plastics impregnated or coated with diagnostic or laboratory reagents	kg	7	0	10	0	
	3822.00.20	- អង្គធាតុរឺវត្ថុធាតុប្លាស្ទិកប្រើក្នុងទីពិសោធន៍ជា បន្ទះ សន្លឹក ហ្វីល ម្សៅ និងអង្កត់	- Paperboard, cellulose wadding and web of cellulose fibres impregnated or coated with diagnostic or laboratory reagents	kg	7	0	10	0	
	3822.00.30	- អង្កត់សូចនាករដែលបានសំលាប់មេរោគ	- Sterilisation indicator strips and tapes	kg	7	0	10	0	
	3822.00.90	- ផ្សេងទៀត	- Other	kg	7	0	10	0	
38.23		អាស៊ីដខ្លាញ់ម៉ូណូកាបុកស៊ីលិកឧស្សាហកម្ម ប្រេងអាស៊ីដបានពីការចំរាញ់ អាល់កុល ខ្លាញ់នៃឧស្សាហកម្ម ។	**Industrial monocarboxylic fatty acids ;acids oils from refining; industrial fatty alcohols .**						
		- អាស៊ីដខ្លាញ់ម៉ូណូកាបុកស៊ីលិកឧស្សាហកម្ម ប្រេងអាស៊ីដបានពីការចំរាញ់	- Industrial monocarboxylic fatty acids ;acids oils from refining :						
	3823.11.00	- - អាស៊ីដ ស្តេអារិច	- - stearic acid	kg	7	0	10	0	
	3823.12.00	- - អាស៊ីដ អូឡេអ៊ិច	- - Oleic acid	kg	7	0	10	0	
	3823.13.00	- - អាស៊ីដខ្លាញ់ ប្រេងតាល់	- - Tall oil fatty acids	kg	7	0	10	0	
	3823.19	- - ផ្សេងទៀត :	- - Other :						
	3823.19.10	- - - អាស៊ីតប្រេងដែលបានមកពីការចម្រាញ់	- - - Acid oils from refining	kg	7	0	10	0	

	3823.19.90	- - - ផ្សេងទៀត	- - - Other	kg	7	0	10	0	
	3823.70	- អាល់កុល ខ្លាញ់នៃឧស្សាហកម្ម	- Industrial fatty alcohols						
	3823.70.10	- - ជាទម្រង់ក្រមួន	- - In the form of wax	kg	7	0	10	0	
	3823.70.90	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
38.24		គ្រឿងភ្ជាប់សំរាប់ពុម្ព ឬស្នូលឡើលាយផលិតផលគីមី និងផលិតផលនៃឧស្សាហកម្មគីមី ឬពាក់ព័ន្ធ (រាប់បញ្ចូលទាំងផលិតផលដែលមាន ល្បាយផលិតផលធម្មជាតិ) គ្មានចែង ឬបញ្ចូលនៅទីណាផ្សេងផលិតផលសំណល់គីឧស្សាហកម្ម គីមីឬពាក់ព័ន្ធគ្មានចែងនៅទីណាផ្សេង ។	Prepared binders for foundry moulds or cores; chemical products and preparations of the chemical or allied industries (including those consisting of mixtures of natural products), not elsewhere specified or included; residual products of the chemical or included						
	3824.10.00	- គ្រឿងភ្ជាប់សំរាប់ពុម្ព និងស្នូលឡើលាយ	- Prepared binders for foundry moulds or cores	kg	7	0	10	0	
	3824.30.00	- កាបៀរ លោហៈធាតុមិនផ្តុំលាយជាមួយគ្នា ឬជាមួយគ្រឿងភ្ជាប់	- Non-agglomerated metal carbides mixed' together or with metalicbinders	kg	7	0	10	0	
	3824.40.00	- គ្រឿងបន្ថែមផ្សំ សំរាប់ស៊ីម៉ង់ត៍ បាយអរ និងបេតុង	- Prepared additives for cements, mortars or concretes	kg	7	0	10	0	
	3824.50.00	- បាយអរ និងបេតុង មិនធន់កំដៅ	- Non-refractory mortars and concretes	kg	7	0	10	0	
	3824.60.00	- ស័រប៊ីតុល ក្រៅពីផលិតផល នៃទីតាំងលេខ ២៩០៥.៤៤ ។	- Sorbitol other than that of subheading No. 2905.44	kg	7	0	10	0	
		- ល្បាយមានប៉េហាឡូសែននៃអ៊ីដ្រូកាបោនអាស៊ីក្លិចដែលមានអាឡូសែនផ្សេងគ្នាពីរឬច្រើនជាង :	- Mixtures containing perhalogenated derivatives of acyclic hydrocarbons containing two or more different halogents :						
	3824.71.00	- - ដែលមានអ៊ីដ្រូកាបោន អាស៊ីក្លិចប៉េហាឡូសែនតែជាមួយហ្វ្លុយអូរ៊ីន និង ក្លរ៊ីន	- - Containing acyclic hydrocarbons perhalogenated only with fluorine and chlorine	kg	7	0	10	0	
	3824.72.00	- - ដែលមានប្រូមូក្លរូមេតាន, ប្រូមូទ្រីហ្វ្លុយអូរូមេតាន ឬ ឌីប្រូមូតេត្រាហ្វ្លុយអូរអេតាន	- - containing bromochlorodifluoromethane, bromotrifluoromethane or dibromotetrafluoroethanes	kg	7	0	10	0	
	3824.73.00	- - ដែលមានអ៊ីដ្រូប្រូមូហ្វ្លុយអូរូកាបោន	- - Containing hydrobromofluorocarbons (HBFCs)	kg	7	0	10	0	

	3824.74.00	- - ដែលមានអ៊ីដ្រូក្លរ៉ូហ្វ្លុយអរ៉ូកាបោន ទោះជាមាន ឬ មិនមានភើហ្វ្លុយអរ៉ូកាបោន ឬ អ៊ីដ្រូហ្វ្លុយអរ៉ូកាបោន តែមិនមាន ក្លរ៉ូហ្វ្លុយអរ៉ូកាបោន	- - Containing hydrochlorofluorocarbons (HCFCs), whether or not containing perfluorocarbons (PFCs) or hydrofluorecarbons (HFCs) but not containing chlorofluorocarbons (CFCs)	kg	7	0	10	0	
	3824.75.00	- - ដែលមានកាបោន តេត្រាក្លរីត	- - Containing carbon tetrachloride	kg	7	0	10	0	
	3824.76.00	- - ដែលមាន ១,១,១ - ទ្រីក្លរអេតាន (មេទីលក្លរ៉ូហ្វម)	- - Containing 1,1,1-trichloroethane (methyl chloroform)	kg	7	0	10	0	
	3824.77.00	- - ដែលមានប្រូម៉ូមេតាន, (មេទីល ប្រូមីដ) ឬ ប្រូម៉ូក្លរ៉ូមេតាន	- - Containing bromomethane (methyl bromide) or bromochloromethane	kg	7	0	10	0	
	3824.78.00	- - ដែលមានភើហ្វ្លុយអរ៉ូកាបោន ឬអ៊ីដ្រូហ្វ្លុយអរ៉ូកាបោន តែមិនមានក្លរ៉ូហ្វ្លុយអរ៉ូកាបោន ឬ អ៊ីដ្រូក្លរ៉ូហ្វ្លុយអរ៉ូកាបោន	- - containing perfluorocarbons (PFCs) or hydrofluorocarbons (HFCs),but not containing chlorofluorocarbons (CFCs) or hydrochlorofluorocarbons (HCFCs)	kg	7	0	10	0	
	3824.79.00	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
		- ល្បាយដែលមានអុកស៊ីរ៉ាន (អេទីឡែនអុកស៊ីដ) ប៉ូលីប្រូមីណាត ប៊ីភេនីល ប៉ូលីក្លរីណាត ប៊ីភេនីល ប៉ូលីក្លរីណាត ទែភេនីល ឬ ទ្រីស (២,៣- ឌីប្រូម៉ូប្រូពីល) ហ្វូស្វាត	- Mixtures and preparations containing oxirane (ethylene oxide), polybrominated biphenyls (PBBs), polychlorinated biphenyls (PCBs), polychlorinated terphenyls (PCTs) or tris (2,3-dibromopropyl) phosphate:						
	3824.81.00	- - ដែលមានអុកស៊ីរ៉ាន (អេទីឡែនអុកស៊ីដ)	- - Containing oxirane (ethylene oxide)	kg	7	0	10	0	
	3824.82.00	- - ដែលមានប៉ូលីក្លរីណាត ប៊ីភេនីល ប៉ូលីក្លរីណាត ទែភេនីល ឬប៉ូលីប្រូមីណាតប៊ីភេនីល	- - Containing polychlorinated biphenys (PCBs), polychlorinated terphenyls (PCTs) or polybrominated biphenyls (PBBs)	kg	7	0	10	0	
	3824.83.00	- - ដែលមានទ្រីស (២,៣- ឌីប្រូម៉ូប្រូពីល)ហ្វូស្វាត	- - Containing tris (2,3-dibromopropyl) phophate	kg	7	0	10	0	
	3824.90	- ផ្សេងទៀត :	- Other :						
	3824.90.10	- - វត្ថុធាតុលុបទឹកខ្មៅ វត្ថុធាតុកែស្តង់ស៊ីល វត្ថុរាវសំរាប់កែផ្សេងទៀតដាក់ក្នុងសំបកវេចខ្ចប់សំរាប់លក់រាយ ។	- - Ink removers, stencil correctors and other correcting fluids, put up in packings for retail sale	kg	7	0	10	0	
	3824.90.20	- - គីមីចម្រុះប្រើសម្រាប់ឧស្សាហកម្មម្ហូបអាហារ	- - Mixtures of chemicals, of a kind used in the manufacture of foodstuff	kg	7	0	10	0	
	3824.90.30	- - ថ្នាំថតចម្លងដែលមានជាតិហ្គេលទីនដែលនៅជាដុំ ឬរៀបចំរួចរាល់ដើម្បីប្រើប្រាស់ ឧទា លើក្រដាស ឬក្រណាត់	- - Copying pastes with a basis of gelatin whether presented in bulk or ready for use (e.g. on a paper or textile backing)	kg	7	0	10	0	
	3824.90.40	- - ថ្នាំលាបកត់អសរីរៈ	- - Composite inorganic solvents	kg	7	0	10	0	

	3824.90.50	- - ប្រេងអាសេតូន	- - Acetone oil	kg	7	0	10	0	
	3824.90.60	- - សារធាតុចម្រុះដែលមានជាតិប៊ីចេង	- - Preparations or mixtures containing monosodium glutamate	kg	7	0	10	0	
	3824.90.90	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
38.25		ផលិតផលជាកាកសំណល់គីមី ឬឧស្សាហកម្ម ដែលគ្មានចែងនៅកន្លែងផ្សេង រួមបញ្ចូលទាំងសំណល់ពីទីក្រុង ភក់ជ្រាំ និងសំណល់ផ្សេងទៀត ដូចមានចែងក្នុងកំណត់សម្គាល់លេខ ៦ នៅក្នុងជំពូកនេះ	Residual products of the chemical or allied industries, not elsewhere specified or included; municipal waste; sewage sludge; other wastes specified in Note 6 to this Chapter.						
	3825.10.00	- សំណល់ពីទីក្រុង	- Municipal waste	kg	7	0	10	0	
	3825.20.00	- ភក់ ឬជ្រាំ	- Sewage sludge	kg	7	0	10	0	
	3825.30.00	- សំណល់ពីមន្ទីរពេទ្យ	- Clinical waste	kg	7	0	10	0	
		- សំណល់ពីសារធាតុរលាយសរីរៈ	- Waste organic solvents :						
	3825.41.00	- - ដោយហាឡូសែន	- - Halogenated	kg	7	0	10	0	
	3825.49.00	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
	3825.50.00	- សំណល់ជាតិដែកពីសារធាតុស្រោង ពីប្រេងអ៊ីដ្រូលិក ពីប្រេងហ្វ្រាំង និងថ្នាំការពារត្រជាក់	- Wastes of metal pickling liquors, hydraulic fluids, brake fluids and anti-freeze fluids	kg	7	0	10	0	
		- សំណល់ផ្សេងទៀត ពីគីមី ឬឧស្សាហកម្ម	- Other wastes from chemical or allied industries:						
	3825.61.00	- - ផ្សំឡើងដោយគីមីសរីរៈ	- - Mainly containing organic constituents	kg	7	0	10	0	
	3825.69.00	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
	3825.90.00	- ផ្សេងទៀត	- Other	kg	7	0	10	0	

ផ្នែកទី VII

វត្ថុធាតុផ្លាស្ទិក និងវត្ថុធ្វើពីផ្លាស្ទិក កៅស៊ូ និងវត្ថុធ្វើពីកៅស៊ូ

SECTION VII

PLASTICS AND ARTICLES THEREOF; RUBBER AND ARTICLES THEREOF

កំណត់សំគាល់

Notes

1.- ផលិតផលបង្ហាញជាឈុតដែលមានធាតុច្រើនរួមផ្សំដោយឡែកៗ ហើយដែលស្ថិតទាំងស្រុងឬភាគខ្លះនៅក្នុងផ្នែកនេះ ហើយត្រូវបានគេគ្រោងលាយជាមួយគ្នាដើម្បីទទួលបានផលិតផលមួយនៃផ្នែក VI ឬ VII ត្រូវចាត់ថ្នាក់ទៅក្នុងទីតាំងពាក់ព័ន្ធនឹងផលិតផលនោះដោយតែវត្ថុធាតុរួមផ្សំត្រូវបាន :

Goods put up in sets consisting of two or more separate constituents, some or all of which fall in this Section and are itended to be mixed together to obtain a product of Section VI or VII, are to be classified in the heading appropriate to that products, provided that the constituent are:

(a) ក្រោយពីការវេច វេចខ្ចប់ ដោយស្គាល់ជាក់លាក់ថាសំរាប់តែប្រើប្រាស់ជាមួយគ្នាដោយគ្មានត្រូវការការវេច វេចខ្ចប់ឡើងវិញ ។

having regard to the manner in which they are put up, clearly identifiable as being intended to be used together without first being repacked;

(b) បង្ហាញក្នុងពេលជាមួយគ្នា និង

presented together; and

(c) ស្គាល់ដោយធាតុ ឬចំនួនវត្ថុធាតុនីមួយៗជាការបំពេញបន្ថែមគ្នាទៅវិញទៅមក។

identifiable, whether by their nature or by the relative proportions in which they are present, as being complementary one to another.

2.- លើកលែងតែទំនិញដែលក្នុងទីតាំងលេខ ៣៩.១៨ ឬ ៣៩.១៩ ត្រូវចាត់ទៅជំពូក ៤៩ នូវវត្ថុធាតុផ្លាស្ទិក កៅស៊ូ និងវត្ថុធ្វើពីវត្ថុធាតុទាំងនោះ ដែលបំពាក់នូវរូបភាពបោះពុម្ពឬអក្សរដោយដៃហើយគ្មានលក្ខណៈបន្ទាប់បន្សំប្រៀបធៀបទៅនឹងការប្រើប្រាស់ដើមរបស់វា ។

Expcept for the goods of heading No.39.18 or 39.19, plastics, rubber, and articles thereof, printed with motifs, characters or pictorial representations, which are not merely incidental to theprimary use of the goods, fall in Chapter 49.

ជំពូកទី ៣៩

វត្ថុធាតុប្លាស្ទិក និងវត្ថុធ្វើពីជាតិប្លាស្ទិក

Chapter 39

Plastics and Articles Thereof

កំណត់សំគាល់

Notes

1.- ដែលហៅថា "វត្ថុធាតុប្លាស្ទិក" គឺជាវត្ថុធាតុ នៃទីតាំងលេខ ៣៩.០១ ទៅ៣៩.១៤ កាលបើវាត្រូវទទួលឥទ្ធិពលក្រៅណាមួយ (ជាទូទៅកំដៅនិងសំពាធគឺជាអន្តរាគមន៍នៃសុលវ៉ង់ ឬប្លាស្ទីហ្វីយ៉ង់អាចទទួលបានក្នុងពេលប៉ូលីមែរកម្មឬភាពកម្មួយដែលវត្ថុធាតុទាំងនោះបានកាត់ចេញវិញ ដោយសារការស្ងួត ។

Throughout the Nomenclature the expression "plastics" means those materials of headings Nos. 39.01 to 39.14 which are or have been capable, either at the moment of polymerisation or at some subsequent stage, of being formed under external influence (usually heat and pressure, if necessary with a solvent or plasticiser) by moulding, casting, extruding, rolling or other process into shapes which are retained on the removal of the external influence.

ក្នុងនាមវល្លិ វត្ថុធាតុប្លាស្ទិកមានន័យសំដៅទៅលើវត្ថុធាតុជាសរសៃប្លាស្ទិកដែលគេធ្វើអោយកាន់តែស្វិត។ ពាក្យនេះគេមិនប្រើសំដៅទៅលើវត្ថុធាតុវាយនភ័ណ្ឌដែលមានចែងក្នុងផ្នែក XI ។

Throughout the Nomenclature any reference to "plastics" also includes vulcanised fibre. The expression, however, does not apply to materials regarded as textile materials of Section XI.

2.- ជំពូកនេះមិនរួមបញ្ចូល

(a) ជាតិក្រមួនចែងក្នុងទីតាំងលេខ ២៧.១២ ឬ ៣៤.០៤ ។

(b) ធាតុបន្សំសរីរាង្គដែលខុសប្លែកពីភាគគំណត់បង្កគីមី ជំពូក ២៩ ។

(c) អ៊ីបប៉ារីន និងអំបិលរបស់វា "លេខ ៣០.០១"

This Chapter does not cover :

(a) Waxes of heading No. 27.12 or 34.04;

(b) Separate chemically defined organic compounds (Chapter 29);

(c) Heparin or its salts (heading No. 30.01);

(d)	សូលុយស្យុង (ក្រៅពីកូឡូឌីយ៉ុង) នៅក្នុងអង្គធាតុរំលាយកាវសរីរាង្គដែលងាយហួតហើយនៃផលិតផលដែលបានបញ្ជាក់ក្នុងទីតាំងលេខ ៣៩.០១ ដល់ ៣៩.១៣ កាលបើទំងន់នៃអង្គធាតុរំលាយលើសពី ៥០% នៃ ទំងន់របស់សូលុយស្យុង (ទីតាំងលេខ ៣២.០៨) សន្លឹកឬបន្ទះសំរាប់វាយផ្លាកសញ្ញាធ្វើពីផែកទីតាំងលេខ ៣២.១២ ។	Solutions (other than collodions) consisting of any of the products specified in headings Nos. 39.01 to 39.13 in volatile organic solvents when the weight of the solvent exceeds 50 % of the weight of the solution (heading No. 32.08); stamping foils of heading No. 32.12;
(e)	ភ្នាក់ងារសំរាប់សំអាតផ្ទៃក្រៅសរីរាង្គផលិតផលទីតាំងលេខ ៣៤.០២	Organic surface-active agents or preparations of heading No. 34.02;
(f)	ជ័ររំលាយ និងជ័រដែលមានជាតិអេស្ទែរ "ទីតាំងលេខ ៣៨.០៦" ។	Run gums or ester gums (heading No. 38.06);
(g)	ប្រតិករផ្សំឡើងសំរាប់រោគវិនិច្ឆ័យ ឬមន្ទីរពិសោធន៍ បានវត្ថុធាតុពីជាតិផ្លាស្ទិក (ទីតាំងលេខ ៣៨.២២) ។	Diagnostic or laboratory reagents on a backing of plastics (heading No. 38.22);
(h)	កៅស៊ូសំយោគដូចដែលកំណត់នៅក្នុងជំពូក ៤០ និងវត្ថុធ្វើពីកៅស៊ូសំយោគ ។	Synthetic rubber, as defined for the purposes of Chapter 40, or articles thereof;
(ij)	កែប និងគ្រឿងបង្ហៀរសេះ (ទីតាំងលេខ ៤២.០១) វ៉ាលីស្បែក កាបូបយួរដៃ និងធុងផ្សេងទៀតនៃលេខ ៤២.០២ ។	Saddlery or harness (heading No. 42.01) or trunks, suitcases, handbags or other containers of heading No. 42.02;
(k)	វត្ថុដែលធ្វើដោយការត្បាញ ឬក្រង នៃជំពូក ៤៦	Plaits, wickerwork or other articles of Chapter 46;
(l)	ក្រដាសបិទជញ្ជាំងដែលមានចែងនៅក្នុងទីតាំងលេខ ៤៨.១៤ ។	Wall coverings of heading No. 48.14;
(m)	ផលិតផលនៃផ្នែក XI "វត្ថុវាយនភ័ណ្ឌ និងរបស់ធ្វើពីវាយនភ័ណ្ឌ" ។	Goods of Section XI (textiles and textile articles);
(n)	វត្ថុនៃផ្នែកXII (ស្បែកជើងនិងផ្នែកខ្លះទៀតនៃស្បែកជើងវត្ថុប្រើសំរាប់ឬពាក់លើក្បាល ឆ័ត្រ និងឆ័ត្រតាំងថ្ងៃ ឈើច្រត់ រំពាត់ខ្សែតី ឬ ភាគរបស់វា ។	Articles of Section XII (for example, footwear, headgear, umbrellas, sun umbrellas, walking-sticks, whips, riding- crops or parts thereof);

(o)	គ្រឿងអលង្ការមនោវិកែត ទីតាំងលេខ ៧១.១៧ ។	Imitation jewellery of heading No. 71.17;
(p)	វត្ថុនៃផ្នែក XVI (ម៉ាស៊ីន និងគ្រឿងប្រើប្រាស់ក្នុងផ្ទះជាមេកានិកឬអគ្គិសនី)	Articles of Section XVI (machines and mechanical or electrical appliances);
(q)	គ្រឿងបំលាស់វេយន្ត ឬយានយន្តនៃផ្នែក XVII	Parts of aircraft or vehicles of Section XVII;
(r)	វត្ថុថែងក្នុងជំពូក ៩០ (ធាតុអុបទិក ផៃវ៉ែនតា វត្ថុប្រើសំរាប់គូរកំនូរផាលើម) ។	Articles of Chapter 90 (for example, optical elements, spectacle frames, drawing instruments);
(s)	វត្ថុថែងក្នុងជំពូក ៩១ "នាឡិកា នាឡិកាដៃ ឬស្រោមនាឡិកាផាលើម" ។	Articles of Chapter 91 (for example, clock or watch cases);
(t)	វត្ថុថែងក្នុងជំពូក ៩២ (គ្រឿងភ្លេង និងភាគដទៃទៀតរបស់វាផាលើម)។	Articles of Chapter 92 (for example, musical instruments or parts thereof);
(u)	វត្ថុដែលមានថែងនៅក្នុងជំពូក៩៤ (គ្រឿងសង្ហារឹម ឧបករណ៍សំរាប់បំភ្លឺយីហោបំភ្លឺគ្រឿងសំណង់ដែលបំរុងទុកជាមុន)។	Articles of Chapter 94 (for example, furniture, lamps and lighting fittings, illuminated signs, prefabricated buildings);
(v)	វត្ថុថែងក្នុងជំពូក ៩៥ (ប្រដាប់ក្មេងលេង ប្រដាប់ល្បែង គ្រឿងប្រដាប់ប្រដាសំរាប់កីឡា)។	Articles of Chapter 95 (for example, toys, games, sports requisites); or
(u)	វត្ថុថែងក្នុងជំពូក ៩៦ (ច្រាស ខ្សែរអារ៉ូត ឆ្នុក ក្រាស់ ចង្កឹ បំពង់ខ្សៀ ខ្សៀខ្លី សំរាប់តកន្ទុយបារី និងរបស់ស្រដៀងគ្នាផ្សេងទៀត ភាគនៃបំពង់ទឹកក្តៅ ស៊ីឡូ)	Articles of Chapter 96 (for example, brushes, buttons, slide fasteners, combs, mouthpieces or stems for smoking pipes, cigarette-holders or the like, parts of vacuum flasks or the like, pens, propelling pencils).

3.- រាល់បញ្ញាតែក្នុងទីតាំងលេខ ៣៩.០១ ទៅ ៣៩.១១ នូវផលិតផលណាដែលបានមកពីសំយោគគីមីហើយចូលមកប្រភេទខាងក្រោម :

Headings Nos. 39.01 to 39.11 apply only to goods of a kind produced by chemical synthesis, falling in the following categories :

(a)	ប៉ូលីយូឡេហ្វីនសំយោគរាវដោយមានចំណុះតិចជាង ៦០% ដែលគេបិតនៅសីតុណ្ហភាព ៣០០ °c បន្ទាប់ពីបំប្លែងទៅជា ១០.១៣ millibar ដោយអនុវត្តនូវវិធីបិត នៅក្រោមសំពាធទាប(ទីតាំងលេខ៣៩.០១ និងទីតាំងលេខ៣៩.០២)។	Liquid synthetic polyolefins of which less than 60 % by volume distils at 300 °C, after conversion to 1.013 millibars when a reduced-pressure distillation method is used (headings Nos. 39.01 and 39.02);

តទៅរាជកិច្ចលេខ ៥៩